ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៨ លេខ ២ ខែកុម្ភៈ ព. ស. ២៤៩៨ គ. ស. ១៩៥៦

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា*

## បញ្ជីរឿង

— ការបួសក្នុងពុទ្ធសាសនា ........ លោកស្រី-អ៊ុ ............ ១០៣
— ការចំរើននឹងការសាបសូន្យធម្មវិន័យក្នុង
ពុទ្ធសាសនា............. ព្រះទេពសត្ថា កឹម-ទូរ ...... ១១១
— សតិសម្បជញ្ញកថា .......... ព្រះបាឡាត់-សុង-ស៊ីវ ...... ១១៨
— បញ្ញាសជាតក ភាគទី ៤ (តមក) ... បណ្ឌិត្យមហា ឈឹម-ស៊ុមន៍ ... ១២៩

*ផ្នែកអក្សរសាស្ត្រ*

— ទំនៀមទម្លាប់ស្ដ្រីនៅស្រុកទីបេ ...... អ្នកស្រី សារិះយ៉ាន ...... ១៤១
— សុភាសិតរាជនីតិ ពាក្យកាព្យ...... អ្នកឧកញ៉ា នៅ ........ ១៤៧
— ពេជ្រព្រះរាជា (តមក) ........ លោក ស៊ិន-ហ៊ាន ...... ១៥៣
— រឿងសាមកុក (តមក)......... ឧកញ៉ា នូ-កន ....... ១៥៩
— ដំណឹងតាមច្បាប់ក្នុងកន្តារៈ (តចប់) .. លោក ផេង-ជ្រីវ ...... ១៦៧
— រឿងបល្ល័ង្កទិព្វ (តមក)...... លោក វ៉ាយ-ប៊ុក ...... ១៨២

*កំណត់នឹងប្រវត្តិការណ៍*

- ព្រះអនិច្ចធម្មនៃសម្ដេចព្រះសង្ឃនាយក
គណៈធម្មយុត្តិកនិកាយ ......... លោកប៊ូ-ប៉ូ ............... ១៨៨

មួយឆ្នាំមាន ១២ សៀវភៅ — ជំរៀបជាវ ២៣០,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

### PARTIE RELIGIEUSE:


| | | Page |
|---|---|---|
| — L'ordination bouddhique . . . | *M. SREY-OU* . . . . . . . | 103 |
| — Le progrès et la décadence du Bouddhisme . . . . . . | *Vén. KEM-TO* . . . . . . . . | 111 |
| — Satisampajannakatha . . . . | *Brah Balat SONG-SIV* . . . | 118 |
| — Pannasajataka vol. 4 (suite.) . | *M. CHHIM-SOUM* . . . . | 129 |


### PARTIE LITTERAIRE:


| | | |
|---|---|---|
| — La coutume des femmes tibétaines . . . . . . . . . . | *Mme SRIN-SARIS-YANN* . | 141 |
| — Subhasitarajaniti (Poème) . . | *Oknha NEOU* . . . . . . . | 147 |
| — Conte "Le Diamant du Raja" (suite) . . . . . . . . . . | *M. SIN-HEAN* . . . . . | 153 |
| — Histoire de SAMKOK (suite). . | *Oknha NOU-KAN*. . . . . | 159 |
| — Le souffle du désert (suite) . | *M. PHENG-CHRIV* . . . | 167 |
| — Les trente deux récits du TRONE (suite) . . . . . . . | *M. RAY BUC*. . . . . . . | 182 |


### NOTES ET CHRONIQUES:


| | | |
|---|---|---|
| — Décès du Chef de l'Ordre Dhammayuttikanikay . . . . | *M. BOU-PO* . . . . . . . | 188 |


Prix d'abonnement annuel (comprenant 12 numéros) 230$00

# សេចក្តីថ្វាយសព្ទសាធុការពរ

សៀវភៅនេះឧទ្ទិសថ្វាយដោយគោរពចំពោះព្រះរាជពិធីរាជាភិសេក

នៅឱកាសដ៏ប្រកបដោយសិរីសួស្តីជ័យមង្គលមហាប្រសើរក្នុង ព្រះរាជពិធីព្រះរាជាភិសេក និងព្រះរាជពិធីតាំងតុបចម្រើនព្រះជន្មវស្សា ពីថ្ងៃទី ២ ដល់ទី ៨ មីនា ១៩៥៦ នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រិយានី ទ្រង់បានឡើងសោយរាជសម្បត្តិ ក្នុងព្រះរាជអាណាចក្រកម្ពុជា ដែលជាព្រះរាជពិធីមានលក្ខណៈពិសេសម្យ៉ាង គឺសម្តេចព្រះមហាក្សត្រិយានី បានទ្រង់ទទួលព្រះរាជាភិសេកដែរ ដើម្បីជានិមិត្តរូបដ៏ខ្ពង់ខ្ពស់បំផុតនៃស្ត្រីខ្មែរ ដែលក្នុងពង្សាវតារតាំងពីបុរាណកាលមក ពុំធ្លាប់មានព្រះក្សត្រិយានីព្រះអង្គណាមួយ បានឡើងគង់លើព្រះរាជបល្ល័ង្ក ជាមួយនឹងព្រះរាជភស្តា ដូចជាសម្តេចព្រះមហាក្សត្រិយានីព្រះអង្គនេះឡើយ ហើយដែលជាសុភមង្គលយ៉ាងក្រៃលែង បង្ហាញឱ្យឃើញជាច្បាស់ថារជ្ជកាលនេះ ជារជ្ជកាលប្រសើរបំផុត ក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ,

ពុទ្ធសាសនបណ្ឌិត្យ សូមថ្វាយចំពោះល្អងធូលីព្រះបាទទាំងពីរព្រះអង្គ នូវពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ សូមទ្រង់គង់នៅជាបរមសុខក្នុងសិរីរាជសម្បត្តិ ដើម្បីថែរក្សាប្រទេសជាតិឱ្យបានសុខចម្រើនអស់កាលជាអង្វែងតទៅ ។

ពុទ្ធសាសនបណ្ឌិត្យ

## ផ្នែកសាសនា

# ការបួសក្នុងពុទ្ធសាសនា

ស្រី-អ៊ូ ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ
រៀបរៀង

---

ការបួស ជាករណីយកិច្ច ប្រចាំជីវិតរបស់ពុទ្ធសាសនិកជនជាតិខ្មែរ ជាប់មកយូរកាលណាស់ហើយ ព្រោះការបួស ជាការផ្លាស់ចិត្តគំនិត ដែលធ្លាប់កាយមាយ សាវ័ណ្ឌ ប្របូកប្របល់នៅក្នុងរឿងលោក ឲ្យមកតាំងនៅក្នុងអាការស្ងប់ស្ងៀម ។

ការបួស បើបួសជាសាមណេរ ហៅថា បព្វជ្ជា បើបួសជាភិក្ខុ ហៅថា ឧបសម្បទា ។ ប្រពៃណីខ្មែរ កាលកុលបុត្តមានអាយុ ២០ ឆ្នាំ បរិបូណ៌ ដែលជាអាយុនៅក្នុងវយៈកាលជាអ្នកមានចិត្តធ្ងន់ធ្ង អាចអត់ធន់ ចំពោះសេចក្តីស្រេកឃ្លានបាន ក៏ត្រៀមខ្លួនទីងបួស ប្រុងប្រៀបគ្រឿង អដ្ឋបរិក្ខារគឺចីពរ, ស្បង់, សង្ឃាដី, បាត្រ, កាំបិត, ម្ជុល, វត្តពន្ធ ចង្កេះ, តម្រងទឹក; ត្រៀមអដ្ឋបរិក្ខារទាំង ៨ យ៉ាងនេះ ទុកឲ្យគ្រប់គ្រាន់ មុនបួសប្រមាណជា ១៥ ថ្ងៃ ឬ ១ ខែ ។

អ្នកគ្រប់គ្រងគឺមាតាបិតាជាដើម ត្រូវនាំកូនទៅដែលបម្រុងនឹងបួស ទៅផ្ញើទុកឲ្យនៅនឹងលោកគ្រូចៅអធិការ ដើម្បីរៀនហាត់វិធីបួសក្នុងកាលដ៏សមគួរ ។ បព្វជាបេក្ខ ឬ ឧបសម្បទាបេក្ខដែលទៅនៅរៀនហាត់

វិធីបួសនេះ ហៅថា នាគ កាលបើបានជានាគហើយ អ្នកគ្រប់គ្រង ឬអ្នកទំនុកបម្រុង ត្រូវហាមឃាត់នាគនោះ កុំឲ្យដើរលេងផ្តេសផ្តាស ក្រែងមានរឿងហេតុកើតឡើង បណ្តាលឲ្យនាគនោះខានបួស ។

ពាក្យថា នាគ ប្រែថា "អ្នកប្រសើរ, អ្នកមិនធ្វើបាប" បានសេចក្តីថា អ្នកបម្រុងនឹងបួស ជាមនុស្សប្រសើរ ជាមនុស្សមិនធ្វើអំពើបាប ។

ការបួសជាភិក្ខុ ត្រូវបួសក្នុងរោងឧបោសថ ព្រោះរោងឧបោសថនៅក្នុងដែនសីមា ។ ការបួសជាសង្ឃកម្មមួយ ត្រូវធ្វើក្នុងដែនសីមា ។

ពាក្យថា សីមា សំដៅយកខេត្តសម្រាប់កំណត់ឲ្យជាទីធ្វើការរបស់សង្ឃ, វត្តខ្លះមានសីមានៅជុំវិញរោងឧបោសថ វត្តខ្លះមានសីមានៅប្របកំពែងវត្តជុំវិញ; ដំណើរទាំងនេះដើម្បីឲ្យដឹងថា ខេត្តរបស់សង្ឃមាននៅត្រឹមណេះត្រឹមណោះ; ការធ្វើសង្ឃកម្មដូចការបួសជាដើម ត្រូវធ្វើក្នុងសីមាជាការចាំបាច់ ។

ការបួសសម្រេចនៅលើសង្ឃ, បើវត្តក្រខ្សត់លោកសង្ឃ ត្រូវមានជុំនុំសង្ឃយ៉ាងតិចត្រឹម៥រូប, បើវត្តសម្បូរលោកសង្ឃ ត្រូវមានជុំនុំសង្ឃយ៉ាងតិចត្រឹម ១០ រូប ហើយត្រូវមានព្រះថេរៈ ១ រូបជាព្រះឧបជ្ឈាយ៍ គឺជាប្រធានក្នុងការបំបួសកុលបុត្ត ទាំងជាអ្នកត្រួតត្រាមើលទោសតូចធំរបស់អ្នកបួស ហើយសង្ឃត្រូវសន្មតភិក្ខុ ១ រូប ឬ ២ រូប ឲ្យជាអ្នកសាកសួរអន្តរាយិកធម៌របស់អ្នកបួស ក្នុងកណ្តាលជុំនុំសង្ឃថា "អ្នកមាន

រោគឃ្លង់ ប៉ូស ស្រែង ហឺត ឆ្កួតជ្រូក ជាដើមដែរឬទេ” កាលបើសួររួចស្រេចហើយ ត្រូវសូត្រញត្តិ ក្នុងលំដាប់តទៅ; លុះចប់ញត្តិហើយ ទើបព្រះឧបជ្ឈាយ៍ប្រាប់អនុសាសនវិធី គឺប្រៀនប្រដៅអ្នកបួសថ្មីឲ្យដឹងនូវកិច្ចខាងដើម គឺមុនដំបូងត្រូវដឹងនិស្ស័យគ្រឿងអាស្រ័យរបស់បព្វជិត, និស្ស័យនោះមាន ៤ យ៉ាង :

១— ត្រាច់ទៅបិណ្ឌបាត

២— ស្លៀកដណ្ដប់សំពត់បង្សុកូល

៣— នៅជិតគល់ឈើ

៤— ឆាន់ថ្នាំដែលត្រាំដោយទឹកនោមគោ [១] ។

និស្ស័យទាំង ៤ នេះ ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាត ក្នុងសម័យដែលស្រុកទេសមិនសម្បូរដោយគ្រឿងប្រើប្រាស់ កំពុងក្រីក្រដុនដាប, សម័យឥឡូវនេះ ស្រុកទេសបានចំរើនរុងរឿងសម្បូរដោយលាភសក្ការៈ ភាពនៃភិក្ខុក៏ប្រែប្រួលប្រព្រឹត្តទៅតាមសេចក្ដីចំរើនរបស់ស្រុកទេសដែរ ។ ត្រង់បទថា ឲ្យភិក្ខុស្វែងរកសំពត់បង្សុកូលដោយទីកន្លែងដែលគេចោល លើគំនរអាចម៍ដី ឬតាមទីប៉ាឆា មកធ្វើជាសំពត់សម្រាប់ស្លៀកដណ្ដប់,

---

១ ប្រែចេញពីបទថា បូតិមុត្តៈ ដែលប្រែតាមរូបសព្ទថាទឹកនោមស្អុយ, ពាក្យនេះមិនទាន់ដាក់ជាទឹកនោមគោទេ, អ្នកខ្លះយល់ថាទឹកនោមមនុស្ស ម្ល៉ោះហើយក៏នោមដាក់ដើម្បីត្រាំផ្លែស្រម៉ខ្លុតព្រៃជាដើម ធ្វើជាថ្នាំកែរោគ, តាមពិតសរីរៈមនុស្សក្នុងវិន័យបញ្ញត្តិតឹងរឹងណាស់ថា ភិក្ខុឆាន់ចង្ក្រាន់ឬទឹក សូម្បីលាយដោយពោម ឬសាច់មនុស្សក៏ត្រូវអាបត្តិ ។ ចំពោះបទបូតិមុត្តៈនេះ ក្នុងគម្ពីរបរមត្ថទីបនីអដ្ឋកថាខុទ្ទកនិកាយ មានកែពន្យល់ថា យំ កិញ្ចិ គោមុត្តំ ប្រែថាទឹកនោមគោណាមួយ ។

សម័យនេះ សំពត់មានសាច់ល្អៗ ក៏ច្រើន ទាំងទាយកអ្នកមានសទ្ធាជ្រះថ្លាក៏មានច្រើនដែរ ទើបអនុញ្ញាតឲ្យភិក្ខុប្រើប្រាស់សំពត់មានសាច់ល្អៗបាន ។ ត្រង់បទថា ឲ្យភិក្ខុនៅជិតគល់ឈើ ឥឡូវនេះ វត្តអារាមមានច្រើនកុះករ ទើបអនុញ្ញាតឲ្យភិក្ខុនៅតាមវត្តបាន ។ ត្រង់បទថា ឲ្យឆាន់ថ្នាំដែលត្រាំដោយទឹកនោមគោសម្រាប់កែរោគផ្សេងៗ សម័យនេះមានមន្ទីរពេទ្យជាច្រើន សម្បូរដោយថ្នាំពេទ្យហើយ ទើបអនុញ្ញាតឲ្យភិក្ខុឆាន់ថ្នាំតាមវិធីពេទ្យបាន ។

លំដាប់តទៅ ព្រះឧបជ្ឈាយ៍គប្បីប្រាប់អករណីយកិច្ច គឺកិច្ចដែលអ្នកបួសមិនត្រូវធ្វើ, អករណីយកិច្ចនោះមាន ៤ យ៉ាង :

១— មិនត្រូវសេពមេថុន

២— មិនត្រូវលួចលាក់របស់គេ

៣— មិនត្រូវសម្លាប់សត្វ

៤—មិនត្រូវពោលអួតគុណវិសេសដែលមិនមានក្នុងខ្លួន។

កាលព្រះឧបជ្ឈាយ៍ បានប្រាប់និស្ស័យ ៤ និងអករណីយកិច្ច ៤ ដូចពោលមកដោយសង្ខេបនេះ ឈ្មោះថា បប់អនុសាសនវិធីត្រឹមប៉ុណ្ណេះ ។ អ្នកបួសថ្មីក៏បានតម្រង់ភាពជាភិក្ខុក្នុងព្រះពុទ្ធសាសនា, អ្នកបួសថ្មីនោះមាននាមថា ភិក្ខុ ព្រោះជាអ្នកសូម គឺជាអ្នកទទួលទេយ្យទានអំពីទាយក, មាននាមថា បព្វជិត ព្រោះជាអ្នកវៀរចាកអំពើមានទោស

គ្រប់យ៉ាង, មាននាមថា សមណ: ព្រោះជាអ្នកស្ងប់ស្ងាត់ គឺជាអ្នករម្ងាប់សេចក្ដីអាក្រក់ ។

អ្នកដែលបានបួសហើយនេះ ឈ្មោះថាជាអ្នកជួយតម្រង់គាំពារព្រះពុទ្ធសាសនាឲ្យបានត្រង់ ឲ្យបានចំរើនរុងរឿងជាស្ថាពរ ដរាបមកដល់សម័យបច្ចុប្បន្ននេះឯង ។

## ប្រយោជន៍អដ្ឋបរិក្ខារ

បរិក្ខារ គ្រឿងប្រដាប់សម្រាប់ប្រើប្រាស់ របស់អ្នកបួសមាន ៨ យ៉ាង ដូចបានពណ៌នាមកហើយក្នុងខាងដើម, ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតគ្រឿងបរិក្ខារទាំង ៨ នេះ ដល់អ្នកបួស ដើម្បីនឹងប្រើប្រាស់ រក្សាចិញ្ចឹមរាងកាយ នឹងរក្សាចិញ្ចឹមផ្ទៃឲ្យបានស្រួលល្អ ។ លោកអ្នកបួសថ្មីអង្គខ្លះ ក្នុងសម័យនេះប្រហែលជាពុំទាន់យល់ប្រយោជន៍ នៃបរិក្ខារទាំង ៨ នេះដោយច្បាស់លាស់ទេ ហេតុនេះ ខ្ញុំសូមអធិប្បាយអំពីប្រយោជន៍នៃបរិក្ខារទាំង ៨ នេះ ឲ្យឃើញច្បាស់លាស់ឡើង តាមគោលបំណងនៃព្រះបរមគ្រូដែលទ្រង់អនុញ្ញាតទុកមក ។

បណ្ដាបរិក្ខារទាំង ៨, បរិក្ខារមួយ ៗ មានប្រយោជន៍ពីរ ៗ ដូចសេចក្ដីអធិប្បាយតទៅនេះ ៖

បាត្រ, ស្បង់, សង្ឃាដី មានប្រយោជន៍ ២ យ៉ាងគឺ កាយបរិហារិយ ការរក្សារាងកាយ ឬ ការចិញ្ចឹមរាងកាយ ១ កុច្ឆិបរិហារិយ ការរក្សាផ្ទៃ ឬ ការចិញ្ចឹមផ្ទៃ ១ ។

កាលភិក្ខុស្លៀកដណ្តប់ស្បង់ចីវរ ចេញដើរទៅក្នុងបន្ទោះស្រុក, តែចីវរនោះ ហៅថា កាយបរិហារ្យ គ្រឿងរក្សាចិញ្ចឹមរាងកាយ ។

កាលភិក្ខុដើរទៅក្នុងបន្ទោះស្រុក ជួនជាស្រេកទឹក ហើយយកជាយចីវរត្រងទឹកឆាន់ ឬក៏យកចីវរវេចផ្លែឈើតូចធំមានផ្លែស្វាយ និងផ្លែល្ហុងជាដើម ក្នុងកាលដែលទាយកគេប្រគេនមក, តែចីវរនោះ ហៅថា កុច្ឆិបរិហារ្យ គ្រឿងរក្សាចិញ្ចឹមផ្ទៃ ។

បាត្រ, កាលភិក្ខុយកបាត្រដងទឹកស្រង់ ឬយកបាត្រដងទឹកស្រោចស្រោះព្រំកុដិជាដើម, បាត្រនោះ ហៅថា កាយបរិហារ្យ គ្រឿងរក្សាចិញ្ចឹមរាងកាយ ។

កាលភិក្ខុយកបាត្រទទួលអាហារភោជន ដែលទាយកប្រគេនមក ដើម្បីឆាន់, បាត្រនោះ ហៅថា កុច្ឆិបរិហារ្យ គ្រឿងរក្សាចិញ្ចឹមផ្ទៃ ។

កាំបិត, កាលភិក្ខុយកកាំបិតមកកាប់កាត់ ចិតសំរួច ធ្វើឈើស្ទន់សម្រាប់ចាក់ធ្មេញ ឬធ្វើជើងគ្រែ ជើងតាំង ជើងមុង និងកាត់ហែកចីវរជាដើម, កាំបិតនោះ ហៅថា កាយបរិហារ្យ ជាគ្រឿងរក្សាចិញ្ចឹមរាងកាយ ។

កាលភិក្ខុយកកាំបិតឈូសសកអំពៅពុះផ្លែដូង ចិតផ្លែស្វាយ ដើម្បីឆាន់ជាដើម, កាំបិតនោះ ហៅថា កុច្ឆិបរិហារ្យ ជាគ្រឿងរក្សាចិញ្ចឹមផ្ទៃ ។

ម្ជុល, កាលភិក្ខុយកម្ជុលដេរប៉ះស្បង់ចីពរសង្ឃាដី ឬដោះបន្លាដែលមុតដៃជើង, ម្ជុលនោះ ហៅថា កាយបរិហារ្យ គ្រឿងរក្សាចិញ្ចឹមពងកាយ ។

កាលភិក្ខុយកម្ជុលចាក់ដោតនំចំណី មាននំផ្អែមជាដើម ឬចាក់ផ្លែឈើ ដើម្បីឆាន់, ម្ជុលនោះ ហៅថា កុច្ឆិបរិហារ្យ គ្រឿងរក្សាចិញ្ចឹមផ្ទៃ ។

វត្ថពន្ធបង្កេះ, កាលភិក្ខុយកវត្ថពន្ធ មកក្រវាត់ឲ្យមាំ ហើយចេញដើរទៅក្នុងចន្លោះស្រុក, វត្ថពន្ធនោះ ហៅថា កាយបរិហារ្យ គ្រឿងរក្សាចិញ្ចឹមពងកាយ ។

កាលភិក្ខុចេញដើរទៅក្នុងចន្លោះស្រុក ហើយមានគេយកគេប្រគេនអំពៅច្រើនដើម គ្មានខ្សែរល្វើអ្វីទងចង ក៏យកវត្ថពន្ធមកចងអំពៅជាបាច់នាំមកដើម្បីឆាន់, វត្ថពន្ធនោះ ហៅថា កុច្ឆិបរិហារ្យ គ្រឿងរក្សាចិញ្ចឹមផ្ទៃ ។

ធមក្រក (តម្រងទឹក), កាលភិក្ខុយកធមក្រកដងទឹកស្រង់ ឬដងទឹកស្រោចប្រោះព្រំទីសេនាសនៈទីធ្លាទីលានក្បែរបរិវេណកុដិ ដើម្បីកុំឲ្យធូលីហុយឡើងជាដើម, ធមក្រកនោះ ហៅថា កាយបរិហារ្យ គ្រឿងរក្សាចិញ្ចឹមពងកាយ ។

កាលភិក្ខុយកធមក្រកដងទឹកឆាន់ ឬយកធមក្រកទទួលដាក់អង្ករ

អំបុកជាដើម សម្រាប់ទុកឆាន់, ធមក្រកនោះហៅថា កុដិបរិហារ្យ គ្រឿងក្រោបញ្ចឹមផ្ទៃ ។

បរិក្ខារទាំង ៨ យ៉ាងរបស់អ្នកបួស មានប្រយោជន៍ពីរៗ ដូចសេចក្ដីអធិប្បាយមកដោយសង្ខេបត្រឹមប៉ុណ្ណោះ ។

សូមនិគមបរិក្ខារទាំង ៨ ចងជាគាថា ដើម្បីឲ្យងាយចាំដូចខាងក្រោមនេះ ៖

តិចីវរញ្ច បត្តោ ច វាសី សូចិ ច ពន្ធនំ
បរិស្សាវនេន អដ្ឋេតេ យុត្តយោគស្ស ភិក្ខុនោ

(ប្រែ) បរិក្ខារទាំង ៨ នេះរបស់ភិក្ខុ អ្នកប្រកបព្យាយាម គឺត្រៃចីវរ, បាត្រ, កាំបិត, ម្ជុល, វត្ថពន្ធបង្កេះ, ធមក្រក ។

---

## មិនបញ្ចេញឫទ្ធិ គេមើលងាយ

៣១ — សូម្បីសក្កទេវរាជ បើមិនបញ្ចេញឫទ្ធិយសសក្តិឲ្យគេឃើញច្បាស់ទេ ក៏តែងបាននូវការមើលងាយពីមហាជន; បុគ្គលហ៊ានដើរកន្លងនូវស្ថានដែលមានភ្លើងនៅខាងក្នុង, តែកាលណាភ្លើងឆេះហើយ បុគ្គលមិនហ៊ានកន្លងឡើយ ។

## មិនសាកសួរ មិនបាននូវការរាប់រក

៣២ — មន្ត្រីណាចរចាជាមួយព្រះរាជាហើយមិនហ៊ានទូលសួរ មន្ត្រីនោះឈ្មោះថាមនុស្សល្ងង់ខ្លៅ មិនតែប៉ុណ្ណោះទេ មន្ត្រីនោះតែងបាននូវការមិនរាប់រក ព្រមទាំងបាននូវការមើលងាយពីព្រះរាជាថែមទៀតផង ។

បញ្ចតន្ត្រ:

# ការចំរើន និង ការសាបសូន្យធម្មវិន័យ
# ក្នុងព្រះពុទ្ធសាសនា

ព្រះទេពសត្ថា កិម - ទិវ បន្ធុមង្គលោ

រៀបរៀង

---

ការចំរើននិងការសាបសូន្យនៃធម្មវិន័យក្នុងពុទ្ធសាសនា អាស្រ័យហេតុដូចមានសេចក្ដីអធិប្បាយតទៅនេះ ៖

ធម្មជាត ៣ យ៉ាងជាពន្លឺដែលអាចបំភ្លឺសត្វលោកឲ្យភ្លឺជាក់ច្បាស់ក្នុងលោកទៅបាន អាស្រ័យដោយមិនមានគ្រឿងមន្ទិលសៅហ្មង ចូលមកបិទបាំង ; ឯធម្មជាត ៣ យ៉ាងនោះគឺ :

១ — សុរិយមណ្ឌលំ មណ្ឌលព្រះអាទិត្យ

២ — ចន្ទមណ្ឌលំ មណ្ឌលព្រះចន្ទ ។

ព្រះអាទិត្យនិងព្រះចន្ទទាំងពីរនេះ រមែងរះឡើងភ្លឺរុងរឿងបានតែតាមវេលា, គឺព្រះអាទិត្យរះឡើងភ្លឺរុងរឿងបានតែក្នុងវេលាថ្ងៃ ដល់វេលាយប់នឹងគតវិញ, ព្រះចន្ទរះឡើងភ្លឺរុងរឿងបានតែក្នុងវេលាយប់ ដល់វេលាថ្ងៃនឹងគតវិញ; ព្រះអាទិត្យនិងព្រះចន្ទដែលអាចរះឡើងភ្លឺរុងរឿងបានតាមវេលានោះសោតទៀត ព្រោះតែគ្មានសភាវៈអ្វីដទៃចូលមកបៀតបៀនជ្រៀតជ្រែកបិទបាំង ប្រសិនបើមានខ្យល់ព្យុះភ្លៀងផ្គររមេឃស្រទំបុះអ័ព្ទ

បែកផ្សែងបន្សុរភ្លៀងធ្លាក់ចុះមកក្នុងវេលាណា រស្មីព្រះអាទិត្យនិងព្រះចន្ទនោះឯង ក៏វិនាសបាត់ទៅទាំងអស់ អាចញុំាងលោកទាំងមូលឲ្យងងឹតសូន្យឈឹងទៅមួយរំពេចក្នុងវេលានោះពុំខាន ។

៣— តថាគតប្បវេទិតំ ពុទ្ធវចនំ ពុទ្ធវចនៈ គឺធម៌និងវិន័យដែលព្រះតថាគតបានត្រាស់ដឹងហើយទ្រង់សំដែងទុកមក, ពុទ្ធវចនៈនោះជាពន្លឺមួយរបស់សត្វលោក ៗ អាចយកពន្លឺគឺធម៌និងវិន័យនោះមកបញ្ចាំងចុះបំភ្លឺមើលហេតុពិតនិងមិនពិត, មើលអំពើល្អនិងអាក្រក់, ចុះពិនិត្យរកគុណនិងទោស, ខុសនិងត្រូវ គ្រប់យ៉ាង ឲ្យឃើញជាក់ច្បាស់ ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក ហើយអាចញុំាងចិត្តឲ្យងាកបែរចេញពីសេចក្ដីយល់ខុសក្នុងហេតុដែលមិនពិត និងអំពើអាក្រក់ប្រកបដោយទោសនោះបោលចេញបាន ព្រមទាំងបានប្រតិបត្តិប្រព្រឹត្តកាន់យកតែហេតុដែលពិត និងអំពើដែលល្អប្រកបដោយគុណ ដើម្បីជាប្រយោជន៍ក្នុងលោកនេះនិងលោកខាងមុខ ។ ពុទ្ធបរិស័ទដែលមានបញ្ញាចក្ខុយ៉ាងនេះ អាស្រ័យដោយពន្លឺគឺធម៌និងវិន័យនេះឯង ។

ឯធម៌និងវិន័យ ដែលនឹងអាចប្រតិស្ឋានតាំងទៅ បានសេចក្ដីរុងរឿងអស់កាលជាយូរអង្វែងទៅបាន លុះតែអាស្រ័យដោយពួកពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថជាអធិបតីក្នុងសង្គមនីមួយ ៗ មិនព្រងើយកន្តើយបានប្រឹងជួយឧបត្ថម្ភទំនុកបំរុងផង ទាំងកុលបុត្រអ្នករៀនសូត្រក៏មានគុះការចេះដឹងជាច្រើន ហើយខំព្យាយាមបង្ហាត់បង្រៀនសិស្សានុសិស្ស ៗ

គ្នាផង ទំព្យា យាមរំលឹកដាស់តឿនណែនាំអ្នកដទៃឲ្យមានសេចក្ដីប្រព្រឹត្ត ប្រតិបត្តិត្រឹមត្រូវផង ទើបធម៌និងវិន័យរបស់ព្រះសម្មាសម្ពុទ្ធនោះនឹងរុងរឿងឋិតថេរចិរកាលទៅបាន ។

មួយទៀត បុគ្គលជាធម្មកថិកក្ដី មិនមែនជាធម្មកថិកក្ដី មានសេចក្ដីយល់ខុស ប្រកបដោយមានះចចេសរឹងត្អឹង ហាមឃាត់សាសនារបស់ព្រះពុទ្ធ ឬជាអ្នកកំណាញ់ធម៌លាក់លៀមចំណេះវិជ្ជា មិនចង់ឲ្យអ្នកណាមួយគេចេះដឹងលើសខ្លួនឬស្មើនឹងខ្លួន ខ្វះបខាតលាភសក្ការៈរបស់ខ្លួនក្ដី ជាអធម្មវាទី ពោលនូវហេតុដែលមិនមែនជាធម៌ មិនមែនជាវិន័យថាជាធម៌ ថាជាវិន័យទៅវិញដូច្នេះក្ដី បុគ្គលបែបនេះបានឈ្មោះថាជាអ្នកបិទបាំងពន្លឺនៃធម៌និងវិន័យរបស់ព្រះសម្មាសម្ពុទ្ធ ឲ្យស្រអាប់បាត់ពន្លឺរស្មី ជាអ្នកដឹកនាំមនុស្សទាំងពួងឲ្យវង្វេងក្នុងគំនិតសំគាល់ខុសជាត្រូវ សំគាល់ត្រូវថាជាខុសវិញដោយច្រើន ដូចគ្នានឹងព្រះអាទិត្យព្រះចន្ទរះឡើងកំពុងមានរស្មីភ្លឺត្រចះល្អ បើមានសភាវៈដទៃ មានរាហូអសុរិន្ទជាដើម ចូលមកបៀតបៀនជ្រៀតជ្រែកបិទបាំងព្រះអាទិត្យនឹងព្រះចន្ទកាលណាហើយ ពន្លឺរស្មីដែលកំពុងរុងរឿងល្អនោះ ក៏ប្រែទៅជាស្រអាប់បាត់ពន្លឺវិនាសសូន្យទៅមួយរំពេចក្នុងកាលនោះឯង, ឯធម៌និងវិន័យរបស់ព្រះសម្មាសម្ពុទ្ធ ក៏ដូច្នោះដែរ ។ រួមសេចក្ដីដែលបានពណ៌នាមកថា ធម៌និងវិន័យដែលបានចំរើនរុងរឿងឡើង ឬវិនាសសាប

សូឡ្យទៅ ក៏ដោយសារតែពួកពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថអ៊ីង ឯង ៗ

មានពាក្យចោទសួរថា ពុទ្ធសាសនាគឺធម៌និងវិន័យ ដែលអាចរុងរឿងតាំងនៅអស់កាលជាអង្វែងទៅបាន អាស្រ័យដោយសារ បរិយត្តិ (ការរៀនសូត្រ) ជាឫសគល់ ឬក៏អាស្រ័យដោយសារ បដិបត្តិ (ការប្រតិបត្តិ) ជាឫសគល់? បញ្ហានេះ សូមទាញយករឿងដែលមានក្នុងគម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ មកឆ្លើយបញ្ជាក់ថា មានភិក្ខុពីរពួកគឺភិក្ខុខាងបរិយត្តិមួយពួក, ភិក្ខុខាងប្រតិបត្តិកាន់ធុតង្គមួយពួក ៗ មានបញ្ហាកើតឡើងដល់ភិក្ខុទាំងនោះថា បរិយត្តិ ជាឫសគល់នៃសាសនា ឬក៏ បដិបត្តិ ជាឫសគល់នៃសាសនា? ពួកភិក្ខុខាងប្រតិបត្តិកាន់ធុតង្គឆ្លើយឡើងថា បដិបត្តិ ជាឫសគល់នៃសាសនា ៗ ឯពួកភិក្ខុខាងបរិយត្តិឆ្លើយថា បរិយត្តិ ជាឫសគល់នៃសាសនា ៗ ខណៈនោះព្រះថេរៈទាំងឡាយដែលគង់នៅជាកណ្ដាលប្រកាសឡើងថា យើងមិនទាន់យល់ព្រមតាមពាក្យរបស់លោកទាំងសងខាងទេ សូមលោកទាំងឡាយលើកយកសូត្រជាភាសិតនៃព្រះជិនស្រីមកពោលអាងផង ទើបបាន ៗ លំដាប់នោះ ពួកភិក្ខុខាងបដិបត្តិកាន់ធុតង្គលើកយកសូត្រពីរអន្លើមកពោលអាងថា ឥមេ ច សុភទ្ទ ភិក្ខូ សម្មាបដិបត្តី វិហរេយ្យុំ អសុញ្ញោ លោកោ អរហន្តេហិ អស្ស "ម្នាលសុភទ្ទ,

ប្រសិនបើភិក្ខុទាំងឡាយនេះ មានការប្រតិបត្តិដោយប្រពៃជាប្រក្រតី, លោក(នេះ)មិនគប្បីសូន្យចាកព្រះអរហន្តទាំងឡាយឡើយ" ។ បដិបត្តិមូលកំ មហារាជ សត្ថុ សាសនំ បដិបត្តិយំ ធរន្តេ តិដ្ឋតិ "បពិត្រមហារាជ, សាសនារបស់ព្រះសាស្តាមានសេចក្តីប្រតិបត្តិជាឫសគល់ ឋិតនៅក្នុងបុគ្គលអ្នកទ្រទ្រង់សេចក្តីប្រតិបត្តិ" ។ ឯពួកភិក្ខុខាងបរិយត្តិ ក៏នាំយកសូត្រដូចខាងក្រោមនេះមកពោលអាងថា :

យាវ តិដ្ឋន្តិ សុត្តន្តា វិនយោ យាវ ទិប្បតិ
តាវ ទក្ខន្តិ អាលោកំ សុរិយេ អព្ភុដ្ឋិតេ យថា ។
សុត្តន្តេសុ អសន្តេសុ បមុដ្ឋេ វិនយម្ហិ ច
តមោ ភវិស្សតិ លោកស្ស សុរិយេ អត្ថង្គតេ យថា ។
សុត្តន្តេ រក្ខិតេ សន្តេ បដិបត្តិ ហោតិ រក្ខិតា
បដិបត្តិយំ ឋិតោ ធីរោ យោគក្ខេមា ន ធំសតីតិ ។

"ព្រះសូត្រទាំងឡាយឋិតនៅដរាបណា, ព្រះវិន័យនៅរុងរឿងដរាបណា, សត្វលោកក៏អាចនៅឃើញពន្លឺបានដរាបនោះ ដូចជាព្រះអាទិត្យដែលរះខ្ពស់ត្រដែតឡើង ដូច្នោះឯង ។ កាលបើព្រះសូត្រទាំងឡាយមិនមាន ទាំងព្រះវិន័យក៏ភិក្ខុភ្លេចភ្លាំងអស់ទៅហើយដែរ, ងងឹតអ័ព្ទអន្ធការក៏នឹងកើតមានដល់សត្វលោក ដូចជាព្រះអាទិត្យដែលអស្តង្គតបាត់ពន្លឺ ដូច្នោះឯង ។ កាលបើភិក្ខុនៅរក្សាព្រះសូត្របាននៅឡើយ,

សេចក្ដីប្រតិបត្តិ ក៏ឈ្មោះថាជាគុណជាតិ ដែលភិក្ខុនៅរក្សាបានដែរ; ធីរជនអ្នកឋិតនៅក្នុងសេចក្ដីប្រតិបត្តិ រមែងមិនខ្វាត់ឃ្លាតចាកធម៌ជាដែនក្សេមចាកយោគៈឡើយ ” ។

កាលពួកភិក្ខុខាងបរិយត្តិ នាំយកព្រះសូត្រមកសំដែងសាងដូច្នេះហើយ, ពួកភិក្ខុខាងប្រតិបត្តិកាន់ធុតង្គ ក៏យល់ស្របជាមួយគ្នាហើយនៅស្ងៀម ។ សេចក្ដីនេះ អដ្ឋកថាចារ្យបានអធិប្បាយបន្ថែមដោយសេចក្ដីប្រៀបធៀបបំភ្លឺថា ហ្វូងគោ ដែលមានសុទ្ធតែគោបាទាំងរយទាំងពាន់ កាលបើមិនមានមេគោជាសត្វរក្សាតំណបវេណីនៅក្នុងហ្វូងគោបានោះផងទេ វង្សប្រវេណីឬពូជគោនោះឯង ក៏មុខជានឹងដាច់សូន្យទៅយ៉ាងណាមិញ; សាសនាក៏ដូច្នោះដែរ, ទោះបីមានភិក្ខុច្រើនរូបដល់រយពាន់ក៏ដោយ បើសុទ្ធតែជាអ្នកប្រារព្ធវិបស្សនាកម្មដ្ឋាន ធុតង្គរុក្ខមូលនៅតាមស្រ័យក្នុងព្រៃ, តែបើមិនមានភិក្ខុអ្នកទ្រទ្រង់បរិយត្តិជាពូជទេ ឬ ក៏បរិយត្តិអន្តរធានទៅដោយហេតុណាមួយហើយ, ការចាក់ធ្លុះ ឬការត្រាស់ដឹងនូវអរិយមគ្គអរិយផល ក៏ពុំមានដែរ ព្រោះមិនមានបរិយត្តិជាច្បាប់សម្រាប់ចង្អុលបង្ហាញពន្យល់បំភ្លឺផ្លូវប្រតិបត្តិឲ្យត្រឹមត្រូវទៅបាន ។ ន័យមួយទៀត លោកប្រៀបថា អក្សរដែលគេឆ្លាក់ភ្ជាប់នៅលើផ្ទាំងថ្ម ដើម្បីជាគ្រឿងសំគាល់ឲ្យដឹងនូវទីដែលមានផ្ទាំងកំណប់ទ្រព្យដែលគេកប់ទុក, ដរាបណា អក្សរទាំងនោះ នៅមិនទាន់រលុបរលាយបាត់ទៅទេ; ដរាបនោះ ផ្ទាំងកំណប់ទ្រព្យនោះ ឈ្មោះថាមិនទាន់វិនាសបាត់ទៅ

នៅឡើយ យ៉ាងណាមិញ; ឯសាសនានេះ ក៏យ៉ាងនោះឯង, បើបរិយត្តិនៅមាន ភិក្ខុទ្រទ្រង់សិក្សារៀនសូត្រនៅឡើយ ឬមិនទាន់អន្តរធានដោយហេតុណាមួយទេ សាសនារបស់ព្រះសម្មាសម្ពុទ្ធក៏មិនទាន់អន្តរធានសាបសូន្យទៅដែរ ព្រោះអាស្រ័យបរិយត្តិជាប្រមាណ គឺបរិយត្តិជាឫសគល់របស់សាសនាដូចបានពណ៌នាមកនេះឯង ។

## បំណោទ ៨ យ៉ាង

បំណោទនេះអ្នកប្រាជ្ញតែងឡើងក្នុងរជ្ជកាលនៃព្រះបាទសម្តេចនរោត្តម ដែលនគរយើងធ្លាក់ទៅជាអាណាព្យាបាលនៃបរទេស ។

| | | |
|---|---|---|
| ១– | បាក់ទឹកដូង | អំផ្លូងមួយពាន់ |
| ២– | កាប់ឈើឈ្នាន់ | អន្ទាន់អន្លូង |
| ៣– | កាប់របង | រំលងសីមា |
| ៤– | កន្ទុយត្រីប្រា | មេនាងនក |
| ៥– | កន្ទុយត្រីផ្ទក់ | មេនាងកែវ |
| ៦– | អកកំបោរ | ប្រចាំជង់ |
| ៧– | បំពង់ឫស្សី | ប្រចាំវែក |
| ៨– | ក្បាលទំពែក | ក្អែកជុះដាក់ប៉ក់ ។ |

## ស្រាយបំណោទទាំង ៨

ទី ១– ម៉ាស៊ីនទឹក, ទី ២– តំបាញ, ទី ៣– ខ្សែលួស, ទី ៤– រាស្ត្រយកគ្នាលែងរើសពូជ, ទី ៥– រាស្ត្រយកប្រពន្ធជាតិស្តេច, ទី ៦– ស្តេចឲ្យមាសគ្រាន់តែចាំវាំង, ទី ៧– នាម៉ឺនគ្រាន់តែផ្តួសប្រយោជន៍ឲ្យគេ, ទី ៨– អ្នកស្នេហាជាតិ តែឡើក ជាប់គុក និរទេស សម្លាប់ចោល ។

យូរ-អ៊ិន

# សតិសម្បជញ្ញកថា

ព្រះបាឡាត់ឧត្តមលិខិត ស៊ុង-ស៊ីវ វត្តលង្កា ភ្នំពេញ

រៀបរៀង

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការ ចំពោះព្រះភគវន្តម្ចាស់អរហំ សម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះសង្ឃដោយគោរព) ។

វេលានេះ អាត្មាភាពសូមសំដែងនូវធម៌ដែលមានឧបការៈច្រើនពីរយ៉ាង គឺ សតិនិងសម្បជញ្ញៈ ។

ក៏ធម៌ទាំងពីរប្រការនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងយ៉ាងល្អិតសុខុមពន់ពេក, បុគ្គលដែលជាប់ជំពាក់ទាក់ទងខ្វាំងក្នុងកាម ពុំងាយនឹងប្រតិបត្តិឲ្យពេញបរិបូណ៌បានទេ; តែក្នុងវេលានេះទោះបីធម៌នេះល្អិតសុខុមដូច្នោះ ក៏សូមសំដែងដែរ ដើម្បីជាធម្មស្សវនាការ ចំពោះពុទ្ធបរិស័ទទាំងឡាយដូចតទៅនេះ ៖

សូមផ្តើមអធិប្បាយអំពីលក្ខណៈបុគ្គលអ្នកមានសតិសម្បជញ្ញៈជាមុន ។

ឯលក្ខណៈបុគ្គលអ្នកមានសតិសម្បជញ្ញៈ គឺបុគ្គលដែលប្រកបដោយសតិសម្បជញ្ញៈ កាលនឹងឈានទៅមុខ ឬឈានថយក្រោយ ក៏មានស្មារតីដឹងខ្លួនថា "ឥឡូវនេះអាត្មាអញកំពុងឈានទៅមុខ, កំពុងឈានថយក្រោយ" ។ កាលឱនកាយទៅមុខក្តី ផ្ងារកាយមកក្រោយក្តី

ក្រឡេកមើលទៅមុខក្តី ទៅក្រោយក្តី ទៅឆ្វេងក្តី ទៅស្តាំក្តីក៏មានស្មារតីដឹងខ្លួនថា "ឥឡូវនេះ អាត្មាអញកំពុងនូនកាយទៅមុខ, កំពុងផ្ងារកាយមកក្រោយ" ដូច្នេះជាដើម ។ សូម្បីកាលដែលទឹងប្រើប្រាស់គ្រឿងបរិក្ខារទៀតក៏មានស្មារតីដឹងខ្លួនជានិច្ច ដូចគ្រឿងបរិក្ខាររបស់បព្វជិត កាលដែលទឹងប្រើប្រាស់ សង្ឃាដិ ឬបាត្រ, ចីវរ ក៏មានស្មារតីដឹងខ្លួនថា "ឥឡូវនេះ អាត្មាអញកំពុងប្រើ សង្ឃាដិ, បាត្រ, ចីវរ" ។ កាលដែលទឹងឆាន់បង្អែម ឬឆាន់ទឹក ទឹងទំពា ឬស្រូប, ហិត, លិទ្ធ, ភក្សរបស់អ្វីៗ ក៏មានស្មារតីដឹងខ្លួនថា "ឥឡូវនេះ អាត្មាអញកំពុងឆាន់បង្អែម, ឆាន់ទឹក, ទំពា, ស្រូប, ហិត, លិទ្ធ, ភក្សរបស់នោះៗ" ។ កាលដែលទឹងបន្ទោបង់ឧច្ចារៈ, បស្សាវៈ ក៏មានស្មារតីដឹងខ្លួនថា: "ឥឡូវនេះ អាត្មាអញកំពុងបន្ទោបង់ឧច្ចារៈ, បស្សាវៈ" ។ កាលដេក, ដើរ, ឈរ, អង្គុយ, និយាយ, ស្តាប់ ក៏មានស្មារតីដឹងខ្លួនថា: "ឥឡូវនេះ អាត្មាអញកំពុងដេក, ដើរ, ឈរ, អង្គុយ, និយាយ, ស្តាប់" ។

ភិក្ខុឃើញភ័យក្នុងវដ្តសង្សារ រមែងប្រកបដោយសតិសម្បជញ្ញៈ ដូចសំដែងមកនេះ ។

## អធិប្បាយអំពីសតិ

សតិ ជាធម៌សំខាន់បំផុត ខាងឯធ្វើចិត្តឲ្យបរិសុទ្ធហ្មត់ចត់ល្អ, ព្រោះសម្តេចទ្រង់សំដែងថា ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ

វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ

ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវជាទីទៅតែម្នាក់ឯង ដើម្បីសេចក្តីបរិសុទ្ធិរបស់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកស្រណោះអាឡោះអាល័យ និងសេចក្តីខ្សឹកខ្សួលទាំងឡាយ ដើម្បីរំលត់នូវទុក្ខនិងទោមនស្សទាំងឡាយ ដើម្បីត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង, ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ យទិទំ ចត្តារោ សតិបដ្ឋានា ផ្លូវនោះគឺ សតិបដ្ឋាន ៤ ។ សតិបដ្ឋាន ៤ នោះគឺ:

១– កាយានុបស្សនាសតិបដ្ឋាន ដម្កល់សតិពិចារណាកាយជាអារម្មណ៍ ;

២– វេទនានុបស្សនាសតិបដ្ឋាន ដម្កល់សតិពិចារណាចិត្តជាអារម្មណ៍ ;

៣– ចិត្តានុបស្សនាសតិបដ្ឋាន ដម្កល់សតិពិចារណាចិត្តជាអារម្មណ៍ ;

៤– ធម្មានុបស្សនាសតិបដ្ឋាន ដម្កល់សតិពិចារណាធម៌ជាអារម្មណ៍ ។

ឯវិធីដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រដៅឲ្យពិចារណានោះ មានន័យច្រើនជាអនេក, បើស្រង់យកតែចំណែកដែលដូចគ្នាទាំង ៤ នោះមកសំដែង គឺគឺពិចារណាឲ្យឃើញថា: "កាយនេះគ្រាន់តែជាកាយ, វេទនា

ត្រាន់តែជាវេទនា, ជាបុគ្គល, ជាតួខ្លួនទេ; គួរកុំប្រកាន់, កុំស្អប់, កុំស្រឡាញ់ឡើយ" ដូច្នេះជាដើម ។

កាលបើកំពុងតាំងសតិកំណត់អារម្មណ៍ទាំង ៤ ប្រការ ដូចសំដែងមកនេះ, ចិត្តក៏នឹងជាប់នៅតែក្នុងកុសលធម៌ម្យ៉ាង; បើចិត្តជាប់នៅក្នុងកុសលធម៌ហើយ ឧបក្កិលេសដែលជាអកុសលក៏រកឱកាសកើតឡើងពុំបាន, ចិត្តក៏នឹងប្រាសចាកគ្រឿងសៅហ្មងតែងតែដល់នូវសេចក្ដីជ្រះថ្លាជាខណៈ ៗ ដោយលំដាប់ទៅ ។

នេះជាសេចក្ដីអធិប្បាយដោយសង្ខេបក្នុងពាក្យថាសតិ ។

## អធិប្បាយអំពីសម្បជញ្ញៈ

សម្បជញ្ញៈ នោះចែកជា ៤ ប្រការគឺ:

១– សាត្ថកសម្បជញ្ញៈ ដឹងឋានៈមានប្រយោជន៍,

២– សប្បាយសម្បជញ្ញៈ ដឹងឋានៈជាទីសប្បាយ,

៣– គោចរសម្បជញ្ញៈ ដឹងឋានៈជាទីគោចរ,

៤– អសម្មោហសម្បជញ្ញៈ ដឹងឋានៈមានសេចក្ដីមិនវង្វេង ។

## សាត្ថកសម្បជញ្ញៈ= ដឹងឋានៈមានប្រយោជន៍

ភិក្ខុក្នុងសាសនានេះ កាលបើគិតថានឹងទៅប្រទេសណា ក៏ពុំបានទៅដោយប្រញាប់ប្រញាល់តាមអំណាចចិត្តដែលគិតនោះទេ, តែងពិចារណាឲ្យដឹងថា ដែលអាត្មាអញទៅក្នុងទីនោះ តើនឹងមានប្រយោជន៍ឬទេ? បើឃើញថាមានប្រយោជន៍ គឺនឹងបានឃើញព្រះចេតិយ, ឃើញ

ពោធិព្រឹក្ស, ឃើញព្រះសង្ឃ, ឃើញមហាថេរ, ឃើញអស្សុកដែលមានទំនងឲ្យកើតត្រៃលក្ខណ៍; លុះពិចារណាឃើញយ៉ាងនេះហើយទើបទៅ ។ បើពិចារណាទៅហើយឃើញថាមិនមានប្រយោជន៍ ក៏កាត់គមិកចិត្តនោះចេញ, ពុំបានទៅកាន់ទីដែលប្រាសចាកប្រយោជន៍នោះឡើយ ។ ឯការដែលបានឃើញព្រះចេតិយ, ឃើញពោធិព្រឹក្ស, ឃើញព្រះសង្ឃ, ឃើញមហាថេរ, ឃើញអស្សុភៈនោះឯង តែងជាបច្ច័យឲ្យចំរើននូវសីលគុណ, សមាធិគុណ, បញ្ញាគុណ ។ បើបុគ្គលដែលមានឧបនិស្ស័យ បានសាងសន្សំមកពីបុព្វជាតិច្រើន, កាលបើបានឃើញវត្ថុដ៏ប្រសើរទាំងនោះ ក៏កើតបីតិប្រាមោទ្យ មានពុទ្ធគុណ, ធម្មគុណ, សង្ឃគុណជាអារម្មណ៍, លុះពិចារណា បីតិប្រាមោទ្យនោះដោយខយវយៈ គឺកិរិយាអស់ទៅនឹងសូន្យទៅ:ហើយ, ក៏ច្រើនតែបានសម្រេចអរិយមគ្គអរិយផលដោយលំដាប់ ៗ ទៅ ។ បើបុគ្គលដែលពុំធ្លាប់បានសាងសន្សំឧបនិស្ស័យធម៌ពីបុព្វជាតិមកទេ ក៏នឹងបានជាឧបនិស្ស័យទៅជាតិខាងមុខ ៗ ដែរ ។ ហេតុដូច្នេះ បានជាភិក្ខុដែលមានប្រាជ្ញា នឹងត្រេចទៅស្វែងរកប្រយោជន៍, មានថ្វាយបង្គំនូវព្រះចេតិយ ឬ ពោធិព្រឹក្សជាដើមនេះ ឈ្មោះថាសាត្ថកសម្បជញ្ញៈ ។

## សប្បាយសម្បជញ្ញៈ = ដឹងឋានៈជាទីសប្បាយ

អធិប្បាយថា ភិក្ខុអ្នកប្រកបដោយសម្បជញ្ញៈ រមែងពិចារណាគេដំណើរជាទីសប្បាយនឹងមិនសប្បាយជាមុនថា វេលាដែលអាត្មាអញទៅក្នុងទីនោះ ៗ តើនឹងបានអារម្មណ៍ជាទីសប្បាយឬទេ? បើឃើញថានឹង

យកអារម្មណ៍ឲ្យជាទីសប្បាយមិនបាន ក៏នឹងឈប់បង្អង់ ; លុះបានពេលដែលកើតអារម្មណ៍ជាទីសប្បាយទើបទៅ; យ៉ាងនេះជាដើម ឈ្មោះថាសប្បាយសម្បជញ្ញៈ ។

ដូចម្ដេចដែលហៅថាដំណើរប្រកបដោយប្រយោជន៍ឲ្យកើតសេចក្ដីសប្បាយ? ដំណើរដែលទៅមើលព្រះចេតិយឬពោធិព្រឹក្សជាដើម ហៅជាដំណើរប្រកបដោយប្រយោជន៍ឲ្យកើតសេចក្ដីសប្បាយ ។ ប៉ុន្ដែបើទីនោះមានបរិស័ទច្រើនទៅប្រជុំគ្នាដើម្បីធ្វើមហាបូជា, អស់មហាជនទាំងបុរសស្ត្រី ក៏ស្ទុះតែតាក់តែងកាយដោយគ្រឿងប្រដាប់យ៉ាងល្អល្អះ ដើរច្រាត់ទៅមក ។ ចិត្តរបស់ភិក្ខុដែលទៅកន្លែងទីមានសភាពដូច្នោះ រមែងជាប់ជំពាក់ក្នុងឥដ្ឋារម្មណ៍, មានថ្នាំងថ្នាក់ក្នុងអនិដ្ឋារម្មណ៍, រមែងកើតសេចក្ដីអន្ដរាយដល់ជីវិតព្រហ្មចរិយៈពុំខាន ។ ទីដែលមានសភាពដូច្នោះ ឈ្មោះថាជាទីមិនសប្បាយ, លុះតែទីដែលមិនមានសភាពដូច្នោះ ទើបឈ្មោះថាជាទីសប្បាយ ។

## គោចរសម្បជញ្ញៈ = ដឹងឋានៈជាទីគោចរ

អធិប្បាយថា បណ្ដាកម្មដ្ឋានទាំង ៤០ លើកយកអាកាសកសិណ និងអាលោកកសិណចេញ នៅ ៣៨, ក៏កម្មដ្ឋានទាំង ៣៨ នោះ កាលភិក្ខុបានរៀនកម្មដ្ឋានណាមួយដែលមានអារម្មណ៍ជាទីគាប់ចិត្ត គឺសមគួរតាមចរិតហើយក៏កាន់យកកម្មដ្ឋាននោះជាអារម្មណ៍ គ្រប់វេលាដែលគោចរទៅកាន់ទីផ្សេងៗ, ពុំបានឲ្យចិត្តប្រាសចាកកម្មដ្ឋានឡើយ ។ ដំណើរដែលត្រូវទៅយ៉ាងនេះ ហៅថា គោចរសម្បជញ្ញៈ ។

ដើម្បីនឹងសំដែងឲ្យជាក់ច្បាស់នូវគោចរសម្បជញ្ញៈនោះ ពុទ្ធបរិស័ទគួរជ្រាបតាមន័យដែលលោកចែកជា ៤ យ៉ាងដូច្នេះ គឺៈ

១– ឯកច្ចោ ហរតិ ន បច្ចាហរតិ យោគាវចរជំពូកខ្លះ កាន់យកពុទ្ធានុស្សតិកម្មដ្ឋានជាអារម្មណ៍ បានតែពេលដែលត្រេចទៅ ត្រឡប់មកវិញមិនបាន ។

២– ឯកច្ចោ បច្ចាហរតិ ន ហរតិ យោគាវចរជំពូកខ្លះ បានតែក្នុងពេលដែលត្រឡប់មក, ពេលដែលត្រេចទៅមិនបាន ។

៣– ឯកច្ចោ នេវ ហរតិ ន បច្ចាហរតិ យោគាវចរជំពូកខ្លះ មិនបានទាំងទៅ ទាំងមក ។

៤– ឯកច្ចោ ហរតិ ច បច្ចាហរតិ ច យោគាវចរជំពូកខ្លះ បានទាំងទៅ ទាំងមក ។

កាលបើយោគាវចរកាន់យកពុទ្ធានុស្សតិកម្មដ្ឋាន ជាទីសប្បាយហើយ គប្បីធ្វើនូវបត់វេលាដែលគោចរទៅកាន់ទីផ្សេងៗ នុះឯង ហៅថាគោចរសម្បជញ្ញៈ ។

អសម្មោហសម្បជញ្ញៈ = ដឹងហ៊ានៈមានសេចក្ដីមិនវង្វេង

អធិប្បាយថាៈ សេចក្ដីមិនវង្វេងក្នុងឥរិយាបថទាំងឡាយ មានឈានទៅមុខថយមកក្រោយជាដើម ហៅថាអសម្មោហសម្បជញ្ញៈ ។ បណ្ឌិតគួរជ្រាបសេចក្ដីនោះយ៉ាងនេះថា ធម្មតាពួកហ៊ីនជនរមែងវង្វេងឥរិយាបថទាំងឡាយមានឈានទៅមុខជាដើម គឺគ្រាន់តែដឹងថា អាត្មា

ឈានទៅមុខ ដំហានមុខអាត្មាអញបានឈានទៅហើយ ដូច្នេះប៉ុណ្ណោះ ពុំបានជំនឿវិសេសជាងនេះទៅទៀតឡើយ ។ ឯបណ្ឌិតជនក្នុងព្រះពុទ្ធ-សាសនានេះ មិនវង្វេងដូច្នោះឡើយ គឺកាលបើមានចិត្តគិតថា អាត្មាអញនឹងឈានទៅមុខដូច្នេះហើយ រមែងនឹកឃើញថា: "ឱ! ឥឡូវនេះ វាយោធាតុ ញុំាងវិញ្ញត្តិឲ្យកើតឡើង គឺឲ្យល់កំរើកហើយតើ!" ដូច្នេះ ជាមួយនឹងចិត្តដែលគិតថា "អញឈានទៅមុខ" នោះឯង, ហើយគិតទៅទៀតថា "ឱ! ឥឡូវនេះ ពង្អឹងដែលលោកសន្មត់ថា កាយនេះ កំពុងឈានទៅមុខដោយអំណាចកំរើកវាយោធាតុនឹងកិរិយាចិត្តហើយ" ។ គិតយ៉ាងនេះ គ្រប់ឥរិយាបថនឹងធាតុទាំង ៤ ។ តាមសេចក្តីក្នុងបរមត្ថថា ការដើរជារបស់ពួកធាតុ ការឈរក៏ជារបស់ពួកធាតុទាំងអស់ ។ ចិត្តដែលប្រព្រឹត្តទៅជាមួយនឹងរូបក្នុងចំណែកនោះៗ ជាប់គ្នាដូចខ្សែទឹក ។

សេចក្តីនេះ សមដូចពុទ្ធភាសិតថា:

អញ្ញំ ឧប្បជ្ជតេ ចិត្តំ អញ្ញំ ចិត្តំ និរុជ្ឈតិ
អវិចិមនុសម្ពន្ធោ នទីសោតោវ វត្តតិ ។

"ចិត្តដទៃកើតឡើង ចិត្តដទៃរលត់ទៅ ប្រហែលគ្នានឹងខ្សែទឹកនទី ដែលប្រព្រឹត្តជាប់ទៅតាមរលក" ។

សេចក្តីមិនវង្វេងក្នុងឥរិយាបថទាំងឡាយមានឈានទៅមុខជាដើម ដូចអធិប្បាយមកហើយនេះ ឈ្មោះថា អសម្មោហសម្បជញ្ញៈ ។

បុគ្គលដែលប្រកបដោយសម្បជញ្ញៈដូច្នេះ ចិត្តរមែងជ្រះថ្លា មិនមានឱកាសឲ្យឧបក្កិលេសរុករានចូលមកបាន ។

កាលបើបុគ្គលណាមិនមានសតិសម្បជញ្ញៈនេះហើយ បុគ្គលនោះតែងតែសាត់អណ្តែតក្តាត់ធ្លាក់ទៅក្នុងគំនរអកុសលធម៌ផ្សេងៗ ក្លាយខ្លួនទៅជាបុគ្គលអាក្រក់, ជាបុគ្គលមានកំឡាំងខ្សោយ; សូម្បីតែលាភសក្ការៈក៏អាចសម្លាប់បុគ្គលនោះបាន; ដូចពុទ្ធភាសិតមួយកន្លែងមាននៅក្នុងគម្ពីរសំយុត្តនិកាយថា:

ផលំ វេ កទលឹ ហន្តិ ផលំ វេឡុំ ផលំ នឡំ
សក្ការោ កាបុរិសំ ហន្តិ គព្ភោ អស្សតរឹ យថា ។

ផ្លែចេក តែងសម្លាប់ដើមចេក, ផ្លែឫស្សី តែងសម្លាប់ដើមឫស្សី, ផ្លែបបុស តែងសម្លាប់ដើមបបុស, ឯសក្ការៈ តែងសម្លាប់បុរសអាក្រក់ ដូចជាគភ៌សម្លាប់មេសេះអស្សតរ ។

ន័យមួយទៀតថា: ជីវិតមតកោ (ស្លាប់ទាំងរស់) អាមកបូតិកោ (ស្អុយទាំងស្រស់), បានដល់បុគ្គលដែលមិនមានសតិសម្បជញ្ញៈនេះឯង ។

ធម្មតាបុគ្គលមិនមានសតិសម្បជញ្ញៈ រមែងមានសេចក្តីប្រមាទជានិច្ច, កាលបើមានសេចក្តីប្រមាទដូច្នេះហើយ សូម្បីមានជីវិតរស់នៅក៏ឈ្មោះថាស្លាប់, ព្រោះស្លាប់សតិសម្បជញ្ញៈ; បានជាភាសិតនេះថា ជីវិតមតកោ គឺស្លាប់ទាំងរស់; បុគ្គលបែបនេះតែងតែប្រព្រឹត្តអំពើទុច្ចរិតផ្សេងៗ, បើប្រព្រឹត្តអំពើទុច្ចរិតដូច្នេះហើយ គេក្តីឈ្មោះបុគ្គលនោះក៏អាក្រក់ ស្អុយផ្សាយទៅកាន់ទីប្រាសខ្យល់ ទីដំបណ្តាយខ្យល់ជានិច្ច, ឯ

គ្រោងកាយរបស់បុគ្គលនោះនៅស្រស់ទេ តែមានកេរ្តិ៍ឈ្មោះស្អុយព្រោះ អំពើទុច្ចរិត, បានជាភាសិតនេះថា: អាមកបូតិកោ គឺស្អុយទាំងស្រស់ ៗ

សតិនិងសម្បជញ្ញៈទាំងពីរនេះ បើកើតឡើងព្រមគ្នាក្នុងវេលាមួយ, ក៏រឹតតែទ្វេកម្លាំងច្រើនឡើង អាចកំចាត់សត្រូវគឺកិលេសដែលជាមេធំ គឺរាគៈ, ទោសៈ, មោហៈឲ្យអស់ទៅបាន; បើកិលេសទាំងនេះអស់ទៅ ហើយ ចិត្តក៏រមែងបរិសុទ្ធស្អាតផូរផង់ ទុកជាពុំទាន់ដាច់អស់ជាសមុច្ឆេទ-ប្បហាន ក៏គង់ជាតទង្គប្បហាន; កាលបើជាតទង្គប្បហានរឿយៗ ក៏អាចនឹងក្លាយជាសមុច្ឆេទប្បហានទៅបាន ៗ

ចិត្តនៃបុគ្គលដែលបានដុសខាត់រឿយៗ រមែងស្អាតផូរផង់ដោយលំដាប់តាមទំនងនៃកុសលធម៌ ដែលជាគ្រឿងដុសខាត់នោះៗ, ដូចព្រាហ្មណ៍ម្នាក់ដែលធ្វើការកុសលបន្តិចម្តងៗ ជាលំដាប់ ដរាបដល់បានសម្រេចមគ្គផល ៗ សូមនាំរឿងនោះមកសំដែង ជាឧទាហរណ៍ដូចតទៅនេះ ៗ រឿងនោះមានសំដែងនៅក្នុងគម្ពីរខុទ្ទកនិកាយថា:

មានព្រាហ្មណ៍ម្នាក់បានធ្វើបុណ្យជាលំដាប់ ៗ តាំងពីតិច ៗ ដរាបដល់បានសម្រេចមគ្គផលជាទីបំផុត ៗ មុនដំបូងបានឃើញទីដែលភិក្ខុ ១ រូបឈរឃ្លុំចីពរ, ទីនោះមិនស្អាតប្រឡាក់ដោយកក់ទឹកស្មៅ; ក៏ធ្វើឲ្យស្អាតឡើងបានជញ្ជូនដីខ្សាច់យកមកពោយពាយ រួចធ្វើបាំបាំងកំដៅថ្ងៃ, ខាងក្រោយបំផុតបានសាងសាលា ១ ត្រង់ទីនោះ ៗ វេលាឆ្លងសាលានោះបាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធានមកថ្វាយភត្ត, ហើយក៏ក្រាបបង្គំទូលប្រវត្តិហេតុនៃការសាងសាលានោះតាំងពីខាងដើមជាលំដាប់

មក, រួចហើយវេរសាលានោះថ្វាយចំពោះសង្ឃមានព្រះពុទ្ធជាប្រធាន ។ កាលដែលព្រះបរមគ្រូទ្រង់អនុមោទនា ក៏ទ្រង់សំដែងគាថានេះថា :

អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។

" អ្នកមានប្រាជ្ញាគួរកំចាត់មន្ទិលរបស់ខ្លួនក្នុងខណៈ ។ បន្តិចម្ដង ៗ ដោយលំដាប់ទៅ, ដូចជាងមាសដែលជម្រះស្នឹមនៃមាសប្រាក់ដូច្នោះ" ។

ហេតុនេះ សប្បុរសទាំងឡាយគួរប្រតិបត្តិតាមពុទ្ធនីតិនេះគ្រប់ ៗ ប្រាណ ។

ពាក្យដែលទូន្មានឲ្យផ្ចិតផ្ចង់របស់ខ្លួន ឲ្យខ្ពូរផង់ជាលំដាប់ ដរាបដល់បានសម្រេចអរហត្តជាទីបំផុត ដូចសំដែងមកនេះ រាប់ថាជាពុទ្ធសាសនាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រះពុទ្ធរាល់ព្រះអង្គដែលបានត្រាស់ក្នុងកាលទាំងពួង តែងតែទ្រង់ប្រដៅដូច្នេះ ។

ធម៌ទេសនាដែលសំដែងមកក្នុងវេលានេះ សន្មត់ថាចប់ដោយសង្ខេបត្រឹមប៉ុណ្ណោះ ។

ដោយតេជះនៃធម្មទេសនានេះ បរិស័ទទាំងឡាយគ្រប់ជាន់ ដែលបានប្រតិបត្តិតាមសាសនវិធី ក្រោមអធិបតេយ្យនៃព្រះសម្មាសម្ពុទ្ធ សូមឲ្យបានប្រកបដោយអនាគុរគាព (សេចក្ដីមិនក្ដៅក្រហាយ), ដើម្បីជាពលរដ្ឋ ប្រកបកិច្ចសាសនា បានមគ្គាភិសម័យសមតាមអធ្យាស្រ័យវត្ថុបំណងកុំបីឃ្លៀងឃ្លាត ឡើយ ។

# បញ្ញាសជាតក

## ភាគទី ៤

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ
នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង
កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## វដ្តង្គុលីរាជជាតក ទី ២០

លោកអាចារ្យ ឈឹម-ណាក ប្រែពីបាលី

(ត-ចប់)

---

ព្រះមហាបុរសបានទ្រង់ព្រះសវនាការពាក្យនោះហើយ ក៏ត្រាស់ថា យើងនឹងធ្វើស្ដេចព្រមទាំងពលទាំងអស់នោះឲ្យរត់ទៅឯងៗ ឥតសម្លាប់ដោយគ្រឿងសស្ត្រាវុធណាមួយឡើយ ។

គ្រានោះ សហជាតអមាត្យទាំងឡាយដែលមានកំណើតថ្ងៃជាមួយនឹងព្រះពោធិសត្វ ក្រាបបង្គំទូលព្រះពោធិសត្វថា បពិត្រព្រះសម្មតិទេព, យើងខ្ញុំសូមប្រាំង, ទូលព្រះបង្គំជាខ្ញុំទាំងអស់ សុទ្ធតែជាអ្នកមានកំលាំងពលំ ជាវីរបុរសក្លៀវក្លាអង់អាចឈ្លាសក្នុងសង្គ្រាម មិនជាអ្នកត្រឡប់រត់ថយក្រោយទេ, អាចញាំញីពួកសេនារបស់ស្ដេចដទៃឲ្យខ្ទេចខ្ទីដូចផង់ធូលីបាន ដូចជាមហាគជេន្ទ្រពារណ៍ មិនមែនដូចដំរីសាមញ្ញឡើយ ខ្ញុំព្រះអង្គទាំងឡាយ សូមទទួលអាសាចាប់ស្ដេចទាំង ១០១ ព្រមទាំងយោធាឲ្យត្រាតែបាន, សូមព្រះរាជទានព្រះរាជានុញ្ញាត ។ ព្រះមហា-

សត្វមានព្រះរាជឱង្ការថា "ណើយ, អ្នកទាំងឡាយកុំច្បាំងឡើយ, តែកើតច្បាំងហើយ មុខជាពួកស្តេច ១០១ ទាំងពួកពលទាំងអស់នុះ ស្លាប់វិនាសអស់មិនខាន សូម្បីតែអមាត្យម្នាក់ដែលរួចខ្លួន រត់នាំដំណឹងពីអ្នកទាំងនោះស្លាប់ ទៅប្រាប់ដល់កូនប្រពន្ធទាំងឡាយឯស្រុក ក៏គ្មានផង, ហេតុដូច្នេះ ចូរអ្នកទាំងអស់គ្នាស្ងួតទឹកបរិភោគបាយព្រឹកហើយ ស្លៀកពាក់តាក់តែងកាយ មកហែខ្ញុំទៅតាមដំណើរប្រក្រតី, ខ្ញុំជិះលើខ្នងដំរី ទៅបង្អើលពួកស្តេច ១០១ ព្រមទាំងពួកពលទាំងអស់ឲ្យរត់ខ្ចាត់ខ្ចាយ ដោយគ្រាន់តែចង្អុលដោយម្រាមដៃ ១ ខ្ញុំមិនសម្លាប់ទេ, ណើយ, អ្នកទាំងឡាយកុំព្រួយបារម្ភណ៍ថ្វី ដល់ថ្ងៃស្អែកសឹមអ្នកទាំងអស់គ្នា មកហែខ្ញុំចេញទៅ" ទ្រង់មានព្រះរាជឱង្ការដូច្នេះហើយ ក៏បញ្ជូនពួកអមាត្យឲ្យទៅកាន់ទីលំនៅរបស់ខ្លួនវិញ ។

លំដាប់នោះ កាលដែលរាត្រីភ្លឺច្បាស់ហើយ ព្រះពោធិសត្វទ្រង់ស្រង់ ទ្រង់សោយព្រះស្ងោយដែលមានឱជារសយ៉ាងឆ្ងាញ់ពិសារ ស្តេចទ្រង់គ្រឿងអលង្ការគ្រប់គ្រឿងស្រេច ស្តេចទៅប្រថាប់នៅនាព្រះរាជ-ណាន ទ្រង់ប្រជុំពួកអមាត្យទាំងអស់ ហើយទ្រង់គង់លើគជេន្ទ្រដែលជារាជពាហណៈ ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង មានខ្សែដង្គន់ខ្សែហាង ស្អិតស្អាងដោយមាស ជាដំរីដែលគេប្រើប្រាស់ដោយកន្ទេរពេជ្រ ដែលគេបង្ហាត់បានបទត្រឹមត្រូវ អាចញាំញីនូវសេនាដំរីក្លៀវក្លារបស់ស្តេចដទៃបាន ទ្រង់មានពួកអមាត្យហែហមចោមរោមជាបរិវារ ដូចជាសក្ក-ទេវរាជ ដែលមានពួកទេវតា ពួកស្រីអប្សរបរិវារកញ្ញា មានរូបយ៉ាងល្អ

បំណាច់ នឹងស្រីជាទេពមហេសីទាំង ៤ ហែហមទៅដូច្នោះ. ព្រះអង្គមាន ពួកពលបរិវារ ដែលមានរូបរាងស្អាត ៗ ជាច្រើន បក់ផាត់បំព្រះដាយ សុវណ្ណវាលវិជនី មានដងវិចិត្រដោយរតនៈផ្សេង ៗ អ្នកខ្លះបើកបាំង ស្វេតឆ័ត្រវិចិត្រដោយកែវទឹកមាសសុវណ្ណ. អ្នកខ្លះកាន់ទង់កាន់ផ្ទាំង សំពត់, អ្នកខ្លះប្រគំដេញដំតូរ្យតន្ត្រី មានប្រការផ្សេង ៗ, អ្នកខ្លះកាន់ ប្រដាប់ប្រដាដទៃ ៗ ផ្សេង ៗ ជាច្រើនប្រការ, ហែព្រះរាជាតាមព្រះ រាជប្រវេណីដូចធម្មតាប្រក្រតី, ព្រះបក្រី ទ្រង់ចេញទៅតាមទ្វារខាងកើត, ទ្រង់ទតឃើញសេនារបស់ស្តេចដទៃហើយ ត្រាស់ព្រះរាជឱង្ការសួរថា ចតុរង្គអង្គសេនាទាំង ៤ ពួក គឺសេនាដំរី សេនាសេះ សេនារថ សេនា ថ្មើរជើង មកឡោមព័ទ្ធជុំវិញខ្វល់ខ្វាញ់ ដ៏ល្អថ្កុំថ្កើងរុងរឿងដូចព្រះអាទិត្យ តម្រៀបគ្នាជាជួរជាប់ប្រកិតតាមក្រោយខ្លួនគ្នា ដូចជារបៀបរលកនៃទឹក ក្នុងសមុទ្រផុតវិស័យនឹងរាប់បាន; សេនាទាហានច្រើនទាំងម៉្លេះនេះ តើ ជាសេនាទាហានរបស់អ្នកណា ? ។ អមាត្យទាំងឡាយបានស្តាប់ព្រះរាជ-ឱង្ការនោះហើយ ក៏ក្រាបបង្គំទូលព្រះពោធិសត្វថា បពិត្រព្រះសម្មតិ-ទេព ស្តេចទាំង ១០១ អង្គក្នុងជម្ពូទ្វីបនេះ មកដើម្បីច្បាំងជាមួយនឹង យើង, សេនាទាហានជាច្រើនមានរបៀបដូចជារលកសាគរមិនដាច់ពី គ្នានេះ ជាសេនាទាហានរបស់ស្តេចទាំងនោះ ។ ព្រះពោធិសត្វ ទ្រង់ ព្រះសណ្តាប់ពាក្យអមាត្យក្រាបបង្គំទូលដូច្នោះហើយ ទើបត្រាស់ព្រះ រាជឱង្ការថា នែព្រះស្តេចទាំងឡាយ ចូរអ្នករាល់គ្នា ទៅប្រាប់ស្តេច ទាំង ១០១ តាមពាក្យខ្ញុំថា បើស្តេចគ្រប់អង្គចង់ច្បាំងជាមួយនឹងខ្ញុំ ចូរ

ឡើងគង់ដំរីឲ្យគ្រប់ៗ អង្គទៅចុះ, មិនតែប៉ុណ្ណោះ ទាំងពួកសេនាដំរី ក៏ត្រូវឡើងជិះដំរី ពួកសេនាសេះ ក៏ត្រូវឡើងជិះសេះ, ពួកសេនារថ ក៏ត្រូវឡើងជិះរថ ពួកអ្នកកាន់ទង់ជ័យកាន់ផ្ទាំងសំពត់ ក៏ត្រូវលើកឡើង តាមបំណាំចុះ, ពួកសេនាថ្មើរជើងទាំងនោះ ក៏ត្រូវប្រុងប្រៀបគ្រឿង ក្រោះ និងកិច្ចការគ្រប់យ៉ាង ដែលត្រូវធ្វើក្នុងសង្គ្រាមឲ្យឆាប់ៗ ភ្លាមៗ ឡើង ។ អមាត្យទាំងឡាយ ទៅថ្វាយដំណឹងដល់ពួកស្តេចទាំង ១០១ តាមព្រះរាជឱង្ការនោះ សព្វគ្រប់ប្រការ ។ ព្រះរាជាគ្រប់ព្រះអង្គ ទ្រង់ព្រះសណ្តាប់ពាក្យអមាត្យទាំងឡាយហើយ ក៏ទះព្រះហត្ថាសើចហៅ កញ្ជ្រៀវខ្សៀវខ្សារ ទ្រហឹងអឹងអាប់ ហាក់ដូចស័ព្ទសន្ធឹកស្រុកទ្រុឌផែន ប្រថពី, ព្រះរាជាទាំងនោះ ព្រមទាំងសេនាបតីនិងពួកទាហានទាំងអស់ សុទ្ធសឹងប្រដាប់ដោយគ្រឿងក្រោះដ៏ល្អស្រស់ថ្លៃថ្លា ហត្ថាកាន់លំពែង កាន់ខែល កាន់អាវុធមានប្រការផ្សេងៗ ឡើងជិះពាហនៈ តាមសមគួរ ដល់ដំណែងរៀងៗខ្លួន ។ កងទ័ពទាំងអស់គឺរីលំពែងស្នែងត្រែ និង ព្រះខាន់ផ្សេងៗ មានពន្លឺភ្លឺផ្លេកពាសពេញទាំងអាកាស ដូចជាលដេរ-ជាសដូចផ្លេកបន្ទោរជាច្រើនកោដិ ពួកដំរី ក៏បញ្ចេញកោញ្ចនាទជញ្ជួច ទ្រហឹង, ពួកសេះក៏កញ្ជ្រៀវខ្សៀវខ្សារ ពួកពលថ្មើរជើង ក៏ស្រែកសន្ធាប់; សំឡេងគឹកកងនៃពួកជនទាំងនោះ ដូចជាសន្ធឹកខ្យល់ប្រល័យកប្ប ។ ស្តេចទាំង ១០១ ឈមមុខសំដៅទៅរកព្រះពោធិសត្វ ដោយការប្រុង ប្រយ័ត្នប្រឹងសង្វាតយកជ័យ ។

លំដាប់នោះ ដោយអានិសង្សនៃការកសាងម្រាមព្រះហស្តព្រះ

ពុទ្ធបដិមា ក៏ព្រះពោធិសត្វ គ្រាន់តែលើកម្រាមព្រះហស្តមួយចង្អុលពួកស្តេចទាំងពួកពលទាំងនោះ ក៏ពួកពលដំរី ធ្លាក់ពីលើដំរី, ពួកពលសេះធ្លាក់ពីលើសេះ, ពួកពលរថ ធ្លាក់ពីលើរថ, ពួកពលថ្មើរជើង ដែលមានគ្រឿងក្រោះសៀតយ៉ាងពិតស្និទ្ធ ក៏រត់ខ្ចាត់ខ្ចាយទៅ, ពួកខ្លះដួលស្រុសជាប់នៅកន្ទួង, ពួកខ្លះរត់ទៅដោយរហ័ស ពួកខ្លះចូលព្រៃព្រឹក្ស, ពួកខ្លះក៏ចូលទៅពួនសម្ងំនៅក្បែរមាត់ព្រែក មាត់ស្ទឹងបឹងទន្លេទឹងមាត់សមុទ្រ, ពួកខ្លះក៏របូតសំពត់រត់ទៅទាំងអាក្រាត ។ ព្រះមហាសត្វឃើញជនទាំងនោះដល់នូវវិបត្តិដូច្នោះ ក៏មានព្រះរាជហឫទ័យករុណាអាសូរ មានព្រះរាជឱង្ការថា នែអ្នកទាំងឡាយ! ចូរអ្នកពល់គ្នាក្រោកឡើង កុំភ័យឡើយ ។ ពួកស្តេចទាំងអស់នោះ ក្រោកឡើងក៏ភ័យខ្លាចស្លាប់ ក៏អង្គុយប្រណម្យអញ្ជលី អង្វរគេរសូមថ្វាយគ្រឿងសក្ការៈនិងរាជសម្បត្តិ ព្រមទាំងរាជធីតារបស់ខ្លួនដល់ព្រះពោធិសត្វ ។ ព្រះបាទវដ្ដង្គលិករាជបរមពោធិសត្វ ក៏បានជាស្តេចឯករាជ្យក្នុងជម្ពូទ្វីប ទ្រង់ឲ្យនាំព្រៀនប្រដៅស្តេចទាំងនោះ ហើយបញ្ជូនទៅកាន់រាជធានីរបស់ខ្លួនទីទៃ ៗ វិញ ។ ព្រះបាទវដ្ដង្គលិករាជ ក៏ទ្រង់ស្តេចចូលទៅកាន់ព្រះរាជបុរីរបស់ព្រះអង្គ ព្រមទាំងបរិវារ ។ លំដាប់ពីនោះមក ពួកស្តេចទាំង ១០១ តែងបញ្ជូនគ្រឿងបណ្ណាការស្ទួយសាអាករ មកថ្វាយព្រះបាទវដ្ដង្គលិករាជនោះរៀងរាល់ឆ្នាំ ។ ព្រះមហាសត្វ តែងទ្រង់ព្រះរាជទានព្រះរាជទ្រព្យគ្រប់មុខរបស់ព្រះអង្គ ឲ្យជាទានដល់សមណព្រាហ្មណ៍កម្សត់ទុគ៌តទីទាល់ក្រ

ទ្រង់សោយរាជ្យប្រកបដោយទសពិធរាជធម៌ទាំង ១០ ប្រការ ឥតមានព្រះរាជហឫទ័យលំអៀងដោយអគតិណាមួយឡើយ ។

សម័យនោះ អាសនៈសក្កទេវរាជ ក៏សំដែងអាការក្តៅគាយៗឡើង ដោយអានុភាពនៃសេចក្តីករុណារបស់ព្រះមហាសត្វ ។ សក្កទេវរាជទ្រង់ អាវជ្ជនាការពិចារណាដោយទិព្វចក្ខុជាបហេតុនោះហើយ ទ្រង់ចុះពីទេវលោកមកភ្លាម ចូលមកកាន់សំណាក់ព្រះមហាសត្វ ទ្រង់ញុំាងទិសឲ្យស្វាងរុងរឿងដូចជាព្រះអាទិត្យកំពុងរះឡើងនាទកាល័យ, បញ្ចេញរស្មីភ្លឺព្រោងព្រាត ហើយទ្រង់ត្រាស់សួរព្រះមហាសត្វថា:

បុច្ឆាមិ តំ មហារាជ កិំ បុញ្ញំ បកតំ តយា
បុព្វេ បិ កេន បុញ្ញេន លទ្ធោ តេ វិជយោ អយំ ។

"បពិត្រមហារាជជាស្តេចធំ, ខ្ញុំសូមសួរព្រះអង្គ, កាលពីដើមព្រះអង្គបានធ្វើបុណ្យដូចម្តេច? ជ័យជំនះ ដែលព្រះអង្គបានឈ្នះដោយឥតមានសេចក្តីខ្វះខ្វែងកងសង្គ្រាមប៉ុន្មាននេះ តើព្រះអង្គបានដោយបុញ្ញកម្មដូចម្តេច?" ។

ព្រះពោធិសត្វទ្រង់ព្រះសវនាការ ស្តាប់ព្រះរាជបុច្ឆារបស់ព្រះឥន្ទ្រាធិរាជនោះហើយ ទ្រង់មានព្រះហឫទ័យត្រេកអរសាទរ ទ្រង់មានជាតិស្សរញ្ញាណរលឹកនឹកឃើញព្រះជាតិរបស់ព្រះអង្គក្នុងកាលមុន ទើបទ្រង់សំដែងនូវបុព្វកម្មរបស់ព្រះអង្គថា:

ពាណិជោហំ បុរេ អាសិ នាមតោ កុលភទ្ទតោ
គច្ឆាមិ តេន សទ្ធឹ សោ ធនេន ទាយំ ឯសតិ
ឆិន្នមេកាង្គុលី ទិស្វា ពុទ្ធរូបស្ស តាវទេ
អហំ តុដ្ឋចិត្តោ អាសិំ ន ឧស្សហាមិ ចេតសា
មទ្ទិត្វា មត្តិកាសុទ្ធំ គុឡិយា អង្គុលី ករេ
តេន បុញ្ញានុភាវេន លទ្ធា មេ វិជយោ អយំ

– "បពិត្រសម្តេចសក្កទេវរាជ, កាលពីមុន ខ្ញុំបានកើតជាឈ្មួញឈ្មោះកុលភទ្ទៈពាណិជ បានទៅស្វែងរកទ្រព្យដោយការជួញប្រែ ជាមួយនឹងពួកឈ្មួញអ្នកមានទ្រព្យផងគ្នា, គ្រានោះ ខ្ញុំបានឃើញម្រាមព្រះហស្ត ១ របស់ព្រះពុទ្ធរូប ១ ព្រះអង្គ ដែលរបេះដាច់បាត់, ខ្ញុំក៏មានចិត្តត្រេកអរ ពុំអាចអត់សង្កត់ទប់ចិត្តបាន ទើបយកដីស្អិតដ៏ល្អ មកច្របាច់លាយដោយប្រេងល្ង តម្រាមព្រះហស្តព្រះពុទ្ធរូបនោះឲ្យបានជាប្រក្រតីឡើងវិញ ដោយអានុភាពនៃបុណ្យដែលបានជួសជុលម្រាមព្រះហស្តព្រះពុទ្ធ-រូបនោះ បានជាដល់មកជាតិនេះ ខ្ញុំមានជ័យជំនះឈ្នះសឹកសត្រូវ ដោយគ្រាន់តែលើកម្រាមដៃចង្អុលទៅយ៉ាងនេះ ម្យ៉ាងវិញទៀត ទោះបីសីហមិគរាជ ដ៏កាចសាហាវក្តី ឬដំរីដ៏ក្លៀវក្លាខ្លាំងពានក្តី ពួកសេនាយោធាព្រមទាំងពាហនៈច្រើនយ៉ាងណាក្តី បើហ៊ានឈមមុខឆ្ពោះត្រង់មករកខ្ញុំ ដោយបំណងចង់បៀតបៀនឲ្យមានសេចក្តីទុក្ខអន្តរាយ, ខ្ញុំគ្រាន់

តែលើកម្រាមដៃ ១ បង្អុលទៅ ក៏អាចការពារទុក្ខភ័យសេចក្តីអន្តរាយនោះបាន, សត្រូវទាំងប៉ុន្មានមានរាជសីហ៍ជាដើមនោះ ក៏នឹងភ្ញាក់ផ្អើលរត់រផាត់រទាំងព្រាត់ព្រាយខ្ចាត់ខ្ចាយអស់ទៅ ឬនឹងដួលដេកក្រាបនៅក្នុងទីនោះក៏សឹងមាន; បពិត្រសម្តេចសហស្សន័យទេវកោសិយ, ដោយតេជះបុណ្យដែលខ្ញុំបានដួសផុលម្រាមព្រះហស្តព្រះពុទ្ធរូបនោះ តទៅខាងអនាគត ខ្ញុំនឹងបានត្រាស់ជាព្រះពុទ្ធ ជាលោកនាយកទៀតពុំខាន" ។ ព្រះអង្គទ្រង់មានព្រះរាជឱង្ការ ចំពោះព្រះឥន្ទ្រាធិរាជដូច្នេះស្រេច ទើបស្តេចទ្រង់ប្រកាសប្រាប់ដល់បណ្តាជនប្រុសស្រីទាំងឡាយថា ម្នាលអ្នកទាំងឡាយដ៏ចំរើន, មិនត្រឹមតែការកសាងព្រះពុទ្ធរូបប៉ុណ្ណោះទេ, ទាំងពុទ្ធបូជា ដែលអ្នកទាំងឡាយមានសទ្ធាជ្រះថ្លាបូជាចំពោះព្រះពុទ្ធហើយ សូម្បីបន្តិចបន្តួចសោះ ក៏គង់មានអានិសង្សច្រើនជាអនេក ៗ

សម្តេចព្រះវជិរបាណីសក្កទេវរាជ ទ្រង់ព្រះសណ្តាប់ព្រះរាជឱង្ការព្រះបាទវដ្តង្គលីរាជនោះហើយ ទ្រង់មានព្រះរាជហឫទ័យប្រកបដោយសេចក្តីជ្រះថ្លាជាសោមនស្ស កាលទ្រង់គង់សំដែងខ្លួនឲ្យព្រះបាទវដ្តង្គលីជ្រាបច្បាស់ ទ្រង់សរសើរដូច្នេះថា:

សក្កោហមស្មិ ទេវិន្ទោ　　អាគតោស្មិ តវ សន្តិកេ
អនាគតេបិ សម្ពុទ្ធោ　　បាបុណិស្សសិ ភូបតិ
និសិន្នោ ពោធិមូលស្មឹ　　មារញ្ចេវ វិធំសនំ
បក្កវាឡបរិយន្តំ　　និក្ខិសំសោ បរាជយិ

កិលេសក្ខន្ធមារញ្ច　　មច្ចុមារំ អសេសតោ
ទ្វត្តឹស នរកេ សុញ្ញេ　　អកាសិ សគ្គំ បូរយិ
ធម្មបាពោបេត្វាន　　អមត្តសគ្គេ ប បាបុណាតិ ។

"បពិត្រមហាបុរស, ខ្ញុំនេះ ជាសក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ បានមកកាន់សំណាក់ព្រះអង្គក្នុងកាលឥឡូវនេះ; បពិត្រព្រះម្ចាស់ផែនដី, ខ្ញុំព្រះអង្គមានសេចក្ដីសង្ឃឹមថា តទៅក្នុងអនាគតកាលខាងមុខ ព្រះអង្គទ្រង់បានគង់នាពោធិព្រឹក្សមណ្ឌល កំចាត់បង់មារាធិរាជព្រមទាំងពលឲ្យបរាជ័យចាញ់គេជាដៃ រត់ខ្ចាត់ខ្ចាយទៅឆ្ងាយដល់កណ្ដាប់ចក្រវាឡ ទ្រង់កំចាត់បង់នូវកិលេសមារ ខន្ធមារ មច្ចុមារ មិនឲ្យមានសេសសល់, ទ្រង់នឹងបានដល់នូវសម្មាសម្ពោធិញាណ បានត្រាស់ជាព្រះពុទ្ធ ទ្រង់ធ្វើនរកទាំង ៣២ ឲ្យសូន្យ ហើយទ្រង់លើកឡើងនូវសត្វនិករ ដាក់ក្នុងសំពៅពោលគឺធម៌ បើកបរសំពៅទៅដឹកល់ទុកក្នុងឋានសួគ៌ និងអម្រឹតមហានិព្វាន ជាប្រាកដពុំខាន" ។

សម្ដេចសក្កទេវរាជ ត្រាស់សរសើរព្រះមហាក្សត្រដូច្នោះហើយ ទ្រង់លាព្រះពោធិសត្វ ធ្វើនិវត្តនាការត្រឡប់ទៅកាន់ទេវលោក ជាទីនិវេសនដ្ឋានរបស់ព្រះអង្គវិញ ក្នុងខណៈនោះឯង ។

អង្គសម្ដេចព្រះបរមសាស្ដាចារ្យជាម្ចាស់ ទ្រង់នាំព្រះធម៌ទេសនានេះមកសំដែងហើយ កាលទ្រង់សំដែងអានិសង្សនៃការកសាងព្រះពុទ្ធបដិមា ចំពោះព្រះរាជបសេនទិកោសល ទ្រង់ត្រាស់ជាបទព្រះគាថាថា:

សត្តក្ខត្តុំ ច ទេវិន្ទោ ទេវរជ្ជមការយិ
អសីតិ ច សត្តក្ខត្តុំ ចក្កវត្តិសិរីវរោ

សេចក្តីក្នុងបទព្រះគាថានោះថា បុគ្គលអ្នកកសាងព្រះពុទ្ធរូបនោះ នឹងបានជាព្រះឥន្ទ្រ សោយទេវសម្បត្តិដល់ ៧ ជាតិ, តាំងបានជាសម្តេចបរមចក្កពត្តិ មានសិរីសម្បត្តិដ៏ប្រសើរដល់ ៨០ ជាតិឬ ១០០ ជាតិ នឹងបានជាស្តេចប្រទេសរាជ ជាច្រើនអសង្ខេយ្យជាតិរាប់ពុំបាន ។ មួយវិញទៀតបុគ្គលឯណា បានធ្វើបដិសង្ខរណកិច្ច ជួសជុលព្រះពុទ្ធរូបដែលមានអវយវៈវិកលវិការដាច់របេះត្រង់កន្លែងណាៗក្តី ដោយត្រឹមតែដីស្អិតម្យ៉ាងប៉ុណ្ណោះ ក៏ផលានិសង្សនៃការជួសជុលព្រះពុទ្ធរូបនោះ ជាអចិន្តេយ្យផលផុតវិស័យ នឹងគិតឲ្យដឹងកំណត់ថាប៉ុណ្ណោះប៉ុណ្ណោះបាន ។ បុគ្គលអ្នកកសាងព្រះពុទ្ធរូបមានសភាពដូច្នោះ ដោយមានបីតិសេចក្តីជ្រះថ្លាហើយ ផលានិសង្សនោះក៏ពេញបរិបូណ៌ អាចនាំបុគ្គលនោះឲ្យទៅឧប្បត្តិចាប់ជាតិកំណើតកើតក្នុងឋានសួគ៌ អស់កាលជាអង្វែងគ្រប់គ្នា ។ បុគ្គលអ្នកកសាងព្រះពុទ្ធរូបដោយដីស្អិតវិចិត្រឲ្យជារបស់ថ្លៃថ្លា ឬគូររក់សរចនាដោយផ្ទាំងសំពត់ ឬផ្ទាំងវត្ថុដែលល្មមធ្វើបានក៏បុគ្គលអ្នកកសាងនោះ ត្រូវមានតេជះច្រើនគ្រប់គ្នា ដូចជាព្រះអាទិត្យ ដែលរះច្បាស់ប្រាសចាកមន្ទិលសៅហ្មងដូច្នោះ, បុគ្គលនោះ កាលមានជាតិជាមនុស្សរស់នៅដរាបដល់អស់ជីវិត រំលាយខន្ធទៅកាន់បរលោកនាយ មិនដែលក្លាយជាតិកំណើតទៅកើតជានរកឬប្រេត មិនកើតក្នុងទុគ្គតិភព

មិនកើតជាតិប្រេតដែលមានពង់កាយធំ ឬ តូចយ៉ាងណាឡើយ ព្រោះ ហេតុដែលបានកសាងកុសលគឺ សាងព្រះពុទ្ធរូបនោះឯង ។ ព្រះពុទ្ធរូបនោះ បុគ្គលឯណាសាងហើយ ទោះបីតូចក្តីធំក្តី តូវជាតំឡូវក្តីផលានិសង្សនោះ ក៏បានសម្រេចស្មើ ៗ គ្នា តាមដោយកម្លាំងសទ្ធាសេចក្តីជ្រះថ្លា; ក្នុងបំណោមជនទាំង ៣ ពួកគឺ អ្នកនាំដើមពោធិព្រឹក្ស ១ ពួក អ្នកប្តេជ្ញាខ្លួនបួលបួសក្នុងព្រះពុទ្ធសាសនា ១ ពួក អ្នកកសាងព្រះពុទ្ធរូប ១ ពួក នោះត្រូវបានផលានិសង្សដូចគ្នា; បើប្រាថ្នាចង់បានត្រាស់ជាព្រះពុទ្ធ, ក៏នឹងបានត្រាស់ជាប្រាកដពុំខាន ។ បុរសបុគ្គលណាមួយ កសាងព្រះពុទ្ធរូប ដោយកុកដំរីក្តី ដោយស្នែងសត្វអ៊ីៗ ក្តី ដោយថ្មសិលាក្តី ដោយឥដ្ឋជាធម្មតាក្តី ទោះបីដួលគេកសាង ឬកសាងផ្ទាល់ខ្លួនឯង, ក៏បុរសបុគ្គលនោះ អន្ទោលជាតិកំណើតទៅកើតក្នុងកាលអនាគត នឹងបានសម្រេចនូវព្រះនិព្វានជាទីបំផុតនៃសេចក្តីទុក្ខ ក្នុងសំណាក់នៃព្រះអរិយមេត្រីយ្យសម្មាសម្ពុទ្ធ ឬបើប្រាថ្នាចង់បានត្រាស់ជាព្រះពុទ្ធផ្ទាល់ខ្លួនឯង, ក៏ប្រាកដជានឹងបានត្រាស់ក្នុងកាលជាខាងក្រោយពុំខាន ។ កាលអង្គសម្តេចព្រះបរមសព្វញ្ញូសាស្តាចារ្យ ទ្រង់ត្រាស់សំដែងធម៌ទេសនាចប់សព្វគ្រប់ហើយ, មនុស្សនឹងទេវតាទាំងឡាយជាច្រើន បានសម្រេចមគ្គផលទីទៃ ៗ ផ្សេងៗ ពីគ្នា តាមសមគួរដល់ឧបនិស្ស័យបច្ច័យវាសនា ខ្លះបានសម្រេចដល់សោតា សកិទាគា អនាគា អរហត្ត ក៏ផាត់បង់នូវកិលេស ឥតមានសេសសល់នៅក្នុងខន្ធសន្តាន ដោយបានស្តាប់ធម៌

ទេសនានេះ ៗ សម្ដេចព្រះបរមសាស្ដាចារ្យជាម្ចាស់ ទ្រង់ត្រាស់សំដែងថ្ងៃជាតកនេះចប់សព្វគ្រប់ហើយ ទ្រង់ប្រជុំជាតកថា ពួកយោធាសេនាទាហានរបស់ព្រះបាទវដ្ដង្គុលីរាជទាំងប៉ុន្មាន បានមកកើតជាពុទ្ធបរិសទ្យទាំងអស់, ព្រះបាទវដ្ដង្គុលីរាជនោះ បានត្រាស់ជាព្រះសម្មាសម្ពុទ្ធ គឺអង្គតថាគតហ្នឹងឯង ៗ

ចប់ វដ្ដង្គុលីរាជជាតក ទី ២០

## ការខ្លាចនៃវត្ថុ ៤ យ៉ាង

១– ទឹកខ្លាចគេដងទុកដំកល់

២ ជាតិដែកៗដែកដុលខ្លាចដំណៅ

៣– ក្រញូងខ្លាចធ្វើខ្ចបក្អួចដូចស្មៅ

៤– ទូកខ្លាចគេទៅជាន់តែមផ្អៀង ៗ

## ធៀបនឹងមនុស្សខ្លាច ៤ ពួក

ទី ១– អ្នកមានបំណេះខ្លាចគេទុកស្ងៀម

ទី ២– អ្នកធ្វើការងារខ្លាចគេប្រើគ្មានថ្ងៃ

ទី ៣– អ្នកជាន់ខ្ពស់ខ្លាចគេប្រើឲ្យធ្វើការទាបថោក

ទី ៤– អ្នកមានរៀនខ្លាចអ្នកដទៃមកជាសំអាង ៗ

សុគន្ធប្រីជាតិន

# ផ្នែកអក្សរសាស្ត្រ

## ទំនៀមទម្លាប់ស្ត្រីនៅស្រុកទីបេ

អ្នកស្រី ពេជ្រ-សល់ ហៅ សារិះយ៉ាន ប្រែចាក

អត្ថបទរបស់លោកអាលេក្សង់ឌ្រិ - ដាវីដ - ណែល

ក្នុងទស្សនាវដ្តីហ្វ្រង់ស-អាស៊ី

---

ពិតមែនតែនៅស្រុកទីបេមានជនជាតិក្រៅចូលទៅនៅច្រឡូកច្រឡំនឹងជនជាតិទីបេជាច្រើន ប៉ុន្តែគេគង់អាចស្រាវជ្រាវរកទំនៀមដើមរបស់ជនជាតិទីបេនេះបាន ដោយអាស្រ័យការសាកសួរអ្នកស្រុកទីបេ ដែលជាអ្នកពុំសូវកាន់របៀបស៊ីវិល្ស ទំនើបថ្មី ៗ

ទោះជាយ៉ាងណាក៏ដោយ ជនជាតិទីបេនេះមិនមានទំនៀមទម្លាប់យង់ឃ្នងដូចនៅស្រុកអាហ្វ្រិកទេ ព្រោះនៅស្រុកអាហ្វ្រិកគេទុកមនុស្សស្រីដូចជាសត្វធាតុ គេប្រើមនុស្សស្រីឲ្យធ្វើការធ្ងន់ ៗ ចំណែកបុរសជាប្តីទៅជានៅទំនេរលេងសប្បាយទៅវិញ ។

ជនជាតិទីបេទុកស្ត្រីភាពជា “មនុស្សទាបថោកបំផុត” ដោយហេតុនេះហើយទើបស្រី ៗ ជាតិទីបេ ប្រាថ្នាឲ្យបានកើតជាភេទបុរសក្នុងជាតិខាងមុខទៀត ព្រោះជនជាតិនេះជឿថាកាលស្លាប់ហើយនឹងកើតវិញ ដូចខ្មែរយើងដែរ ។ ប៉ុន្តែយើងមិនត្រូវចេះតែជឿទៅៗទេ ព្រោះគេបានសង្កេតឃើញស្ត្រីជាតិទីបេតែងកាន់តំណែងមួយយ៉ាងមាំ ក្នុងគ្រួសារក្នុងការទាក់ទងនឹងសង្គម ហើយមានសេរីភាពច្រើនណាស់ ។ ប្រហែល

មកពីស្ត្រីជាតិនេះមានមាឌមាំ ហើយអាចធ្វើការធ្ងន់ៗបាន មិនចាំបាច់ពឹងកំឡាំងបុរសជាជំនួយទេដឹង ទើបបុរសផ្ទេរភារៈធ្ងន់ៗឲ្យទៅស្ត្រីៗ ស្រកស្ត្រីជាតិទីបេអាចស្ពាយត់ក់ន់យ៉ាងធ្ងន់ហើយដើរឆ្ងាយបាន ទោះជាបុរសជាតិអឺរ៉ុបក៏ធន់មិនបានដល់ដែរ, ហើយជាស្ត្រីហ៊ានណាស់ផង ជួនកាលដើរលើភ្នំតែម្នាក់ឯងដល់ទៅពប់ពាន់គីឡូម៉ែត្រក៏មាន ព្រោះស្ត្រីជាតិទីបេមិនញញើតតែនឹងបុរសទេ ។

ពាស់តែនៅស្រុកទីបេមិនមានច្បាប់ទម្លាប់ឲ្យត្រឹមត្រូវសោះ ។ បើមានស្តេច ឬ នាយកណាមួយបង្កើតច្បាប់មួយឡើង អ្នកស្រុកដែលនៅក្នុងអំណាចស្តេចនោះគោរពច្បាប់តែត្រឹមរជ្យស្តេចនោះ ប៉ុន្តែច្បាប់នោះមិនមែនធ្វើសម្រាប់អ្នកនគរទេ ឃើញប្លែកពីនគរយើងនិងប្រទេសឯទៀត ។ អ្នកស្រុកទីបេគោរពតែទំនៀមទម្លាប់របស់ខ្លួន ដែលមានប្លែកៗគ្នាទៅតាមជនបទ តាមវង្សត្រកូល និងតាមឋានៈក្នុងសង្គម ។

ក្នុងលោកទាំងមូល គេស្គាល់ថាន របស់ស្ត្រីជាតិនីមួយៗនៅពេលដែលស្ត្រីនោះមានប្តី ។

នៅទីបេ ពេលរៀបកូនស្រីឲ្យមានប្តី ឪពុកម្តាយខាងស្ត្រីគ្មានត្រូវចែកប្រាក់ជាដើមទុនឲ្យកូនស្រីទេ ។ តែបុរសដែលចង់បានប្រពន្ធ ត្រូវជូន "ថ្លៃទឹកដោះ" ឲ្យទៅឪពុកម្តាយខាងស្ត្រី ដូចជាខ្មែរយើងដែរ ។ "ថ្លៃទឹកដោះ" នេះ ទុកជាថ្លៃបំណាច់ដែលបានចិញ្ចឹមកូនស្រីមកនោះ, ចំណែកខាងពួកអឺរ៉ុបវិញ អ្នកមានកូនស្រីពិបាកនឹងរកធនធានទុកឲ្យកូន

ស្រីនៅពេលមានប្តី ។ តាមទំនងនេះយើងយល់ថា អ្នកអ៊ឺរ៉ុបដែលមានកូនស្រីដូចជាថោកពេកណាស់ ដែលទៅទិញប្តីឲ្យកូនស្រីវិញ ។

នៅទីបេ ទំនៀមខាងប្រុសត្រូវជូន ប្រាក់-មាស-កែវ-កង ច្រើនតិចតាមធនធានទៅឲ្យខាងស្រី ។ ប៉ុន្តែមិនមែនស្ត្រីដែលមានប្តីនោះមកនៅខាងប្តីតែខ្លួនទទេទេ ។ កូនស្រីនៃអ្នកមានធនធាន មានយកទាំងមាស-ពេជ្រ-គោ-ក្របី-សេះ និងដីធ្លីមកជាមួយផង ព្រោះរបស់ទ្រព្យទាំងអស់នេះ ជាកេរ្តិ៍មត៌កខាងស្រី ។ បើកាលណាមានរឿងទាស់ទែងលែងលះគ្នា ក៏នៅតែបានមកខាងស្ត្រីដដែល ។

នៅស្រុកទីបេ របៀបយកប្រពន្ធប្តី មានច្រើនយ៉ាងណាស់ : មានប្តីមួយប្រពន្ធមួយ - ប្តីមួយប្រពន្ធច្រើន - ស្រីមួយមានប្តីច្រើន និងមានសេរីភាពក្នុងការសេពសម្ភត ។ ប៉ុន្តែទោះបីរបៀបទាំងប៉ុន្មានយ៉ាងខាងលើនេះ គេទុកជាល្អទាំងអស់ក៏ដោយ ជនជាតិទីបេភាគច្រើនចូលចិត្តតែមានប្តីមួយប្រពន្ធមួយ ។ ការយកប្រពន្ធច្រើន ៗ តែអ្នកមានភោគទ្រព្យទោះជាយ៉ាងណាក៏មិនដល់ទៅមានផ្ទះចិញ្ចឹមស្រីដែរ ហើយជាតិនេះមិនចេះបង្ខាំងស្រីមិនឲ្យមានសេរីភាពទេ ។ ធម្មតាអ្នកមានសម្បត្តិ ច្រើនតែមានប្រពន្ធត្រឹមពីរប៉ុណ្ណោះ កម្រមានបីណាស់ ហើយសុទ្ធតែរៀបការពេញច្បាប់ផង ។

តាមធម្មតា នៅស្រុកជាច្រើន ខាងបូព៌ាប្រទេស តែកាលណាប្រពន្ធទីមួយគ្មានកូន គេតែងតែយកប្រពន្ធទីពីរទៀត ព្រោះគេខ្លាចគ្មានអ្នកណាតពូជគេ ។ ម្យ៉ាងទៀត ការណ៍ដែលប្រាថ្នាទ្រព្យសម្បត្តិឬប្រាថ្នា

បង់បានបុណ្យស័ក្តិខ្ពង់ខ្ពស់ក្នុងសង្គម ក៏ជាហេតុនាំឲ្យបុរសរកប្រពន្ធទី ២ ឬ ទី ៣ ទៀតក៏មាន បើជាប្រពន្ធទី ១ អន់ពេក ៗ ក្នុងអាពាហ៍ពិពាហ៍, ផងជាតិនេះ មិនមែនថាគ្មានសេចក្តីស្រឡាញ់សោះទេ ប៉ុន្តែគេទុកជាការបន្ទាប់បន្សំ ៗ

ចំណែកឯស្រីជាតិទីបេដែលយកប្តីច្រើនវិញ ផងបរទេសខ្លះយល់ថា គ្រាន់តែកុំឲ្យបែកខ្ញែកមត៌កប៉ុណ្ណោះ ព្រោះគេច្រើនតែយកប្តីក្នុងវង្សត្រកូលមួយៗ របស់គេ គឺថា បើស្ត្រីមាក់ការជាមួយនឹងកូនប្រុសច្បង ក្នុងត្រកូលណាមួយ ស្ត្រីនោះត្រូវទុកខ្លួនជាប្រពន្ធរបស់ប្អូនថ្លៃប្រុសទាំងអស់ ហើយនៅពេលរៀបមង្គលការ គេចុះឈ្មោះប្តី នឹងប្អូនប្រុសក្នុងបញ្ជីទាំងអស់ឬគេគ្រាន់តែយកឈ្មោះអ្នកទាំងអស់នោះមកពប់ប្រាប់ ៗ ក្នុងថ្ងៃពិធីនេះសាមីខ្លួនខាងស្រី ត្រូវថ្លែងសេចក្តីកក់យនឹងសេចក្តីស្មោះបំពោះឪពុកម្តាយក្មេកនឹងញាតិសន្តានដែលជាសាច់ថ្លៃទាំងប៉ុន្មាន ហើយនឹងរាប់រកដោយស្មើគ្នាចំពោះបុរសដែលត្រូវជាប្តីខ្លួនទាំងអស់ មិនត្រូវបង្ហាញឲ្យឃើញថាស្រឡាញ់ណាជាងណាទេ ៗ តាមទម្លាប់ស្ត្រីនេះ ត្រូវមើលការខុសត្រូវលើទ្រព្យសម្បត្តិ របស់ប្តីទាំងពីរបីនាក់នោះ ហើយប្តីទាំងអស់ត្រូវប្រគល់ប្រាក់កាសដែលរកបានឲ្យប្រពន្ធតែមួយនេះដែរ ប្រពន្ធនេះត្រូវមើលការខុសត្រូវឲ្យប្តីទាំងអស់ ថែទាំកូនចៅ ហើយនឹងចាត់ប្រាក់កាសត្រូវចាយពាយព្រមទាំងត្រូវទុកដាក់ ៗ ឯទំនៀមគឺត្រូវធ្វើដូច្នេះពិត, តែគេមិនសូវធ្វើតាមទេ ជួនកាលគេជាតែមាត់ក្រៅក៏មាន ៗ ប្អូនប្រុសខាងប្តីដែលត្រូវជាប្តីរបស់ប្រពន្ធបងប្រុសខ្លួននោះ ពុំសូវនៅជាមួយ

ទេ ។ មានតែបងប្រុសបង្អស់ទេ ដែលច្រើននៅផ្ទះជាមួយប្រពន្ធ ។ ចំណែកប្អូនប្រុសទាំងប៉ុន្មាន មួយទៅធ្វើឯស្រុកឆ្ងាយ មួយទៀតទៅរកស៊ីនៅស្រុកចិន មួយទៀតទៅស្រុកក្លិង ហើយនៅៗ ទីនោះ សឹងតែជានិច្ចកាលផង ។ ខ្លះទៀតនៅថែរក្សាកេរ្ដិ៍អាកររបស់គ្រួសារ ដែលនៅឆ្ងាយពីផ្ទះឪពុកម្ដាយខ្លួន ។ បើសិនជាអ្នកអស់នោះរកស៊ីបានប្រាក់ច្រើនក្រៅអំពីប្រាក់បំណាច់របស់គ្រួសារ អាចការប្រពន្ធក្រៅទៀតបាន ។

បើប្អូនប្រុសរបស់ប្ដីមិនចង់យកប្រពន្ធរបស់បងទេ អាចទៅការប្រពន្ធក្រៅពីត្រកូលរបស់ខ្លួនបាន ប៉ុន្តែអ្នកនោះនឹងត្រូវបាត់អំណាចទាមទារមត៌កទានឪពុក ។

លើកតែអាពាហ៍ពិពាហ៍តាមធម្មតាចេញ ជនជាតិទីបេតែងប្រព្រឹត្តរួមសង្វាសនឹងគ្នាដោយសេរី តែគេមិនយល់ថាជាការអាក្រក់ទេ ។ ការរួមសង្វាសដោយសេរី មានច្រើនណាស់នៅទីបេ ប៉ុន្តែចំពោះតែអ្នកជំនួញទេ ព្រោះជនពួកនេះច្រើនមានស្រីជាសមាជិកាមាំមួនណាស់ ។ ក្រៅអំពីជំនួយជាប្រយោជន៍នៃជំនួញរបស់ប្ដី ស្ដ្រីទាំងនេះបេះកាន់របរធំៗ ហើយរកប្រាក់ទុកដោយឡែកជាទ្រព្យរបស់ខ្លួនទៀត ។

ទោះជាគេដឹងថា ស្ដ្រីបេះតែមានការត្រេកត្រអាលនឹងបុរសឯទៀតក្រៅពីប្ដីរបស់ខ្លួនយ៉ាងនេះក៏ដោយ ប្ដីក៏មិនដែលបង្ខាំងប្រពន្ធទុកក្នុងផ្ទះទេ; ស្ត្រីស្រុកនោះដើរលេង ទទួលភ្ញៀវ ទៅបុណ្យ ទៅទទួលភោជនាហារដោយសេរី ហើយនិយាយជជែកលេងនឹងបុរសដោយគ្មានញញើតអៀន

ខ្មាសផង ៗ ក៏ប៉ុន្តែ ដល់មកសម័យឥឡូវនេះ ពោះស្រីមានសេរីភាពយ៉ាងនេះក៏ដោយ គង់នៅមានទំនៀមមួយទៀត ដែលស្រីស្រុកទីបេមិនដែលមានសេរីភាពសោះ គឺការរើសប្ដីខ្លួនឯង ៗ

ទំនៀមផ្សំផ្គុំកូនចៅតាំងតែពីតូចៗ នៅស្រុកឥណ្ឌៀនិងនៅស្រុកចិន ទំនៀមនេះមិនដែលមាននៅស្រុកទីបេទេ ៗ ប៉ុន្តែឪពុកម្ដាយទុកដាក់កូនចៅតែតាមចិត្តខ្លួន មិនសួរចិត្តកូនស្រីឡើយ ហើយកម្រនឹងមានកូនស្រីណាហ៊ានបង្វែរចិត្តឪពុកម្ដាយបានផង ៗ

ទំនៀមចាស់នេះ គេលែងកាន់ជាង ១០ ឆ្នាំមកហើយ ឥឡូវនេះគេមានទាំងហាមប្រាមទៀតផង ៗ

ទំនៀមនៅទីបេ មិនដូចទំនៀមនៅស្រុកឥណ្ឌៀទេ នៅឥណ្ឌៀយកគ្នាជាប្ដីប្រពន្ធតែមួយ ៗ រហូតអស់ជីវិត ឯនៅទីបេប្ដីប្រពន្ធចង់លែងលះគ្នាក៏បាន ឲ្យតែទៅថ្លែងទោសនិងការមិនសុខចិត្តបែបណាមួយ ប្រាប់មនុស្សណាដែលចាស់ជាងគេនៅក្នុងភូមិ ឬមនុស្សណាដែលបានមកជាសាក្សីក្នុងពេលរៀបមង្គលការ ៗ អ្នកទទួលពាក្យបណ្ដឹងនេះ អាចកាត់សេចក្ដីឲ្យបាន ហើយនឹងជំរះអំពីទ្រព្យសម្បត្តិថា ត្រូវបានទៅអ្នកណា ឬអ្នកណាផង ៗ អ្នកស្រុកទីបេមិនដែលឈ្លោះគ្នា ព្រោះរឿងប្រចែប្រច័ណ្ឌប្ដីប្រពន្ធទេ ៗ បើគេលួចពង្រត់ប្រពន្ធបាត់ទៅ ប្ដីគ្រាន់តែទៅទារឲ្យសងបណ្ណាការមកខ្លួនវិញ អំពីអ្នកសហាយប្រពន្ធខ្លួននោះ, ចំណែកខាងស្រីវិញ ក៏ទៅទារប្រាក់ពីស្រីណាដែលលួចយកប្ដីរបស់ខ្លួននោះដែរ ៗ

# សុភាសិតរាជនីតិ

ពាក្យកាព្យ

## អ្នកឧកញ៉ាមហាវិនិច្ឆ័យ នៅ

រៀបរៀង

---

## អារម្ភកថា

*សុភាសិតនាមរាជនីតិ*

ជាក្បួនសំនួនចាស់បុរាណគិត  ប្រពៃពិតសម្រាប់ថ្វាយក្សត្រា ។
ដ៏ជាឥស្សរេតកេតុម្ភជ  វិសុទ្ធថ្លៃវិសេសសុសមា
ជាពំនឹងពឹងពាក់សរណា  ពស្ត្ររដ្ឋបានសុខនិរទុក្ខភ័យ ។
តែច្បាប់ក្បួនបុរាណជាពាក្យពយ  និយាយសារសព្ទប្រាប់តែន័យ
ដំណើរច្បាប់ក្រិត្យក្រមដ៏ប្រពៃ  ឥតមោះមៃមែនមានជាក្បួនមក ។
ទើបខ្ញុំរិះត្រេកត្រិះជាពាក្យជួន  សំនួនកាព្យកិច្ចគិតលៃលក
ទុកតំណតទៅជនរិះរក  ត្រាន់នឹងយកមកមើលគិតរិះធ្យាន ។
រឿងនេះសម្ដេចព្រះសុគន្ធា  ព្រះឧបជ្ឈាយ៍ទ្រង់ប្រោសព្រះរាជទាន
ឲ្យដល់ខ្ញុំយកទុកជាប្រធាន  ត្រាន់ទូន្មានប្រដៅនូវអាត្មា ។
ដែលនឹងចូលធ្វើជាខ្ញុំព្រះបាទ  សម្ដេចកវនាថអគ្គឥស្សរ
គួរឲ្យចេះបំណេះសេវកា  សុសមាសុចរិតដោយក្រិត្យអើយ ។

អ្នកឧកញ៉ាមហាវិនិច្ឆ័យ នៅ

បានរៀបរៀង រឿងនេះ កាលនៅជាសុគន្ធរបនា ។

# រាជនីតិសាស្ត្រសុភាសិត

រាជនីតិ សត្ថំ វញ្ញោ ទិដ្ឋធម្មត្ថសាធកំ
វិប្បតេ ពុទ្ធិវឌ្ឍិតំ បរំវឌ្ឍិមទ្ធនេ ។
ឥត្ថាវិ រតនត្តយំ សុភាសិតំ បរិក្ខាមិ
សុខាវហំ បអាទិ បញ្ញាវឌ្ឍិ រាជាធំ ។

ខ្ញុំសូមបង្គំបីព្រះគុណ រតនត្រ័យជាមុនដោយសិរសំ
ទីនេះពាលកាសិកគិតល់ខំ គតាំងលេខាពោហារកាព្យ ។
តម្រិះត្រិះទុកតាមតម្រា រាជនីតិរក្សារាជជពាប
ដើម្បីក្តីសុខមិនដុនដាប កាត់បាបប្រាបបង់រាជសត្រូវ ។
គ្រានេះនឹងថែងតាត់តាមក្បួន សំនួនសួនរបេងបតម្រូវ
តម្រាយអ្នកប្រាជ្ញពីមុនកូរ តឡូវក្លាយសំដូចាប់ជួនថា ។
គម្ពីររាជនីតិសាស្ត្រនេះ ទ្រទ្រង់តម្រិះរាជខត្តិយា
ដើម្បីចំរើនព្រះប្រាជ្ញា បេហ្គាអំណាចក្នុងខែត្រដែន ។
កិរិយាញ៉ាញក់រាជបរច័ក្ស បំបាក់ខ្ញុំបខ្លាចពប់រយសែន
ដោយព្រះប្រាជ្ញាក្លាវៃខ្ទួន ណាសំណែនក្នុងដួងព្រះហ្ឫទ័យ ។
មួយបើចង់ផ្ចាប់ខ្ញុំរាជការ ឯណាពោហារប្រាជ្ញាវៃ
ឬជាអន់អាប់ពុំប្រពៃ ក្នុងន័យឲ្យស្តាប់ការបរបា ។
ចង់ដឹងអ្នកមានសីលវត្ត ប្រាកដប្រកបគ្រិត្យកិរិយា
ឬជាទុស្តសីលសូន្យអសារ លោកថាមើលនាកាលនៅផង ។

ចង់ដឹងអ្នកស្អាតឬមិនស្អាត
ប្រមាទទ្វេធ្វេសធ្វើឲ្យហ្មង
មិនល្អិតគិតល្អដោយបំណង
មើលនាទំនងធ្វើការងារ ៗ
ចង់ដឹងចរិតចិត្តសុភាព
រៀនកបទាបទន់ធន់អាចារ
កតញ្ញូស៊ូជន្មមរណា
មើលគ្រាកាលមានភ័យមកដល់ ៗ
ក្សត្រខត្តិយវង្សទ្រង់គួរលះ
ស្រឡះចាកមនុស្សគ្មានយោបល់
ប្រកបទោសហេតុមិនមានផល
មិនគួរដឹកល់ជាមាត្យា ៗ
បុរសប្រកបទោសប្រាំបី
មានន័យសំដែងថ្លែងទុកថា
មួយមនុស្សប្រមូសមិនខុសក្រហ៍
មួយមានកិរិយាចិត្តអាក្រក់ ៗ
មួយមានគំនិតចិត្តឆោតខ្លៅ
មួយហៅមារយាទជាតិលាមក
មួយតែងធ្វើការឲ្យខូចធុក
មួយប្រាំងប៉ៃទុកទោសខ្លួនឯង ៗ
មួយមិនមានចិត្តគិតសន្ដោស
ប្រសប្រោសសប្បុរសគ្រប់តំណែង
មួយមិនក្លៀវក្លាអាចខះខែង
តាំងតែងតតបបច្ចាមិត្ត ៗ
មហាក្សត្រគួរកាត់លះបុរស
ប្រកបទោសអស់ប្រាំបីពិត
មិនគួរចិញ្ចឹមនៅជាប់ជិត
គួរគិតកុំយកមកប្រើការ ៗ
មួយទៀតក្សត្រខត្តិយវង្ស
បំរុងប្រជារាស្ត្ររដ្ឋា
គួរកុំតាំងមនុស្សទោសមុហា
ប្រាំពីរប្រការទៀតតទៅ ៗ
មួយមនុស្សវប៊ីទុច្ចរិត
ក៏ចាមិនល្អិតចិត្តឃោរឃៅ
សំដីអាក្រក់តក់ម៉ក់ទៅ
មិនស្គាល់ពក់ព្រៅនៅក្នុងខ្លួន ៗ
មួយមនុស្សរមែងកាចកិនគេ
រះរេកហេតុកេទផ្ទេរផ្ទួន

ទូលពិតញុះញង់ឲ្យទ្រង់គួន
មួយមនុស្សប្រែកប់ដោយក្តីលោភ
ខ្វះខ្វៃខ្វៃខំតាមចិន្តា
មួយមនុស្សមិនស្គាត់កង្វះមុសាត្រ
ទោះទាំងពជនទីតក្តាំគ្គង
មួយមនុស្សអកតញ្ញូតា
ដំទ្រង់ព្រះគុណគម្ពីរក្រាស់
មួយមនុស្សឃើញតែប្រយោជន៍ខ្លួន
មានម្ចាស់ជាដើមក៏ផ្ទេសទ្វេ
មួយមនុស្សពាមុសាវាទ
ក្លួតព្រាងបញ្ឆេងតាមយោបល់
ប្រាំពីរបទនេះជាទោសពិត
មិនគួរទ្រង់តាំងជាឥស្សរ

## មុខម្ហូបប្រូសេរីកាមាត្យ

វង្វេងវិលវល់ខ្វល់អប្រិយ
ប្រោសប្រាណរាប់អានទុកព្រះទ័យ
តាំងទុកជាធំទីប្រឹក្សា
មួយគឺអា ត់តត់ស្សរិយយស
ទោះទាំងបរិវាររាប់រយលាន
មួយគឺវិនាសប្រយោជន៍ផល

គំនុំគំនួនគួនទោសា ។
ចិត្តលោភមិនល្មមផុតប្រាថ្នា
ហៅមហាលោភោត្រាកគ្គង ។
ប្រមាថមិនវៀនច្បាប់ទំនង
មិនអាចរាប់រងវៀនឲ្យច្បាស់ ។
រមិលគុណមហាក្សត្រជាម្ចាស់
ក្រឡា ប់ក្បួបគេបមិនគ្រេ ។
មែនមួន ិនឃើញប្រយោជន៍គេ
ទុរគ្មានទឹករព្ទកដល់ ។
កុហកបង្វៀតពាក្យឥតផល
មិនមានដកល់ពាក្យសត្យា ។
ទុច្ចរិតប្រាកដកុំកង្ខា
សម្រេចពជការកេងផែនដី ។
បើមិនឡើរឡាតឈ្លាសសេចក្ដី
ហើយព្រះចក្រីទ្រង់មេត្តា ។
រំពៃរំពឹងជួយពជការ
ទោសរើប្រការប្រាកដមាន ។
ខ្ពង់ខ្ពស់ទីងទាបទៅជាគ្មាន
ទឹងអត្ថរបានបាត់បោះបង់ ។
ដែលដល់មកដូចតាមចំណង់

ទឹងក្លាត់ខ្លាត់ចេញចាកព្រះអង្គ
មួយទៀតវង្គតរលត់ខ្ទង
ប្រកបក្តីទុក្ខមិនសុខសាន្ត
ព្រោះហេតុផ្សិតទោសតាំងបុរស
មិនមានប្រាជ្ញាការឧត្តម

### បញ្ចោមប្ចោជមាត្យ

ប្រាជ្ញាវៃពន់ឃាង់គំនិត
ហើយស្តេចសម្រេចឲ្យជាធំ
ជាទីប្រឹក្សាការត្រិត្រិ
មួយគឺទឹងមានឥស្សរិយយស
បរិបូណ៌ព្រមព្រៀងតាំងបរិវារ
មួយមានសម្បត្តិសម្បុរបុណ្យ
ប្រកបបុញ្ញារិទ្ធិអចិន្ត្រៃយ៍
មួយកាលសុវណ្ណគតផុតជន្ម
សោយសុខទិវ្វជាប្រធាន

### យិកិញ្ចោករគេភជោ

ប្រព្រឹត្តសុចរិតឥតមោះមៃ
សេចក្តីតាំងពីរនេះប្រាកដ
ទឹងជាប់ជិតដល់ម្ចាស់តាំងអស់
ហេតុនោះព្រះចៅចមពិកត

តម្រេកត្រេកត្រង់ក៏ត្រូវទាន ៗ
ទៅការកើតទានរកបាន
ប្រមាណតាល់ផុតយថាកម្ម ៗ
អាប់យសមិនយល់ក្តីសាំញ៉ាំ
ទើបនាំដូចន័យតាំងពីពិត ៗ
សេវកាណាមួយឆ្ងៀវឆ្លាតគិត
ប្រព្រឹត្តសុចរិតប្រកបល្អ ៗ
និយមកំណត់សមោសរ
ទឹងកកើតគុណប្រការ ៗ
ប្រសើរខ្ពង់ខ្ពស់យសសក្តា
ឧឡារអនេកអនន្តទ្រៃ ៗ
ទ្រព្យធនគោគកស្រ្តជាមហៃ
អាស្រ័យយុត្តិបញ្ញាញាណ ៗ
បានទៅកើតនាសួគ៌ពិមាន
ដោយទ្រង់មានញាណឆ្នុះឆ្លាសវៃ ៗ
អមច្ចោ អមាត្យណាមួយនៃ
ប្តីប្រពៃទុច្ចរិតស្មោះ ៗ
កំណត់និយមមិនសូន្យសោះ
ព្រោះរបស់អមាត្យសមាគម ៗ
កុំគប់មនុស្សខ្លៅឲ្យផងធំ

ទីងផ្ទាត់ប្រយោជន៍ក្នុងភពរម្យ
គួរតែសេពសមអ្នកប្រាជ្ញប្រាយ ។
ដែលមានបញ្ញាក្លាយោបល់
ដឹងគល់បញ្ហាអត្ថទាំងឡាយ
ទីងមានប្រយោជន៍ផលវែងឆ្ងាយ
សប្បាយសមបុណ្យសុវត្តី ។

## កុលសីលោគុណោបេតំ

អត្ថធិប្បាយស្រាយសេចក្តី
បទ្វែកចេញពីបាលី
តាមន័យលោកចែងសម្តែងថា ។
មហាក្សត្រដ៏ទ្រង់ឥស្សរេត
មុជគេគបមពិនរាជសីមា
ទីងរើសរកជាតុលាការ
ក្នុងទីពិភាក្សាក្តីក្រស្តផង ។
នោះគួរតែងតាំងរាជបុរស
ប្រកបគុណនោះមិនមានហ្មង
ប្រាំពីរប្រការដោយទំនង
បុរាណលោកចង់ជាក្បួនថា ។
ប្រការមួយប្រកបត្រកូលវង្ស
ប្រការមួយឋិតក្នុងសីលាចារ
ប្រការមួយឲ្យមានពាក្យសត្យា
មួយមានប្រាជ្ញាឆ្លៀវឆ្លាសចុះ ។
ប្រការមួយទៀតឲ្យប្រាកដ
ស្ទាញស្ទាត់ធម្មសាត្រច្បាប់សព្វស្រុះ
មួយឲ្យពោលពាក្យមធុរស
មួយទៀតមិនលុះអគតិបួន ។
ប្រាំពីរបទនេះបើបុរស
មាននោះរាបស្មើនៅក្នុងខ្លួន
គួរទ្រង់តាំងទុកឲ្យសមសួន
មាំមួនក្នុងទីពិភាក្សា ។
ន័យមួយគួរតាំងរាជបុរស
ប្រកបគុណនោះប្រាំប្រការ
ឲ្យជាទាយយ៉ាំងចាំរក្សា
ក្រស្តាកែវកងពិទូរ្យរតន៍ ។
មួយគឺប្រកបត្រកូលជាតិ
មារយាទជាមនុស្សត្រង់ប្រាកដ
ប្រការមួយបានហាត់ព្យាមស្ទាត់
ម៉ត់ចត់រក្សាទ្រព្យឲ្យល្អ ។

(មានត)

# ពេជ្រព្រះរាជា

លោក ស៊ិន-ហ៊ាន ប្រែរៀបរៀង

លោក យ៉ូវ-អ៊ុន ពិនិត្យកែសម្រួល

(តមក)

---

អមាត្យបានឮមាណពអង្វរករ ក៏ព្រមទទួលពាក្យថានឹងទៅនៅស្នាក់ផង, មាណពសំដែងសេចក្ដីត្រេកអរហើយឡើងជិះសេះនាំមុខ, អមាត្យបរសេះតាមក្រោយទៅ ។

ក្នុងវេលាព្រលប់ថ្ងៃនោះ មាណពអញ្ជើញអមាត្យរួមភត្តាហារជាមួយគ្នា ក្នុងទីក្បែរមាត់ទឹកខាងក្រោយផ្ទះដែលមាណពជួលនៅ ។ អមាត្យបានស្និទ្ធស្នាលនឹងមាណពអស់វេលាដ៏យូរ ក្នុងខណៈនោះគាត់នឹកថាគេជាបុរស ១ រូបមានចំណេះចេះចាំនឹងមានវិជ្ជាផ្សេងៗ ព្រមទាំងស្គាល់ទីកន្លែងស្រុកទេសដទៃៗទៀត ដូចេះគួរសន្ទនាបណ្ដើរ ទទួលទានអាហារបណ្ដើរ; ក្នុងឱកាសនោះអមាត្យចាប់ភ្លឹកនឹកឃើញនូវពាក្យរបស់មាណពដែលនិយាយអំពីវេលាថ្ងៃនៅក្នុងពេលពិធី ទើបសួរថា ៖

"មាណពសំឡាញ់ ! ខ្ញុំមិនទាន់អស់សង្ស័យនៅឡើយ ចំពោះពាក្យរបស់លោកដែលនិយាយអំពីថ្ងៃមិញ បើលោកមិនចង្អៀតចង្អល់ចិត្តទេ សូមលោកនិយាយប្រាប់ឲ្យខ្ញុំបានដឹងរឿងនោះខ្លះផង, ការដែលខ្ញុំចង់ដឹងរឿងនេះ ដើម្បីជាគ្រឿងប្រដាប់ដល់សតិបញ្ញាខ្ញុំប៉ុណ្ណោះ" ។

"មិនអីទេ ! ខ្ញុំមិនទើសទាល់ចិត្តទេ កាលបើលោកចង់សួរអ្វីក៏សួរមកចុះ តែកុំសួរឲ្យដល់ថ្នាក់ប្រដាប់សតិបញ្ញារបស់លោកឡើយ ព្រោះ

ខ្ញុំនៅវ័យក្មេង បញ្ញាក៏ទុនថយ ម្ដេចឡើយនឹងដឹងអ្វី ៗ ឲ្យល្អជាងលោក ដែលមានវ័យចាស់ជាងខ្ញុំ" មាណពនិយាយជំរាបដោយអាការញញឹម ញញែមបង្ហាញឲ្យឃើញថាមិនមានសេចក្ដីរង្កៀសកន្ទងការសាកសួររបស់អមាត្យឡើយ ។

អមាត្យបាលិតពោលពាក្យអរគុណមាណពហើយ ទើបសួរៈ "មាណពសំឡាញ់! លោកក៏បានជ្រាបហើយថាការបូជាយញ្ញរបស់ព្រះរាជាក្នុងនគរនេះត្រូវមានសំណែនដោយសត្វរស់ ៗ ជាចំនួនច្រើន កប់ថាជាពិធីចាំបាច់ម្យ៉ាងដែលត្រូវធ្វើជាប់ត ៗ គ្នាមក ដរាបដល់សព្វថ្ងៃនេះ ដើម្បីវត្ថុបំណងម្យ៉ាង គឺប្រាថ្នានឹងកំចាត់បោសសំអាតគ្រោះភ័យដែលកើតឡើង ហើយគ្រោះភ័យដែលកើតនោះនឹងវិនាសទៅដោយសារពិធីនេះ ចំណែកលោកត្រឡប់ជាយល់ឃើញថា ពិធីនេះឥតប្រយោជន៍វិញ ទើបខ្ញុំចង់ដឹងចំពោះការយល់ឃើញរបស់លោកជាទីបំផុត" ។

មាណពអង្គុយស្ដាប់អមាត្យសួររាល់តែចប់ ទើបបានក្រោកឡើង ហើយដើរចេញទៅកាន់ទីមាត់ទឹកដោយអាការស្ងួតស្ងប់ ដកដង្ហើមធំ ងើយមុខឡើងសម្លឹងមើលវង់ព្រះចន្ទដែលមានរស្មីដ៏សុខុម កណ្ដាលអាកាស ៈហើយទើបបែរមុខមកនិយាយនឹងអមាត្យៈ

"សំឡាញ់ចាស់! មុននឹងខ្ញុំប្រាប់នូវការដឹងរបស់ខ្ញុំ, ខ្ញុំត្រូវតែជំរាបលោកថា ការចេះដឹងទាំងនេះដែលកើតមានឡើងដល់ខ្ញុំ ដោយខ្ញុំបានទទួលលទ្ធផលផ្លូវមកអំពីព្រះធម៌ដែលជាពាក្យប្រៀនប្រដៅ

សាសនារបស់ព្រះសម្មាសម្ពុទ្ធម្ចាស់ ...” រូបមាណពសម្លឹងមើលមុខអមាត្យបាលិត ។

“ដូចម្ដេច សាសនារបស់ព្រះសម្មាសម្ពុទ្ធម្ចាស់?” អមាត្យបាលិតសួរហើយសម្លឹងមើលមុខមាណព ដោយខ្លាចក្រែងមិនពេញចិត្ត ព្រោះពាក្យនេះគាត់មិនធ្លាប់បានដឹងបានឮនរណានិយាយដល់ឡើយ ។

“ សំឡាញ់ចាស់ ! សាសនា ឬពាក្យប្រៀនប្រដៅទាំងឡាយតែងមានអ្នកគិតគ្នាន់គ្នេរបានហើយនាំមកប្រៀនប្រដៅ ដែលយើងនិយមហៅថាសាស្ដា ហើយពាក្យប្រដៅរបស់សាស្ដានោះហៅថាសាសនា តែសាសនាដែលខ្ញុំកំពុងនិយាយដល់នេះជាសាសនារបស់ព្រះសម្មាសម្ពុទ្ធម្ចាស់, ព្រះអង្គបានត្រាស់ដឹងដោយអំណាចនៃការស្ងប់ចិត្តវៀរចាកកិលេសទាំងឡាយ ដែលកម្រមានអ្នកណាលះបាន, ហេតុនេះឯង ពាក្យប្រដៅរបស់ព្រះអង្គ ទើបជាធម៌ខ្ពស់ជាងពាក្យប្រដៅរបស់សាស្ដាដទៃ ព្រោះព្រះអង្គបានត្រាស់ដឹងដោយប្រពៃ ទើបទទួលព្រះនាមថាព្រះសម្មាសម្ពុទ្ធម្ចាស់” ។

អមាត្យបាលិតមិនទាន់ចូលចិត្តច្បាស់នៅឡើយ គឺមិនដឹងថាព្រះសម្មាសម្ពុទ្ធម្ចាស់ មានគុណវិសេសដូចម្ដេច, ពាក្យប្រដៅរបស់ព្រះអង្គដែលហៅថា ព្រះធម៌ដូចម្ដេច, ទាំងមិនបានដឹងថាព្រះសង្ឃសាវ័ករបស់ព្រះពុទ្ធម្ចាស់ មាននៅកន្លែងនគរពាណាសីទៀតផង ត្រាន់តែដឹងថាព្រះពជាប្រទន់កាន់សាសនាព្រាហ្មណ៍ ទើបមិនបានទ្រង់លើកតំកើងពុទ្ធ-សាសនាឡើយ, ដូច្នោះការធ្វើពិធីផ្សេង ៗ ក្នុងព្រះពជតំណាក់ ក៏ធ្វើ

ទៅតាមពិធីព្រាហ្មណ៍ទាំងអស់, អមាត្យបាលិតក៏ដូចគ្នា បានធ្លាប់ហ៊ឹកហាត់អប់រំផ្សេង ៗ មកតែក្នុងសាសនាព្រាហ្មណ៍ ទើបជឿក្នុងពាក្យប្រដៅរបស់ព្រាហ្មណ៍តែម្យ៉ាង, ព្រោះហេតុនោះទើបបាលិតអមាត្យសួរ:

“សូមលោកមេត្តាប្រាប់ខ្ញុំឲ្យបានដឹងនូវពិធីយញ្ញ ក្រៅអំពីពាក្យប្រដៅសិនចុះ, តើយញ្ញឯណាដែលព្រះសម្មាសម្ពុទ្ធមាស់ទ្រង់ឲ្យធ្វើ? យញ្ញឯណាដែលគួរក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ?” ៗ

មាណពបានស្តាប់ពាក្យសួររបស់អមាត្យបាលិតហើយ ក៏ដឹងភ្លាមថា បុរសជរានេះមានការចេះដឹងដោយបានអប់រំមកតែក្នុងសាសនាព្រាហ្មណ៍ប៉ុណ្ណោះ ចំណែកព្រះធម៌ជ្រាលជ្រៅវិញ គាត់មិនមានការចេះដឹងឡើយ ទើបតបថា:

“លោកឲ្យខ្ញុំប្រាប់អំពីយញ្ញរបស់ព្រះសម្មាសម្ពុទ្ធមាស់នេះជាការល្អហើយ . . . សូមលោកត្រិះរិះមើលចុះ” មាណពនិយាយហើយងើយមើលមុខអមាត្យរួចសម្លឹងទៅឯអាកាស, ទទួលពេលនោះវង់ព្រះចន្ទមានលក្ខណៈជិតពេញវង់ហើយ ទើបមាណពចង្អុលប្រាប់ឲ្យសំឡាញ់ជរាជាគូសន្ទនាមើល:

“វង់ព្រះចន្ទថ្ងៃនេះ ក៏ធំរៀងរាបជិតពេញវង់ហើយ, ការក្តៅក្រហាយចិត្តរបស់ខ្ញុំរឹតតែខ្លាំងឡើង មិនយូរប៉ុន្មានព្រះរាជាដែនគរវេសាលីនេះក៏រៀបចំធ្វើពិធីយញ្ញ, យញ្ញរបស់ព្រះរាជានោះចាត់ថាលាមកអាក្រក់ជាការធ្វើដោយងងឹតល្ងង់ . . . ខុសប្លែកអំពីយញ្ញរបស់ព្រះសម្មាសម្ពុទ្ធមាស់, ឯយញ្ញរបស់ព្រះសម្មាសម្ពុទ្ធមាស់ជាពិធីដ៏បរិសុទ្ធ ប្រសើរក្រៃ

ប្រៀបផ្ទឹមពុំបានឡើយ ព្រោះព្រះអង្គទ្រង់ឲ្យធ្វើយញ្ញគឺការសម្លាប់ដូចគ្នា តែការសម្លាប់នោះ គឺសម្លាប់របស់ដែលមាននៅក្នុងខ្លួន ដែលចាត់ជាកិលេសដ៏លាមកអាក្រក់, សំឡាញ់ដក! សូមលោកមេត្តាឲ្យអភ័យ·ទោសដល់ខ្ញុំ ។ សូមឱកាសសួរលោកវិញ សូមលោកតបឲ្យខ្ញុំបានដឹងផង ដើម្បីជាផ្លូវដល់ការបន្ដុលពន្យល់ខ្ញុំវិញបន្តិចចុះ” ។

អមាត្យបាលិតរង់ស្ដាប់ ដោយសេចក្ដីពេញចិត្ត យូរៗ ញាក់មុខទទួលម្ដងៗ; មាណពទើបពោលតទៅ:

“រូបកាយរបស់លោកក្ដីរបស់ខ្ញុំក្ដី រមែងជាទីស្រឡាញ់នៃយើង មិនមែនឬ?” ។

“មែន” អមាត្យបាលិតទទួលពាក្យ ។

“អើ... នេះឯង សំឡាញ់ចាស់! សាសនារបស់ព្រះគោតម ប្រដៅក្នុងយ៉ាងនេះ ព្រោះការដែលមានជីវិតរស់នៅជារបស់គេបានដោយក្រ, ការសម្លាប់ជីវិតរបស់ខ្លួនឯង អ្នកមានប្រាជ្ញាតែងមិនប្រាថ្នា, ការសម្លាប់ជីវិតអ្នកដទៃ តែងកឲ្យកើតពៀរ, ឯពៀរនោះមានសេចក្ដីសំគាល់ច្រើនយ៉ាង, ពៀរបានដល់ការអាឃាតរបស់អ្នកដែលត្រូវសម្លាប់ដូចការអាឃាតរបស់ញាតិមិត្រ មានបងនឹងប្អូនរបស់អ្នកដែលត្រូវសម្លាប់ជាដើម, ព្រោះអាស្រ័យពៀរទើបការសម្លាប់គ្នាមានឡើងរឿយៗ ដែលជាហេតុកឲ្យកើតបាប, ចុះលោកចូលចិត្តឬទេចំពោះពាក្យថាបាបនេះ?” ។

“ចូលចិត្តហើយសំឡាញ់ ! បាបគឺផលនៃអំពើអាក្រក់ដែលផ្ទុយនឹងពាក្យថាបុណ្យ” អមាត្យបាលិតតបយ៉ាងជាក់លាក់ហើយត្រូវផង ដែលជាទីពេញចិត្តរបស់មាណពពន់ពេក, ទើបមាណពតបវិញ:

“ត្រូវហើយ សំឡាញ់ដ៏មានអាយុ ! សេចក្ដីរីករាយ ដែលកើតអំពីផលនៃបុណ្យ គឺជាផលដ៏បរិសុទ្ធនាំសេចក្ដីសុខសប្បាយទាំងពួងមកឲ្យដល់ចិត្ត, ចំណែកបាបមានផលដ៏ក្ដៅក្រហាយ, ព្រះសម្មាសម្ពុទ្ធមិនទ្រង់លើកតំកើងនូវការផ្ដាច់ជីវិតទេ ! ទោះជាជីវិតរបស់សត្វតូចល្អិតក៏ដោយ ក៏ព្រះអង្គទ្រង់ហាមជាដាច់ខាត, លោកដ៏មានអាយុ ! ការមិនសម្លាប់សត្វដែលមានជីវិត គឺជីវិតខ្លួនយើងនឹងជីវិតរបស់អ្នកដទៃ ហៅថាការកាន់សីល, ការកាន់មិនសម្លាប់ជីវិតនេះឯង ចាត់ថាសីល ក្នុងពួកសីល ៥ នៃពាក្យប្រដៅរបស់ព្រះគោតម ហើយជាសីលខ ដំបូង” ។

អមាត្យបាលិតមិនធ្លាប់ស្ដាប់ពាក្យបែបនេះ អំពីនរណា ១ ដល់មុនសោះ, ការជឿនខ្លួនក៏ផ្ដើមមានឡើង ព្រោះបានឮថាបុណ្យនាំសេចក្ដីសុខមកឲ្យ ហើយបាបជារបស់មានផលដ៏ក្ដៅក្រហាយ ទើបសួរតទៅ:

“សំឡាញ់ ! សូមលោកមេត្តាប្រាប់ខ្ញុំបន្តិចតទៅទៀត, តើដូចម្ដេចទើបចាត់ថាជាបុណ្យ ព្រោះខ្ញុំប្រាថ្នាចំពោះសេចក្ដីសុខ ដែលកើតអំពីផលនៃបុណ្យ...” ។

(មានត)

## កណ្ឌទី ២៣

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាប្រវត្តិសាស្ត្រ
អ្នកវាងវៃឆ្លាតបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ប៊ូឆូបានស្ដាប់ដូច្នោះ ក៏ចាត់ចែងយកទាហានកងក្រោយលើកមកជាកងមុខ យកទាហានកងខាងមុខឲ្យត្រឡប់ទៅនៅពីក្រោយ ហើយឲ្យនាំរទេះដែលផ្ទុកស្បៀងអាហារបរទៅពីមុខកងទ័ព ។ លីយ៉ូយដំកបសួរប៊ូឆូថា ហេតុម្ដេចបានជាមហាឧបរាជឲ្យនាំយករទេះស្បៀងទៅដាក់ពីមុខកងទ័ពវិញ? ។ ប៊ូឆូតបថា យើងលើកទ័ពទៅធ្វើសង្គ្រាមកល់ដងយកស្បៀងអាហារទៅដាក់ពីក្រោយបេះតែបរាជ័យ, ម្ដងណោះយើងឲ្យនាំទ័ពស្បៀងទៅដាក់ពីមុខវិញ ។ លីយ៉ូយដំកបសួរថា បើជាប្រទះនឹងកងទ័ពអ៊ូនសៀវកណ្ដាលផ្លូវ ទាហាននាំស្បៀងទាំងឡាយសុទ្ធតែមិនចំណានក្នុងការសង្គ្រាម ទឹងមិនខូចស្បៀងអាហារឬ? ។ ប៊ូឆូតបថា

“អ្នកកុំព្រួយចិត្តគិតអ្វីឡើយ ត្រង់ដែលទឹងបានទឹងបង់ប្រការម្តេច គង់តែ យូរទៅអ្នកទឹងដឹងគំនិតរបស់យើងមិនខាន” ហើយចូឆូ ក៏ស្រូតបន្ទំលើក កងទ័ពដល់កណ្តាលផ្លូវ ទ័ពមុខចូឆូជួបប្រទះនឹងទ័ពប៊ុនធីរ បានតតាំង ច្បាំងគ្នាជាពទ្ទឹក, កងឡាំលៀងនៃចូឆូដែលនាំស្បៀងអាហារទៅនោះ មិនប៉ុនប្រសប់នឹងច្បាំង ក៏បែកខ្ចាត់ខ្ចាយទៅទាំងស្បៀងអាហារអស់ ។ ទាហានប៊ុនធីរ ក៏ចាប់បានស្បៀងអាហារទាំងគ្រឿងសស្ត្រាវុធជាច្រើន ។ ឯកងឡាំលៀងដែលបែកទៅនោះ ក៏នាំយកពត៌មានមកជំរាបចូឆូថា ទាហានប៊ុនធីរវាយកាត់យកស្បៀងបានអស់ហើយ ខ្ញុំទឹងស្រូតមកជំរាប លោកមិនទាន់ការ ឥឡូវទាហានប៊ុនធីរលើកទ្រនាន់ចូលមក ។ ចូឆូ បានស្តាប់ក៏មិនតបឆ្លើយថាអ្វីសោះ ទទួលក្រឡេកឃើញជើងភ្នំនៅក្បែរ ផ្លូវ ក៏នាំទាហានទាំងពួងចូលទៅអែបនៅក្បែរជើងភ្នំនោះ ហើយឲ្យ ទាហានចុះពីលើសេះដោះក្រឹសចេញ តែទាហានដែលនៅជិតចូឆូនោះ ឲ្យកាន់អាវុធប្រចាំការ ។ ឯទាហានចូឆូក្រឡេកឃើញទាហានប៊ុនធីរ លើកតាមមកជិតក៏ភ័យណាស់ បបួលគ្នាស្រែកដោឡោថា ត្រូវតែថយ ទៅបន្ទាយប៉ុះបែរវិញ ។

ស៊ីនហ៊ីវជំងអធ្យាស្រ័យនៃចូឆូ លុះក្រឡេកឃើញទាហានកងទ័ព ត្រឡប់បែកខ្វែកដូច្នោះ ក៏ហាមឃាត់ពួកទាំងនោះថា កុំឲ្យភ្ញាក់ផ្អើលធ្វើអ្វី ត្រានេះយើងបានគល់ការហើយ ។ ចូឆូបានឮស៊ីនហ៊ីវនិយាយដូច្នោះក៏ ត្រេកចិត្តណាស់អស់សំណើចៈហើយញាក់មុខឲ្យស៊ីនហ៊ីវ ។ ឯទាហាន ប៊ុនធីរលុះលើកគ្នាមកឃើញកងទ័ពចូឆូនៅជើងភ្នំ មិនបានរៀបរយជាជួន

ទ័ព ប៊ុនធឺវនឹងទាហានទាំងពួងក៏មានចិត្តកំរើកលើកគ្នាចូលវាយដណ្ដើម យកសេះទឹងគ្រឿងសស្ត្រាវុធ ដែលដាក់កក់យនៅក្បែរផ្លូវនោះ ៗ ចូច យល់បានចំណាប់ក៏បង្គាប់ឲ្យកងទ័ព ដែលពួនបង្កប់នោះចេញមកឡោម ព័ទ្ធប៊ុនធឺវ ចូលចាប់សម្លាប់ពួកទាហានប៊ុនធឺវ ៗ ក៏កទ័ពមកច្បាំងតស៊ូជា ពន្លឹក លុះឃើញថាកំឡាំងទឹងតទល់មិនបាន ក៏ញាក់សេះស្ទុះបំពាន ចំលាយទ័ពចូចដែលព័ទ្ធនោះចេញទៅតែម្នាក់ឯង ៗ ចូចនៅលើកំព្រែកឡែក ឃើញផ្លូវបោះក៏ស្រែកថា ប៊ុនធឺវជាសេនាឯកអ្នួនសៀវបំផាយសេះរត់ទៅ ខាងណោះហើយ នរណាទឹងយកអាសាចាប់ឲ្យឃើងបាន? ៗ

ទៀវលៀវទឹងស៊ុឡុងក៏ឆ្លើយឡើងទទួលយកអាសា ហើយបំផាយ សេះតាមទៅ ប៊ុនធឺវងាកមកឃើញទាហានសេះ ២ បរដេញតាមមក ក៏ យិតធ្នូបាញ់ត្រឡប់មកវិញ ត្រូវកំពូលមកុដទៀវលៀវដាច់ធ្លាក់ពីលើក្បាល ទៀវលៀវទឹងណាសក៏ពង្រឹតសេះដេញចូលទៅមុខសេះស៊ុឡុង បំណង ទឹងចាប់ខ្លួនប៊ុនធឺវឲ្យបាន ប៊ុនធឺវបាញ់ថែម ១ ព្រួញមកទៀត ត្រូវ កំផ្ទៀងទៀវលៀវធ្លាក់ពីលើសេះ ប៊ុនធឺវក៏ឆាកត្រឡប់មកទឹងកាប់ទៀវ-លៀវ ទទួលស៊ុឡុងស្ទុះទៅទាន់យកដាវរងដាវប៊ុនធឺវជាប់ ស៊ុឡុងនឹងទឹង ប៊ុនធឺវក៏ប្រយុទ្ធគ្នាទៅវិញទៅមកបាន ៣០ ក្បួន ទទួលទាហានប៊ុនធឺវ ដែលទៅពីក្រោយលើកពួនចូលមកជាច្រើន ស៊ុឡុងឃើញទឹងថ្មោះការ ក៏នាំទៀវលៀវត្រឡប់ចេញមករកចូច ៗ គ្នួនអ្នូឃើញផ្លូវបោះក៏បំផាយ សេះនាំទាហានប្រហែល ១១-១២ នាក់ស្លុកពីមុខប៊ុនធឺវ ហើយស្រែក សន្ធាប់ថា អាសត្រូវបរសេះរត់ទៅណា? ប៊ុនធឺវឮច្បាស់ក៏ទឹងប្រឡែក

ចូលប្រយុទ្ធនឹងគួនអ៊ូបាន ៣ ក្លែង ប៊ុនធីរយល់កំឡាំងទឹងទប់ពុំបានក៏បែរសេះថយត្រឡប់ទៅរកកងទ័ពទៀត គួនអ៊ូបរសេះសិកថៅដេញទៅដោយថ្វីជើងលឿនរហ័សដល់ត្រើយទន្លេហង់ហោ ទាន់សេះប៊ុនធីរ គួនអ៊ូក៏លើកដាវកាប់ត្រូវប៊ុនធីរធ្លាក់ពីលើសេះស្លាប់ ។ ចូចូនៅលើកំពូលភ្នំក្រឡេកឃើញ ក៏ឲ្យទាហានដេញកាប់សម្លាប់កងទ័ពប៊ុនធីរស្លាប់ជាច្រើន ទាហានដែលសល់ពីស្លាប់ក៏រត់បែកខ្ចាត់ខ្ចាយអស់ទៅ ស្បៀងនឹងគ្រឿងសស្ត្រាវុធដែលមាននៅទីនោះប៉ុន្មានក៏បានមកទាហានចូចូទាំងអស់ ។

ឯឡៅពីលើកទាហាន ៣ ម៉ឺន ជាទ័ពណ្ណូមកពីក្រោយប៊ុនធីរ ទៅមិនទាន់ឆ្លងទន្លេផង ទទួលជួបប្រទះនឹងទាហានប៊ុនធីរដែលបែកខ្ញែកមកនិយាយប្រាប់ឡៅពីថា មានសេនាចូចូម្នាក់មុខក្រហមពុកមាត់វែងសម្លាប់ប៊ុនធីរស្លាប់ទៀតទៅហើយ ។ ឡៅពីឮដូច្នោះក៏ភ័យស្លុតចិត្តខំបរសេះស្រូតទៅដល់មាត់ទន្លេជាយព្រៃ ក្រឡេកទៅឃើញកងទ័ពត្រើយម្ខាងស្គាល់ជាទាហានចូចូ តែរកមើលមិនឃើញខ្លួនគួនអ៊ូសោះ ឃើញតែទង់ជ័យសរសេរឈ្មោះថាគួនអ៊ូ ឡៅពីក៏មានចិត្តត្រេកអរច្រើន តែក្នុងចិត្តគិតថា "គួនអ៊ូប្អូនអញនៅៗនោះទេឬ" ប្រឹងទឹងចាំមើលឲ្យឃើញខ្លួនគួនអ៊ូ ទទួលទាហានចូចូចុះទូកឆ្លងមក ឡៅពីក៏ភ័យណាស់នាំទាហានខ្លួនថយក្រោយមកវិញ ។

ឯទាហានប៊ុនធីរដែលបែកមកនោះវិញ ក៏នាំយកសេចក្ដីទៅប្រាប់កួតៅនឹងស៊ុមជួយថា ទាហានចូចូមុខក្រហមពុកមាត់វែងឈ្មោះគួនអ៊ូសម្លាប់ប៊ុនធីរស្លាប់ទៅទៀតហើយ ។ កួតៅនឹងស៊ុមជួយក៏នាំរឿងនោះ

ទៅជំរាបអ៊ួនសៀវគ្រប់ប្រការ ។ អ៊ួនសៀវបានឮដូច្នោះខឹងណាស់ក៏ជេរទៀវតីថា អាទៀវតីត្រចៀកយារ! វាក្លួនឲ្យប្អូនវាមកសម្លាប់សេនាឯករបស់យើងដល់ ២ នាក់ ។ ទទួលទៀវតីចូលមកដល់ អ៊ួនសៀវបង្គាប់ឲ្យចាប់ទៀវតីទៅសម្លាប់ ។

ទៀវតីសួរថា ខ្ញុំបាទមានទោសទាស់ខុសពីអ្វី បានជាលោកឲ្យចាប់ខ្លួនខ្ញុំបាទទៅសម្លាប់ដូច្នេះ ? ។ អ៊ួនសៀវតបថា កាលគ្រាមុនៈយើងក៏បានលើកទោសម្ដងទៅហើយ ឥឡូវខ្លួនក្លួនឲ្យប្អូនរបស់ខ្លួនមកសម្លាប់សេនាឯករបស់យើងស្លាប់ម្នាក់ទៅទៀត ហេតុម្ដេចខ្លួនថាមិនមានទោស? ។ ទៀវតីថា "បើទុកជាដូច្នោះក្ដី សូមឲ្យខ្ញុំបាទជំរាបសេចក្ដីឲ្យលោកជ្រាប១ ខសិន រួចសឹមសម្លាប់ខ្ញុំបាទចុះ" ហើយជំរាបថា "អំពីមុននោះ ប្អូនមានចិត្តស្ញើសនឹងខ្ញុំបាទជាច្រើន គិតនឹងសម្លាប់ខ្ញុំបាទចោលចេញ ឥឡូវដឹងថា ខ្ញុំបាទមកសំណាក់ជ្រកកោននៅនឹងលោកក៏ជាកំឡាំងគិតការគេទៅទៀត ប្អូនក៏ក្លួនប្រើគួនអ៊ូមកសម្លាប់សេនាលោកចេញ បើលោកជ្រាបហើយ គង់ខឹងនឹងខ្ញុំបាទ ឧបមាដូចប្អូនខ្ចីដៃលោកឲ្យសម្លាប់ខ្ញុំបាទ គួនអ៊ូនោះប្រាកដជាមិនបានដឹងថា ខ្ញុំបាទមកជ្រកកោននៅនឹងលោកទេ ទើបសុំបេកអាសាប្អូន មកសម្លាប់សេនាឯករបស់លោកចេញ បើខ្ញុំបាទមានសំបុត្រទៅប្រាប់គួនអ៊ូ ៗ ដឹងហើយក៏នឹងចូលមករកខ្ញុំបាទ នឹងបានជួយមកធ្វើការជាកំឡាំងលោកតទៅ ដែលលោកខូចសេនាឯក ២ នាក់នោះ ឧបមាបីដូចជាខូចប្រើស ២ តួទៅវិញ ។

អ៊ួនសៀវបានស្ដាប់ដូច្នោះ ក៏ត្រឡប់ចិត្តគិតឃើញត្រូវ មានអំណរ

ណាស់ និយាយទៅនឹងស៊ុមផ្លួយគ្រូគៅថា "ខ្លួនអ្នកទាំង ២ គិតគប់គ្នាមកញុះញង់ឲ្យយើងសម្លាប់ឡេវតី ដែលមានសតិបញ្ញាទៀងត្រង់នឹងផែនដីនោះ ឲ្យមនុស្សទាំងពួងដឹងឮហើយក៏នឹងគរហាននិន្ទាដល់យើង" ថាហើយក៏បណ្ដេញស៊ុមផ្លួយនឹងគ្រូគៅចេញទៅ ហើយអញ្ជើញឡេវតីមកអង្គុយនិយាយថា បើយើងបានគួនអ៊ូមកទុក ក៏នឹងល្អជាងម៉ាន់លៀងនឹងប៊ុនធីវ ១០ ស្ទួនទៅទៀត ។ ឡេវតីក៏ធ្វើសំបុត្រផ្ញើទៅឲ្យគួនអ៊ូហើយជូនទៅឲ្យអ៊ួនសៀវមើល អ៊ួនសៀវក៏ទទួលយកសំបុត្រនោះមកមើល ហើយចាត់មនុស្សឲ្យនាំសំបុត្រទៅឲ្យគួនអ៊ូនោះ តែមិនមាននរណាហ៊ានទទួលយកអាសាទៅឲ្យសោះ ។ វេលានោះ អ៊ួនសៀវក៏ថយកងទ័ពត្រឡប់ទៅតាំងនៅតំបន់ប៊ូអៀង នាយទាហានក៏តាំងបន្ទាយរាយកងទ័ពចុះទៅ ចម្ងាយផ្លូវប្រហែល ៥០០ សិន (២០ គ.ម.) ឲ្យត្រួតត្រាក្សាបន្ទាយទុកឲ្យមាំមួនមិនទាន់ឲ្យចេញច្បាំងនឹងកងទ័ពចូឆូ ។

ឯចូឆូក៏ឲ្យតាំងបន្ទាយនៅតំបន់គួគរ លុះអ៊ួនសៀវមិនលើកមកច្បាំងសោះ ចូឆូក៏ចាត់ឲ្យហែហ្គូទុនត្រួតត្រាក្សាទាហានក្នុងបន្ទាយ ចូឆូឯងក៏នាំគួនអ៊ូលើកកងទ័ពត្រឡប់ចូលទៅក្រុងហ៊ូតោវិញ លុះដល់ហើយក៏ឲ្យតែងតុលៀងភោជនាហារ ឲ្យគួនអ៊ូនឹងសេនាទាហានទាំងពួងបរិភោគ ។ ចូឆូក៏និយាយនឹងលីយ៉ាយថា ដែលយើងឲ្យកងឡាំលៀងលើកទៅជាកងមុខនោះ នរណាក៏មិនបានដឹងគំនិតយើងជាកលសឹក បានជាអ្នកខ្លះមកនិយាយទទឹងទាស់នឹងយើង មានតែស៊ុនហ៊ីម្នាក់ទេ ដែលអាចដឹងគំនិតយើងបាន ។ ទាហានទាំងពួងក៏សរសើរតម្រិះប្រាជ្ញាចូឆូថា លោកមាន

ប្រាជ្ញាក៏នឹងរក្សកលសឹកសង្គ្រាម នឹងរកនរណាប្រៀបផ្ទឹមគ្មានឡើយ ។

ខណៈនោះ ទទួលមានបំរើសេះកាន់សំបុត្រមកពីការរាជការមកជូនចូឆ្ងថា ចៅហ្វាយដែលឲ្យរក្សាស្រុកយីឡាំប៉ឹងមកថា មានមេចោរ ២ នាក់ឈ្មោះឡៅផេក ១ កុងតៅ ១ លើកពួកម៉ាកមកជាច្រើន ដើរកាត់ត្បាតធ្វើទុក្ខបុកម្នេញអាណាប្រជានុកស្រុកឯអាណាខេត្តយីឡាំ ចៅហ្វាយលើកទាហានទៅបង្ក្រាបជាច្រើនគ្រា ឃើញលើសកំឡាំងនឹងការពារពុំបាន ។ ជាបកសំបុត្រមកសុំកងទ័ពឲ្យលើកទៅជួយ ។

គួនអ៊ូឮដូច្នោះក៏ដំរាបចូឆ្ងថា ដែលពួកចោរធ្វើទុច្ចរិតប្រព្រឹត្តអាក្រក់ដូច្នេះ ខ្ញុំបាទសុំយកអាសាលើកទាហានទៅប្រាប់ប្រាមឲ្យរាបទាបឲ្យបាន ។ ចូឆ្ងឆ្លើយថា អ្នកទើបនឹងមកពីធ្វើការសង្គ្រាមកំពុងនឿយហត់នៅឡើយ គុណបំណាច់របស់អ្នកដែលគាប់ប្រសើរក៏ខ្ញុំមិនទាន់បានទូលស្នើសុំឲ្យអ្នក ដែលអ្នកនឹងសុំយកអាសាទៅបង្ក្រាបចោរវេលានេះទៀតក៏មិនគួរ ។ គួនអ៊ូឆ្លើយថា ខ្លួនខ្ញុំបាទនេះបើឈប់នៅស្ងៀមមិនធ្វើការសង្គ្រាមក៏រមែងឈឺស្កាត់ មហាឧបកជប់រមេត្តាបើកឲ្យខ្ញុំបាទចេញទៅធ្វើការសឹកចុះ ទើបនឹងបានសេចក្តីសប្បាយ ។ ចូឆ្ងថា "បើអ្នកនឹងចង់ទៅធ្វើការសឹកក៏តាមចិត្តចុះ ដែលយើងថាដូច្នេះព្រោះមានចិត្តប្រណី" ហើយចូឆ្ងក៏កេណ្ឌទាហានឲ្យគួនអ៊ូ ៥ ម៉ឺន ឲ្យអ៊ីកឹមនឹងង៉ាក់ជិនអមទៅផង ។ គួនអ៊ូ, អ៊ុកឹម, ង៉ាក់ជិនក៏លាចូឆ្ងលើកទ័ពចេញទៅ ។

ស៊ុនហ៊ុកចូលទៅជំរាបចូឆ្ងថា ដែលលោកប្រើឲ្យគួនអ៊ូលើកទ័ពចេញទៅនោះ ខ្ញុំបាទយល់ថា គួនអ៊ូនឹងស៊ើបសួរដំណឹងរកឡៅពី បើ

ដឹងថាទៀតតើទៅទីណា គូនអ៊ីមុខជាទៅពុំខាន ។ ចូច្នូតបថា យើងបានជាបើកមាត់ព្រមឲ្យគេទៅហើយ វេលានេះបើនឹងប្រែពាក្យសំដីឲ្យហៅត្រឡប់មកវិញនោះ ឃើញថាមិនគួរសមសោះឡើយ, ដល់គេទៅមុខយើងនឹងលែងប្រើឲ្យទៅហើយ ។

ឯគូនអ៊ីកាលលើកទ័ពចេញទៅនោះ បានទៅដល់ស្រុកយើឡាំឲ្យបោះទ័ពចាប់ផ្ដើមឡាយជាមាំមួន លុះពេលកណ្ដាលអាធ្រាត្រស្ងាត់ កងក្រវែលចាប់បានឈ្លើយ ២ នាក់ ឃុំនាំយកខ្លួនជូនគូនអ៊ីៗ ក្រឡេកឃើញស៊ីនខៀនក៏នឹកតែក្នុងចិត្តថា “ស៊ីនខៀនទៅនៅទីណា បានជាឲ្យគេចាប់មកបាន” គូនអ៊ីក៏បណ្ដេញមនុស្សទាំងអស់ឲ្យដើរទៅខាងក្រៅ ទើបខ្សឹបសួរស៊ីនខៀនថា តាំងពីយើងបែកគ្នាទីងទ័ពចូច្នេះទៅគ្រានោះ យើងទាំងអស់គ្នាក៏ព្រាត់ប្រាសទិសទៅតែរៀងខ្លួន ឥឡូវអ្នកមកនៅឯណា បានជាគេចាប់បាន? ។

ស៊ីនខៀនតបថា កាលយើងបែកគ្នាទៅនោះក៏ព្រាត់ខ្ចាត់ពីឡៀតពី ខ្ញុំមកអាស្រ័យនៅនឹងឡៀវផេកក្នុងស្រុកយើឡាំ” រួចស៊ីនខៀនក៏សួរគូនអ៊ីវិញថា ហេតុម្ដេចបានជាអ្នកទៅនៅទីងចូច្នេះ? ចុះបងថ្លៃអ្នកទាំង ២ នោះជាសុខសប្បាយតាមធម្មតាទេឬ? ។

(មានត)

ដំណើរតាមខ្យល់ក្នុងកន្តារ:

# លោក ផេង-ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(ត-ចប់)

---

រួចតមក នាងនឹកឃើញកាលអ៊ីស្មាអ៊ីលយ៉ាងឃាវឃាន ហ៊ានសំឡាប់នាយទាហានរង្គូគី ដើម្បីជួយការពារខ្លួននាង ហើយអ៊ីស្មាអ៊ីលចាប់កៀកនាងដើរសំដៅផ្ទះឪពុក កាលដែលអ៊ីស្មាអ៊ីលជញ្ជក់មាត់នាង ៗ មានតម្រេកក្នុងការជប់ថើបជាពន់ពេក ៗ ឱរឿងទាំងនេះ ឥឡូវឆ្ងាយហើយ ៗ

* * *

ពួកមនុស្សនាំគ្នាដើរតែច ៗ តាមផ្លូវទៅ ៗ គឺដើរក្នុងពេល ឡើងផុតខ្ពាប់លើរណារលចាំងថ្ងៃត្រចះ ៗ មើលជាប់កន្ទុយភ្នែក ៗ ឥឡូវពួកបកចកេកដួចជាចិតទៅជិតក្បែរប្រទេសដែលច្បាំង ទើបតែទន្ទ្រានរកកន់ហើយថ្មី ៗ ៗ គេកាន់តែចូលទៅជិតមាត់សមុទ្រ ដែលមានភូមិជាប់បន្តគ្នាប្រគប ដោយផ្ទះដំនាន់បុរាណ ដំបូលរាប ប្រក់ក្បឿល ប្រក់ស្លឹក ប្រក់ដីស្អិត គ្រាន់តែធ្លាដើរលើលានព្រុស្ករក្រិបក្រៀប ៗ ផ្ទះកន្ទុបទាំងនោះស្រុតរលំដោយទឹកភ្លៀង កំទេចកំទីរះនាំប្រគរលើគ្នា ក្បែរខ្ទមថ្មី ៗ ដែលអ្នកស្រុកទើបនឹងធ្វើយ៉ាងប្រញាប់ឲ្យតែបាននៅ ៗ

ភូមិធំនេះ ត្រូវជាកន្លែងសមស្ថាន គឺជានិគមដែលតាម៉ាព្រេកអេល-យ៉ាឌី បំណាំងទឹងមកលក់ទំនិញ ជាកន្លែងលក់ដូរហើយបានចំណេញ

ប្រែទផង ៗ ឥឡូវទីនេះ ឃើញតែសេចក្ដីទុក្ខនឹងសេចក្ដីអន្តរាយ ៗ ផ្ទះ លក់ទំនិញទាំងឡាយដែលត្រូវគាំភ្លើងធំកំទេចហើយនេះ រលំអស់រលីង ផ្ទានផ្ទាង ត្រូវភ្លើងពេលគេរជាគំនរឈើសុទ្ធតែឆ្យងដែលកណ្ដៀវកំពុង ស៊ី ៗ កងរពងតែប៉ុន្មានម៉ោង អស់ទាំងសំពត់អម្បោះ សំពត់សូត្រ ស្បែកនឹងគ្រឿងប្រដាប់ប្រដាស្បៀងអាហារផ្សេង ៗ នេះទៅជាផេះ ហើយមនុស្សដែលរស់នៅស្រុកអំពាវនាវ យំសោកស្ដាយទ្រព្យសម្បត្តិទ្រព្យ ដែលវិនាស ៗ

ឥឡូវយប់ហើយ នាងឡីឡាដេកមិនលក់ បេះតែមើរមមាល ៗ នាងឃើញអ៊ីស្មាអ៊ីលដួលដេកស្លាប់កណ្ដាលទីវាល មានពស់ក្អែបពេមព័ទ្ធជុំវិញ ដូនកាលនាងឃើញគេនៅកណ្ដាលសមរភូមិ ពាសពេញដោយមនុស្សស្លាប់ រូបបទិបមកគេហាក់ដូចជាស្លាប់ដែរ ប៉ុន្តែគេលោស្ទុះក្រោកឡើង នាងឃើញទ្រូងគេប្រហោង ឈាមហូរចេញពីបេះដូង ៗ រូបគេក៏ត្រឡប់ដួលផ្កាប់មុខទៅវិញ ស្រែកហៅថា: ឡីឡា! ៗ

យល់សប្ដិអាក្រក់នេះធ្វើឲ្យនាងភ្ញាក់ឡើងញ័រអស់ទាំងខ្លួន ហើយកង សំណាល់ពេលទាំងប៉ុន្មាន នាងមានតែសេចក្ដីទុក្ខព្រួយរកទីបំផុតគ្មាន ៗ

មានព្រឹកមួយ ពួកបរាបរក៏កំពុងតែប្រុងប្រៀប នឹងធ្វើដំណើរចេញចាកភូមិឃាដាំយ៉ាដ នាងក្រមុំបានឃើញមនុស្សម្នាក់ជិះអូដ្ឋបរតាមផ្លូវ ៗ លុះមនុស្សនោះមកជិតនៅប្រហែលពីរបីម៉ែត្រ នាងឡីឡាស្រែកដោយសប្បាយថា:

- គាឡិប!

គឺជាតាឡិបប្រាកដមែន ៗ គាត់នេះចេះតែដើរផ្ដេសផ្ដាស ជួនកាលគាត់ទៅនៅទីផ្សារអ្នកដើរលេស ជួយលក់ទំនិញ ជួយមើលថែសត្វពាហនៈឲ្យគេ យកតែបាយស៊ី ៗ នាងក្រមុំស្ទុះសំដៅដំណាលក្ដិក ៗ ស្រែកហៅថា:

– ឡូឡា!

លុះឲ្យសត្វដំនិះលុតជង្គង់រួចហើយ គាត់ក៏ចុះមកដី ៗ

នាងឡូឡារៀបរាប់ប្រាប់តាឡិបអំពីព្រឹត្តិការណ៍ ដែលកើតមានទៅឯក្រុងកាសិ-កាពប៊ូលី ខាងក្រោយការបាត់បោលរបស់គាត់ ៗ តាឡិបក៏មិនសូវជឿងឿលប៉ុន្មានគាត់និយាយថា:

– ខ្ញុំដឹងដែរ រឿងអស់នោះ ៗ ខ្យល់ក្នុងគន្ធារៈនាំដំណឹងទាំងប៉ុន្មានមកប្រាប់ខ្ញុំគ្មានសល់ ៗ

នាងឡូឡាអត់ទ្រាំពុំបាន ក៏សួរថា:

– ចុះតាដឹងឬទេ អ៊ីស្មាអ៊ីលដូចម្ដេចទៅ?

តាឡិបមុខឡើងខ្មៅ ហើយប្រាប់ថា:

– ណ្ហើយកុំគិត! អ៊ីស្មាអ៊ីលចៅហ្វាយខ្ញុំ ជាប់ជាអ្នកទោសរបស់ជាតិតួគីក្នុងបន្ទាយកសាព្រមុិតហើយ ៗ លោកមានសេចក្ដីអន្តរាយធំ . . . ៗ

ពាក្យនោះ ឡូឡាងើងងោង ៗ ដើម្បីកុំឲ្យដួល នាងស្ទុះទៅតោងបង្កៀអូដ្ឋ ប៉ុន្តែការណ៍នេះក៏អន់ខ្សោយ ហើយបាត់ទៅវិញភ្លាម គំនិតដែលគិតឃើញថា គូសង្សារដល់នូវសេចក្ដីអន្តរាយស្លាប់ខ្លួន ធ្វើឲ្យនាងមានកំឡាំងក្លាហាន ៗ នាងនិយាយដោយសំដីម៉ឺងម៉ាត់ថា.

– ត្រូវតែជួយសង្គ្រោះអ៊ីស្មាអ៊ីល ចូរយើងទៅឯបន្ទាយកស្បាម៉ុត ។

តាឡិបដែលជាមនុស្សមិនសូវខ្លាចស្លាប់ សំឡឹងមុខនាងក្រមុំ គាត់ពិនិត្យទៅឃើញថាការសម្រេចនៃនាងឥតកែប្រែ រួចគាត់សំឡឹងមើលជើងមេឃម្ដង ៗ បើទៅតាមផ្លូវដែលគាត់ស្គាល់ ជនទាំងពីរនឹងអាចទៅដល់បន្ទាយកស្បាម៉ុតជោគជ័យ ហើយបានឆាប់ផង ៗ

តាឡិបឆ្លើយថា:

– គំនិតហ្នឹងល្អហើយ ! យើងចេញទៅយប់នេះ !

រួចគាត់ទៅធ្វើការរបស់លោកតាម៉ាត្រេក ។

វេលាល្ងាច កាលដែលពួកចពចរក៏ឈប់សម្រាក លុះព្រឹកស្អែកឡីឡាចូលទៅសំឡឹងមើលម្ដាយនាងកំពុងដេកលក់ ដោយមេត្រីចិត្តរួចត្រឡប់មកជួបនឹងតាឡិបវិញ ។ ជនទាំងពីរធ្វើដំណើរចេញទៅដោយស្ងៀមស្ងាត់សំដៅបន្ទាយកស្បាម៉ុត ។

*

* *

# រឿងបង្ហើយ

នាយទាហានរឹងម្នាក់ ចូលមកដោយស្ងៀមស្ងាត់ ក្នុងគុកបន្ទប់លេខ ២ ដែលគេដាក់លោកអនុសេនីយឯក អ៊ីស្មាអ៊ីលបេន-អៃយ៉ាដ ។ នាយទាហានរឹងគំនាប់ដាក់ជើងទាំងពីរត្រឹមគ្នា ហើយប្រាប់ថា:

– លោកវរសេនីយឯកមានប្រសាសន៍អញ្ជើញលោក ។

អ៊ីស្មាអ៊ីលក្រោកឡើងទាំងពិបាក គេឥតសង្ឃឹមថានឹងបានរស់តទៅទៀតឡើយ ។ មុខគេប្រែកបដោយការហត់ហេវ អស់កំឡាំងនឹងសេចក្ដី

ទុក្ខព្រួយជាពន់ពេក ប៉ុន្តែគេមានសេចក្ដីសម្រេចយ៉ាងម៉ឺងម៉ាត់ ព្រមទទួលមរណភាពដោយក្លាហាន ។ ឱ! ប្រសិនបើគេបានឃើញមុខនាងឡូឡាមុននឹងផ្ដើមដំណើរដ៏ធំនេះ ម្ល៉េះសមនឹងស្រាកទុក្ខបានខ្លះ ។

នាងឡូឡាគឺជាបុប្ផា ជាការរីកពេញក្នុងជីវភាពរបស់គេ នាងឡូឡាមានទឹកអម្រឹតដែលអាចស្រោចបុះក្នុងដួងព្រលឹងរបស់គេ ។ ឱ! មិនត្រូវនឹកសោះឡើងនេះ ព្រោះជាការសន្សឹមស្រមើស្រមៃឥតបានប្រយោជន៍ ។ បំណែកនាងក្រមុំសត់គោតយ៉ាក មិនដឹងជាទ្រាំសោកយ៉ាងណាទេ នៅឯផ្ទះថ្ម កណ្ដាលពពួកដើមត្នោតស្ងួតបៃតងនាក្រុងកាំសិ - កាពប៊ូលី ។

*
* *

"សេចក្ដីស្នេហារបស់ស្ត្រី គឺជាម្លប់នៃដើមឈើលើភ្លខ្សាច់ ...

"ឱដើមត្នោតលៃអើយ! សូមជួយខ្សាច់ត្រង់កន្លែងកប់ខ្មោច កុំសង្កត់ឲ្យធ្ងន់ពេកលើរូបសនៃអ្នក ..." ។

លុះចេញពីបន្ទប់ងងឹតមក អ៊ីស្មាអ៊ីលប៉ប្រិចភ្នែកដោយប្រទះនឹងពន្លឺថ្ងៃ ។ ព្រះអាទិត្យដែលតែងតែធ្វើគ្រប់វត្ថុទាំងពួងឲ្យបំរើន ក្នុងទីនេះគង់បាំងរស្មីទៅលើទស្សនាការខាងសេចក្ដីស្លាប់ ។ សង្គ្រាម? ក៏យោបកនាំយកស្ករពាងដែល ៗ នៃកាំភ្លើងពីទិសទក្សិណមក ។

ទាហានបួននាក់ដើរព័ទ្ធអ៊ីស្មាអ៊ីល ហើយនាយទាហានរង់ជាអ្នកចាត់ការនាំបណ្ដើរតាមច្រក រួចមកដល់កន្លែងយាម ក្នុងទីបំផុត មកដល់ជើងជណ្ដើរបង្អៀតមួយ ដែលនាំឡើងទៅលើថ្នាក់ប៉មជាន់ខ្ពស់នៃបន្ទាយ នៅត្រង់កន្លែងនេះមានទង់ជាតិពណ៌ក្រហម ដេកភ្លែកព្រាក់ ពយផ្កា

មាស របស់ជាតិតួរគីបក់រ៉េច ។ ត្រង់មន្ទីរនោះហើយដែលតុលាការ ចម្បាំងហៅកូនប្រុសនៃលោកតាកាអ៊ុដអោយាដមកជំនុំជំរះ ។

គឺជាបន្ទប់មួយដំបូលក្រឡូម ជញ្ជាំងថ្មខៅ មានរូបព្រះចៅសុលតង់ តាំងលំអនៅនោះ ។ មាននាយទាហានប្រាំនាក់អង្គុយលើកៅអីដែល ដាក់នៅព័ទ្ធជុំវិញតុឈើខ្មៅមួយធំ ។ លោកវរសេនីយហ្វារេឌីន ជា មេទ័ពប្រចាំបន្ទាយជាអធិបតីនៃការជំនុំជំរះ លោកអង្គុយយ៉ាងស្រួលតែ ម្នាក់ឯងលើកៅអីល្អយ៉ាងត្រឹមត្រូវ ។ នៅខាងស្តាំនិងខាងឆ្វេង មាន លោកអនុសេនីយឯកពីរនាក់ជាចៅក្រមរង ។ នៅចុងតុសងខាងមាន អនុសេនីយទោម្នាក់កាន់ការជាក្រឡាបញ្ជី ម្នាក់ទៀតកាន់ការជាកូម៉ីស្សែរ នៃរដ្ឋាភិបាលសម្រាប់សូត្រពាក្យកត់ចម្លើយ ។ លុះអ្នកទោសចូលដល់ នាយទាហានរង់និងពួកទាហានថយចេញភ្លាម តាមសញ្ញារបស់លោក អធិបតី ។

អ៊ីស្មាអ៊ីលបេន អៃយ៉ាដនៅតែម្នាក់ឯងចំពោះមុខចៅក្រម រូបសំនួរ ក៏ចាប់ផ្ដើមឡើង ។ តាមការណ៍ពិត គេហៅមកសួរយកតែនាមទេ ចៅក្រមគ្រប់គ្នាមានការសម្រេចស្រេចអស់ហើយ ។ គេត្រូវធ្វើតាម បទបញ្ជានៃកុងស្តង់ទីណុប គឺសម្រេចទោសត្របំបាត់ជីវិតមនុស្សនេះ ចោលចេញ ។

ចំណែកអ៊ីស្មាអ៊ីលបេន - អៃយ៉ាដនៅតែកាន់អាកប្បកិរិយាស្ងៀម ស្ងាត់ដដែល ។ គេខ្ពើមជាតិតួរគីរហូតដល់មិនព្រមតវ៉ាដើម្បីការពារ ខ្លួនអំពីការចោទបំពានគ្មានយុត្តិធម៌ ។

លុះឃើញថាគ្មានយកចម្លើយអ្វីមួយបានពីអ្នកទោសនោះ ហើយគ្មានបំណងនឹងបន្តសម័យប្រជុំទៅទៀត លោកវរសេនីយឯកប្រាប់នាយទាហានដែលកាន់មុខងារជាក្រឡាបញ្ជីឲ្យសម្រេចសេចក្តី ។

ក្រឡាបញ្ជីនេះគឺជាទាហានចាស់ម្នាក់ ពូជអម្បូរជាន់ទាបដែលអាពុកម្តាយធ្លាប់ធ្វើជាអ្នកបំរើរបស់ពួកព្រះវង្សមានសម្បត្តិ ម្ល៉ោះហើយលោកនេះមានគំនុំតែម្យ៉ាងចំពោះកូននៃព្រះញាតិវង្សទាំងនោះ ទោះបីជាអាក់ប្ញូត្រគឹក៏ដោយ ។ ត្រង់រូបអ៊ីសាអ៊ុលជានាយទាហាន លោកនេះមិនចោទប្រកាន់ក្នុងបទមនុស្សឃាតនឹងការក្បត់ប៉ុន្មានឡើយ ការណ៍ដែលលោកចោទប្រកាន់នោះ ចំពោះត្រង់តែអ៊ីសាអ៊ុលជាកូននៃលោកតាកាអ៊ុជប៉ុណ្ណោះ គឺជាវណ្ណៈនៃព្រះវង្សក្នុងសាសនាឥស្លាមដែលមានអាការខាងក្រៅជាអ្នកចុះចូល តែចិត្តខាងក្នុងជាសត្រូវយ៉ាងមាំនឹងរដ្ឋាភិបាលតួរគី ។ លោកស្តាយដែរ មិនគួរកាត់ទោសដ៏ធ្ងន់ដល់ប៉ុណ្ណោះឡើយ រួចលោកសម្រេចសេចក្តីក្នុងសាលក្រមថា អ៊ីសាអ៊ុលជាប់ទោសយ៉ាងធ្ងន់ក្នុងបទមនុស្សឃាតនឹងការក្បត់ ។ ហើយលោកនិយាយថា: ខ្ញុំកាត់ទោសឲ្យក្រិដ្ឋជាទន្ទាស់បំផុត ចំពោះរូបអនុសេនីយឯកអ៊ីសាអ៊ុល បេន អៃយ៉ាដ ។

អ៊ីសាអ៊ុលនៅតែស្ងៀម ស្តាប់ពាក្យគេជំនុំជំរះ ដូចជាស្តាប់សំរែកផ្គរព្រួសប្រទាំគ្នា គ្មានយកចិត្តទុកដាក់ប្រុងនឹងស្តាប់ប៉ុន្មាន ។ ក្នុងពេលដែលនាយទាហានអយ្យការចោទ កំពុងតែរៀបនឹងគេៗ គិតតែនឹកទៅផ្ទះថ្មស មានដុតបង្ហុយធូបក្រស្នា នៅតាមច្រករបៀងប្រកបដោយក្បូរក្បាច់រចនា, ទីលានក្រាលថ្មកែវ, កន្លែងងូតទឹកពាបក់រីដ៏ត្រជាក់

ក្រុមស្ត្រីបរិវារ ដែលសូរសំឡេងនាងឡីឡាដ៏បរិសុទ្ធ យ៉ាងស្រួយស្រិប លាន់ឮឡើងក្នុងអាកាស មុខនាងស្រស់ប៉ប្រិមដែលអនុស្សាវរីយ៍អាចនាំរំលត់នូវសេចក្តីទុក្ខលំបាកបានខ្លះ ។

សូរគំហកនៃលោកវរសេនីយឯកពញាក់គេអំពីការស្រឡុងយ៉ាងស្រួលនេះ:

- នៃ! លោកឮលោកអនុសេនីយទោជាអយ្យការហោឡូប្តូរទេ! លោកជាអ្នកក្បត់សាសន៍យើង! លោកមិនសមធ្វើជានាយទាហានតួរគីឡើយ! ។

ដោយឮសំដីនេះ អ៊ីស្មាអ៊ីលហាក់ដូចជាភ្ញាក់ចាកការព្រងើយកន្តើយ ។ គេងើបក្បាលឡើងភ្លាម សំឡឹងពេបជ្រាយដោយអាការមើលងាយចំពោះមនុស្សទាំងប៉ុន្មានដែលធ្វើមុខងារជាចៅក្រមខ្លួន ហើយគេស្រែកដោយសំឡេងយ៉ាងក្រអៅ ពេញដោយការក្រអឺតក្នុងជាតិនិងសេចក្តីស្នេហាចំពោះមាតុភូមិថា:

- ខ្ញុំមិនមែនជាតិតួរគី! ខ្ញុំជាជាតិអារ៉ាប់!

លោកវរសេនីយ៍ឯកស្ទុះក្រោកឡើង ។ កំហឹងធ្វើមុខលោកដែលក្រហមស្រាប់ឲ្យរឹតតែក្រហមលើសលប់ទៅទៀត ។ លោកមានវាចាថា:

- អ៊ីស្មាអ៊ីលបេន-អៃយ៉ាដ! លោកទើបតែបង្ហាញឲ្យឃើញនូវការណ៍ដែលត្រូវតែឃុំឃាំងលោកទុកដល់មរណភាព ។ តុលាការនឹងថយចេញដើម្បីសម្រេចនូវជោគវាសនារបស់លោក ។ ម្យ៉ាងទៀត លោកត្រូវប្រយ័ត្នដល់យុត្តិធម៌នៃ... ។

លោកនិយាយមិនទាន់ចាំងផុតសេចក្ដី ស្រាប់តែស្នូរកាំភ្លើងធំយ៉ាងអស្ចារ្យលាន់ឮស្ទើរកក្រើកទាំងបន្ទាយ ។ មានគ្រាប់បែកអ៊ុតាលីមួយធ្លាក់មកលើទ្វារបន្ទាយ ។

*

* *

ពួកទាហានភ្ញាក់ក្រោកឡើងទាំងអស់គ្នា ។ តើមានរឿងហេតុដូចម្ដេច? សត្រូវមកជិតដល់ហើយឬ? ទ្វារបន្ទប់បើកភ្លែត មាននាយទាហានម្នាក់ដែលនៅក្នុងមន្ទីរចាត់ការធំចូលមកដល់ ប្រឡាក់ដីស្រម៉ក បែកញើសជោគ ។ គេឈរស្ងៀមតម្រៀបជើងត្រឹមគ្នា ហើយហុចសំបុត្រជូនទៅលោកមេទ័ពកស្យាមុតិ ។

លោកហ្វារេឌីនចាប់វែនតាពាក់ ហែកសំបុត្រដែលផ្ញើមកពីប៉ុយរ៉ូ ចាត់ការធំជាធុក៏ហើយមើលភ្លាមៗ ។ ក្នុងសំបុត្រនោះមានសេចក្ដីដូចតទៅនេះ ៖

> ទប់ទីងក្បាលវ៉ាតនៃបប្លាមិត្រមិនបានទេ ។
> ត្រូវនាំទ័ពចេញឲ្យរហ័ស ។
>
> វរសេនីយ៍ឯក អ៊ុស្មាន់-បី

លោកមេទ័ពហុចសារឲ្យទៅនាយទាហានឯទៀតៗមើល រួចលោកបង្គាប់អ្នកនាំសំបុត្រឲ្យវិលត្រឡប់ទៅវិញ ។ លោកវរសេនីយ៍ឯកហៅនាយទាហានវេនទីងអ្នកយាមទ្វារឲ្យចូលមក ហើយនិយាយប្រាប់ ចន្ទុល

ចំអុីស្មាអុីលថា: “មនុស្សនេះឈប់ធ្វើជានាយទាហានហើយ” ក្នុងពេលនោះលោកបោចបង់ប៉ាក់សែសយមាស ដែលភ្ជាប់នៅលើស្មា ជាយសស័ក្តិសញ្ញា ចេញអំពីឯកសណ្ឋាន គឺជាអ្នកទោសសាមញ្ញ រួចប្រាប់ឲ្យទាហានពីរនាក់នាំគេបណ្តើរចេញទៅក្រៅក្រុង បើគេចង់តែឲ្យបាញ់ចោលភ្លាម ។

រួចលោកមេទ័ពបែរមកចំពោះនាយទាហានទាំងឡាយ ហើយស្រែកជារបៀបរសេទីយ៍ឯកត្តរគឺថា:

– ឥឡូវនេះ ត្រូវដក ដោះខ្លួនថយចេញសិនរៀងខ្លួន!

អុីស្មាអុីល នៅជាប់ចន្លោះទាហានពីរនាក់ ដើរចេញពីបន្ទាយ ។ ជនទាំងបីគ្រាន់ដល់ផ្លូវមួយចង្អៀត ហើយប្រទះនឹងអ្នកស្រុកកិតក័យតក់ស្លុតតេប្រាក់ ។

កាំភ្លើងបាញ់រកស្តាប់អ៊ឺពុក ។ ពួកកងកាំភ្លើងធំបម្រាមត្រូវទៅខាងក្រោយក្នុងកំពិតខាង ពីទួបន្ទាយកស្សាម៉ុត ហើយបាញ់រះបន្ទាយទឹងមិនតែយ៉ុស្សួរព្រួចលាងផ្ទះ ។

អុីស្មាអុីលធ្វើហ៍ មិនរវល់អើពើអំពីគ្រាប់កាំភ្លើងនឹងអំបែងគ្រាប់បែក ដែលរត់ជិតៗខ្លួន តាមកំពែងថ្មប្រឹងតែដើរដោយស្ងៀមស្ងាត់នាកណ្តាលទាហានត្រួតទាំងពីរធ្វើព្រងើយ ។

ទាហានពីរនាក់នេះចំដើរញាប់ជើង លុះដល់ផ្លូវបត់ អុីស្មាអុីលភ្ញាក់ថយក្រោយ ។ គ្រាប់បែកមួយផ្ទុះឡើង លើកគេចោលទៅលើដី ចំណែកបំណែកថ្មនឹងអាចម៍ដីខ្ចាត់ខ្ចាយឡើង ខ្ទាត់ទៅឯអាកាសដង់ងិតមេឃ ។

អ្នកកំឡោះដួលស្ទុកស្ទឹងបាត់ស្មារតីមួយស្របក់ ៗ លុះគេត្រឡប់ដឹងខ្លួនវិញ ហើយក្រោកឡើង គេឃើញទាហានតួរគីទាំងពីរដេកប្រឆាំងឥតដឹងខ្លួន ឯកសណ្ឋានរហែករយ៉ែអស់មានកាយពាសពេញដោយរបួសគួរសែង ៗ ខ្មោចទាហាន ផ្សេងទៀតពេលខ្មៅក្អិល ដេករឹងត្អឹងហាក់ដូចជាសំឡក់មករកគេ ដោយភ្នែកបើកក្រលួងឥតវិញ្ញាណ ៗ នេះគឺពាសនាល្អធ្វើឲ្យគេបានរួចខ្លួន ៗ

អ៊ីស្មាអ៊ីលញញឹមស្ងួតតែម្នាក់ឯង ៗ

ឥឡូវនេះ តើវាល់អ្វី? មិនដឹងជាស្លាប់ដោយគ្រាប់កាំភ្លើងដូចទឹកភ្លៀងត្រង់កន្លែងណា? គេចាប់ដើរតទៅទៀតដោយសេចក្តីក្លាហានឥតកំរើក ដល់ជើងទីនដ៏ដុតក្តៅធ្លួល ទីនដោង ទីនគំនរផ្ទះកំពុងឆេះ ៗ ខ្មោចស្រី - ប្រុស កូនក្មេងដេករដូករណែលគួរឲ្យស្ញើបពេក ៗ ជញ្ជាំងកំពែងរលំខ្ទេចខ្ទី ព្រៃតែសូរសព្ទទំនួញចេញមកពីក្នុងរូង ពីក្នុងផ្ទះបាក់បែក ៗ សូរកាំភ្លើងធំ ព្រលានទំពែងខ្ទាំង ៗ នៅក្បែរមានផ្ទះមួយរលំ អ៊ីស្មាអ៊ីលឃើញទាហានតួរគីមួយក្រុមស្លាប់ដេកតាមធម្មតា ប្រហែលជាកំពុងស៊ីផឹកនៅលើកនហាល បានជាគេឃើញ ខ្លះកាន់ចាន ខ្លះកាន់ក្អម ខ្លះកាន់កាំបិត ទាហានទាំងនោះមើលទៅហាក់ដូចជានៅរស់ ៗ អ៊ីស្មាអ៊ីលខាកស្តោះដាក់ដោយសេចក្តីខ្ពើម ៗ ទីក្រុងទាំងមូលហាក់ដូចជាប្រព្រឹត្តទៅក្នុងភ្លើងប្រល័យកល្ប ៗ

ឥឡូវសូរកាំភ្លើងធំអនថយ មីត្រៃយ៉ើចាប់បាញ់បន្តឡើងទៀត ៗ

ខណៈនោះ អ៊ីស្មាអ៊ីលគិតថា ការចំដើរតាមផ្លូវដើម្បីឲ្យដល់ទី

ពេលនោះ ដែលឯកសណ្ឋានរបស់គេជាសញ្ញាដោយឡែកដល់បច្ចាមិត្ត នេះចំជាពេលសោះ ។ គេក្រាបពួនត្រង់ជង្ហុកមួយ ក្បែរផ្ទះលំ យកដញ្ជូរជាគ្រឿងបាំង ។ នៅខាងក្រោយគេ ប្រហែលពីរ-បីជំហានក្បែរឫសដើមត្នោតមួយ មានអាកប់ម្នាក់ដេកស្តូកនៅនោះ ។ មនុស្សនោះគ្មានសំពត់រុំទេ មានតែអាវទ្រនាប់រហែកស្ទាំ ដែលបង្ហាញឲ្យឃើញប្រហោងមួយប្រហែលត្រូវទីងគ្រាប់កាំភ្លើង ។ អ៊ីស្មាអ៊ីលចូលទៅជិតសពមិនស្គាល់នោះ ហើយសូត្រលំកគុណព្រះអាឡស់ ដើម្បីសម្រាកនៃដួងវិញ្ញាណរបស់មនុស្សកំសត់នោះ តាមសេចក្តីគោរពច្បាប់សម្រាប់ជាតិ ។ លុះធ្វើដូច្នោះហើយ អ៊ីស្មាអ៊ីលនឹកដល់ក្រុងកាស់-កាពប៉ូលី ។ គេនឹកឃើញផ្ទះ ឃើញឪពុក ប្អូនប្រុស នាងឡៀឡា ឧត្តមទាំងប៉ុន្មានដែលគេស្រឡាញ់ពេញអាន ។

ទ ! ប្រសិនបើគេបានរួចរស់ជីវិត !...

ប៉ុន្តែ វាសនារបស់គេទៀងតែត្រូវស្លាប់ទីងមីត្រែយ៉ើរបស់សាសន៍អឺរ៉ុបមិនខាន ដូចគ្នានឹងស្លាប់ដោយគេចង់ឲ្យរដែរ ឆ្ងាយពីសាច់ញាតិកណ្តាលស្រុកគេ ។

ក្នុងពេលនោះ សូរកាំភ្លើងឈប់ឈាន់ពុ ប្រហែលបួន-ប្រាំនាទីរួចមកហើយ ។ បែកខាងក្តុងតូចៗ កាំភ្លើងធំនៅស្ងៀមឈឹង ។ កាំភ្លើងមីត្រែយ៉ើនៅពុសូរផ្ទុះម្តងៗ, អ៊ីស្មាអ៊ីលនឹកថា កាំភ្លើងទាំងនេះបាញ់រះទីពេលដើម្បីឲ្យត្រូវពួករមត ។

ឥឡូវនេះ ប្រហែលជាប៉ុន្មាននាទីមកហើយ គឺជារហស្សភាពដែលស្ថិតនៅលើវត្ថុបាក់បែកទាំងខ្ទេចទាំងឡាយស្ងាប់ប្រែគរលើគ្នា ៗ នៅទីឆ្ងាយឯណោះគេឮតែបញ្ចេញសព្ទសំឡេងជ័យជំនះ ទាំងសេចក្តីរីករាយ ៗ កាំភ្លើងឈប់បាញ់ កិច្ចបំផ្លាញបំពេញរួចអស់ហើយ ៗ គេឃើញក្អែកទាំងគាត់ហើរពីខាងលើគេហស្ថានបាក់បែកទាំងឡាយ ដោយបក់ស្លាបវង្វើលៗស្ងៀមស្ងាត់ ៗ

កូនទីស្ងាត់ជ្រងំ ស្រាប់តែសំឡេងមួយលាន់ឮឡើងភ្លាមថា:

– អ៊ីស្មាអ៊ីល ! ៗ ឮស្នូរស្រែកហៅ អ៊ីស្មាអ៊ីលស្ទុះក្រោកឡើងបែរសំឡឹងឆ្វេងស្តាំ ស្រែកតបវិញថា: ឡូឡា ! ៗ ស្នូរសំឡេងឆ្លើយកាន់គ្នា គេស្ទុះសំដៅរក ៗ – អ៊ីស្មាអ៊ីល ! ៗ – ឡូឡា !

គូរកំសត់ស្ទុះឆ្ពងផ្ទះបាក់បែករៀងខ្លួន លោតរំលងខ្ទេចយ៉ាងប្រញាប់ដើម្បីជួបគ្នា ៗ គេបានទល់មុខគ្នាមួយរំពេច ៗ ជនទាំងពីរមានសរីរកាយរីងរៃគ្រាំងដោយប្រឡាក់រំសេវទាំងធូលី ប៉ុន្តែទោះបីដូច្នោះ គេក៏គង់ប្រែក្លាយទៅជាសប្បាយរីករាយកើត ព្រោះអាស្រ័យកាមតណ្ហា ៗ សេចក្តីសប្បាយពេញចិត្តពេក ធ្វើឲ្យដួងហឫទ័យនៃជនទាំងពីរកំរើកស្ទើរបែក ៗ គេនៅទ្រឹងស្ងៀមមួយស្របក់មិនអាចហាមាត់និយាយថាដូចម្តេច រួចគេនាំគ្នាយំដូចកូនក្មេង ៗ លុះទីបំផុតគេហៅគ្នាទៅវិញទៅមក ៗ សត្វទាំងពីរសោយសង្វារមណ៍យ៉ាងធំរួចថាដូចម្តេចមិនកើត គ្រាន់តែហៅឈ្មោះគ្នាថា: – អ៊ីស្មាអ៊ីល ! ៗ

– ឡីឡា ! ។ រួចគេចាប់ឱបគ្នាទៅវិញទៅមក ។ –ឱ កែវគូសង្សារ ! ។ –ឱ ដួងជីវិតថ្លៃអូន ! អូនឈប់បែកពីរូបបងហើយ ! មាត់និងមាត់ក៏ប៉ះគ្នាភ្លាម . . . !

ឥឡូវនេះ សន្តិសុខដ៏ធំនៃសាយណ្ណសម័យ ចុះគ្របដណ្តប់លើកន្លែងផែនដីត្រង់នោះ គឺជាទីដែលមនុស្សទន់អន់ប្រាជ្ញា ទើបតែនឹងព្រលែងនូវព្រះភ្លើងនិងព្រះអាវុធ ឲ្យដើរពាតត្បាត ហើយនិងធ្វើឈាមឲ្យហូរពាសពេញ ។

ប៉ុន្តែជីវិតរបស់សត្វដែលត្រូវដុះដាល មានកម្លាំងជាងវត្ថុទាំងពួង ជាងការព្រើលដែលនាំឲ្យវិនាស ជាងការព្យាបាទរបស់សត្រូវ ជីវិតនោះធ្វើផ្កា គឺសេចក្តីស្នេហាឲ្យពកបុចឡើងលើខ្មោចទើបនឹងស្លាប់ថ្មីៗទាំងឡាយ ។

សេចក្តីសុខកាយសប្បាយចិត្តវិលត្រឡប់ធ្លាក់មកចូលក្នុងបេះដូងនៃសត្វដែលមានសេចក្តីស្នេហាចំពោះគ្នានិងគ្នាវិញ ។

ខាងក្រោយចម្បាំងជាភាតរភាព អនុស្សាវរីយ៍ អាចសំដែងនូវអាការដ៏ប្រពៃ ដ៏សុខឥតចលាចលចំពោះស្រីដែលប្រកបដោយសេចក្តីស្នេហាជាមេផ្ទះ និងចំពោះការគោរពដល់ទឹកដីជាកេរ្តិ៍កោះនិងដល់ជាតិភូមិឲ្យកើតមានក្នុងចិត្តវិញ ។

ការសង្ឃឹមដ៏ធំអស្ចារ្យបំប៉ោងបេះដូងនៃជនទាំងពីរនាក់ ។

ឯណោះ ខាងក្រោយភ្នំទាំងឡាយ ព្រះអាទិត្យដូចជាថាសមាស ក្រហមឆ្អៅយ៉ាងសម្បើម កំពុងលិចចុះឯជើងមេឃ ។ ជនទាំងពីរ គឺ អ៊ីស្មាអ៊ីល និងនាងឡីឡា ស្រវឹងដោយបុណ្យរ៉ាសនាប្រកៀកគ្នាទៅវិញទៅមកដើរសំដៅព្រះអាទិត្យអស្តង្គត ។

ចប់

## អ្នកបំរើផ្ទាល់បានគាប់

៣៤– ថាបើគេសេពគប់ព្រះរាជា, អ្នកមិនមែនប្រធានអាចទៅជាប្រធានបាន, ថាបើវៀរបង់មិនសេពគប់ព្រះរាជាហើយ សូម្បីជាប្រធានក៏ផ្លាស់ងារធ្លាក់ខ្លួនទៅជាមិនមែនប្រធានវិញ ។

៣៥– ព្រះនរបតីតែងរាប់រកតែមនុស្សណាដែលនៅជិតផ្ទាល់ព្រះអង្គ មិនថាអ្នកនោះជាមនុស្សល្ងង់ខ្លៅ មានត្រកូលថោកទាប ឬពុំនោះ មានខ្លួនមិនបានទូន្មានទេ តាមធម្មតា ព្រះរាជាក្ដី ស្ត្រីភាពក្ដី លតាជាតិក្ដី តែងទាក់ទងព័ទ្ធពន្ធតែនឹងអ្នកណា ឬ ដើមឈើណាដែលនៅជិត ។

៣៦– សេវកាមាត្យណា ពិចារណាឃើញច្បាស់នូវចំណុចដែលនាំឲ្យក្រោធ ឬនាំឲ្យរីករាយព្រះទ័យ សេវកាមាត្យនោះ អាចឡើងថ្នាក់បន្តិចម្ដងៗ ជាដរាបទៅបាន ។

៣៧– មនុស្សមានវិជ្ជា មនុស្សប្រាជ្ញាធំ មនុស្សមានសិល្បសាស្ត្រ មនុស្សមានសេចក្ដីក្លាហាន និងមនុស្សចេះប្រព្រឹត្តខ្លួនជាសេវកាមាត្យទាំងអស់នេះ មិនមានទីពឹងអ្នកណាក្រៅអំពីព្រះរាជាទេ ។

បញ្ចតន្ត្រៈ

# រឿងបល្ល័ង្កទិព្វ សាមសិបពីររឿង

រឿងព្រេងតំណាល

## លោកសមិត ម្ចាស់ធម: តែង

## លោកវ៉ាយ-ប៊ុក ក្រមការដើមខ្សែ ប្រែរៀបរៀង

(តមក)

---

## និទានតែរូបទេពនិម្មិតទី ១៨

មានកាលមួយថ្ងៃ មហាកដគោជ: ទ្រង់ស្តេចយាងមកជិតព្រះបល្ល័ង្កទិព្វ ដើម្បីនឹងឲ្យគេអភិសេកព្រះអង្គ ស្រាប់តែរូបទេពនិម្មិតទី ១៨ មានទេវភាថាថា:

" ដើម្បីនឹងឲ្យមានសមត្ថភាពគង់នៅលើព្រះបល្ល័ង្កទិព្វនេះបាន, ព្រះមហាក្សត្រិយត្រូវឲ្យមានព្រះគុណសម្បត្តិ គឺពលភាព, សប្បុរសធម៌ ។ល។ ទូលព្រះបង្គំនឹងក្រាបទូលទ្រង់ ដូចតទៅនេះ៖

" មានកាលមួយថ្ងៃ, មហាកដវិក្រមាទិត្យទ្រង់គង់លើកដបល្ល័ង្ក, នាយទ្វារបាលបានចូលមកធ្វើអញ្ជលិកម្មថ្វាយដំណឹងព្រះអង្គថា សូមទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំទើបនឹងបានស្តាប់រឿងមួយប្លែកអស្ចារ្យ, រឿងនោះដូច្នេះ: នៅលើកំពូលទ្វយ:មានបូជនិយដ្ឋានមួយរបស់នាងទេវតាមួយអង្គ ។ នៅចំមុខបូជនិយដ្ឋាននោះ មានបឹងមួយដែលទូលព្រះបង្គំធ្លាប់ឃើញ បឹងនោះមានជណ្តើរមាសក្បឿព្រោងព្រាយ, មានដាំត្បូង, គជខ្សែនឹងផ្កាថ្ម ។ នៅពាក់កណ្តាលបឹងនោះ មានសសរមាស,

ហើយនៅលើសសរនោះ មានបល្ល័ង្កមាសមួយដាំត្បូង ៗ តាំងពីបច្ចូស-សម័យរហូតដល់ថ្ងៃត្រង់, សសរនោះក៏ឡើងបន្តិចម្តង ៗ ស្ទួយបល្ល័ង្កមាសខ្ពស់ឡើង ៗ ទៅប៉ះព្រះអាទិត្យ; តាំងពីថ្ងៃត្រង់រហូតដល់សាយណ្ហ-សម័យ សសរនោះក៏ស្រុតទាបចុះមក ៗ រហូតមកស្ថិតនៅកណ្តាលបឹងដូចដើម ៗ សសរនេះ មានសភាពប្លែកដូច្នេះរាល់តែថ្ងៃ ៗ

ព្រះបាទវិក្រមាទិត្យដល់ទ្រង់ព្រះសណ្តាប់នាយទ្វារបាលក្រាបទូលរឿងនេះហើយ ទ្រង់មានព្រះរាជបំណងចង់ទតរបស់ប្លែកនោះពន់ពេក, ទ្រង់ក៏ហោះទៅលើអាកាសដោយព្រះសុពណ៌បាទប្រកបដោយរិទ្ធ, រួចទ្រង់ស្តេចយាងចុះទៅលើមាត់បឹង ៗ ដល់ព្រះអរុណរះ, សសរនោះផុះលេចពីទឹកឡើងទៅឯអាកាស ៗ ក្នុងពេលនោះ ព្រះបាទវិក្រមាទិត្យទ្រង់ឡើងគង់លើបល្ល័ង្កមាសនោះ ដែលកំពុងតែអណ្តែតឡើងទៅលើអាកាសជាមួយនឹងសសររហូតទៅដល់វង់ព្រះអាទិត្យ ៗ ដោយត្រូវកំដៅព្រះសុរិយាយ៉ាងខ្លាំង ទ្រង់ក៏ដូចជាគេឆ្អើរសន្ធប់បាត់វិញ្ញាណ ៗ ព្រះអាទិទេពសុរិយា ទ្រង់ទតទៅឃើញទូវវិការភាពនៃព្រះបាទវិក្រមាទិត្យ ទ្រង់សព្វព្រះរាជហឫទ័យពន់ពេក, ទ្រង់ក៏យកទឹកអម្រឹតមកស្រោចលើព្រះកាយព្រះបាទវិក្រមាទិត្យ ៗ ទ្រង់ភ្ញាក់ឡើងដឹងព្រះស្មារតីមាំមួន, ទ្រង់ក៏វន្ទាថ្វាយបង្គំព្រះអាទិទេពសុរិយា, រួចទ្រង់សូត្រថ្វាយពរជ័យមង្គលគ្រប់ប្រការ ៗ ព្រះអាទិទេពសុរិយាទ្រង់សព្វព្រះរាជហឫទ័យនឹងព្រះបរិត្តដែលព្រះបាទវិក្រមាទិត្យទ្រង់សូត្រថ្វាយនោះ, ទ្រង់ក៏ព្រះរាជទានទំហូមាសមួយទម្ងន់១ការៈ ៗ ដល់ទ្រង់បានទំហូមាសពីព្រះអាទិទេពសុរិយា

ហើយ, ទ្រង់ក៏ហោះទៅលើអាកាស ដោយព្រះសុពណ៌បាទមានឫទ្ធិ ហើយក៏ទ្រង់វិលកាន់ព្រះរាជធានីវិញ ។ កនវយៈពាក់កណ្ដាលផ្លូវនៃព្រះរាជដំណើរ ទ្រង់បានជួបប្រទះនឹងបុរសទុគ៌តម្នាក់, ទ្រង់មានព្រះរាជហឫទ័យអាណិតអាសូរពន់ពេក, ទ្រង់ក៏ព្រះរាជទានទូវទំហូមាសនោះទៅបុរសនោះ" ។

ដល់បានក្រាបបង្គំទូលនូវរឿងរ៉ាវនេះចប់សព្វគ្រប់ចំពោះព្រះបាទភោជៈ រូបទេពនិម្មិតទី ១៨ ក៏ទូលបន្ថែមថាៈ "ឱព្រះបាទភោជៈ, បើទ្រង់មានវិជ្ជានុភាពដូចព្រះបាទវិក្រមាទិត្យនេះ, ទ្រង់ទើបអាចគង់លើបល្ល័ង្កទិព្វនេះបាន ។

ព្រះបាទភោជៈទ្រង់ព្រះតម្រិះថា ទ្រង់មិនមានវិជ្ជានុភាពបែបនេះទេ, ទ្រង់ក៏អាក់ខានមិនបានទទួលរាជាភិសេកថ្ងៃនោះ ហើយទ្រង់ស្ដេចចេញពីទីនោះទៅ ។

*
* *

## និទាននៃរូបទេពនិម្មិតទី ១៩

ព្រះបាទភោជៈទ្រង់ស្ដេចយាងមកជិតបល្ល័ង្កទិព្វនោះ ដើម្បីនឹងឲ្យគេធ្វើមុទ្ធាភិសេក, រូបទេពនិម្មិតទី ១៩ មានទេវវាចាថាៈ "ឱមហារាជភោជៈ ទ្រង់មិនអាចគង់នៅលើបល្ល័ង្កទិព្វនេះបានឡើយ, មហារាជដែលទ្រង់មានសមត្ថភាពអាចគង់បាន គឺ ព្រះបាទវិក្រមាទិត្យ, សូមទ្រង់ព្រះសណ្ដាប់នូវរឿងដូចតទៅនេះៈ

"មានកាលមួយថ្ងៃ, ព្រះបាទវិក្រមាទិត្យទ្រង់មានព្រះរាជបំណងចង់ជ្រាបអំពីកិច្ចការប្រជាពស្ត្រីរបស់ព្រះអង្គដែលធ្វើសព្វថ្ងៃ ។ ទ្រង់ក្លែងព្រះរូបហើយ ទ្រង់ហោះទៅលើអាកាសដោយរទេះព្រះសុពណ៌បាទធ្វើព្រះរាជដំណើរត្រង់ទៅត្រើយណា ទ្រង់ស្តេចទៅដល់ទីក្រុងមួយឈ្មោះបទ្មាល័យ (Padmâlaya) ។ នៅទីនោះ ទ្រង់បានទតទៅឃើញបូជនិយដ្ឋានមួយប្លែក ។ មានពួកព្រហ្មចារីនិយាយរឿងទៅវិញទៅមក ។ មានព្រហ្មចារីម្នាក់ពោលថា: "ខ្ញុំបានទៅដល់ប្រទេសមួយ ខ្ញុំបានឃើញទន្លេនឹងភ្នំដែលមានទេវតាជាច្រើនមកពីប្រទេសផ្សេង ៗ មកប្រជុំនៅទីនោះ ។ មានភ្នំមួយនោះឈ្មោះ កនកក្រិត (Kanakakrita), គេមិនអាចទៅដល់បានដោយងាយទេ ព្រោះបើអ្នកណាហ៊ានទៅហើយ មុខជានឹងក្ស័យជីវិតក្នុងពេលនោះ ។ ហេតុនេះ បានជាខ្ញុំគេចមិនចង់ទៅទីនោះឡើយ ព្រោះថាស្រីក្មេង ភោគទ្រព្យនឹងសម្បត្តិឯទៀត ដែលរកបានមកដោយសេចក្តីព្យាយាមហើយធ្វើឲ្យបាត់បង់ទៅវិញ គេអាចផ្លាស់ប្តូរបាន; តែចំពោះរូបកាយបើស្លាប់បាត់បង់ហើយ, បើទុកជាព្យាយាមម៉ឺងម៉ាត់យ៉ាងណាក៏ដោយ ក៏មិនអាចយករូបនោះមកវិញបានឡើយ ។ ហេតុនេះ, សុក្រិតភាព ឬ ជោគជ័យ គឺត្រូវរក្សារូបនោះឲ្យបានស្ថិតស្ថេរតទៅអនាគត" ។

ព្រះមហាក្សត្រិយ៍ទ្រង់បានជ្រាបនូវពាក្យយោគីដែលថ្លែង, ទ្រង់មានព្រះបន្ទូលចំពោះព្រះអង្គឯងថា: "ចំពោះមនុស្សដែលមានឋានៈភាពដ៏ឧត្តម មិនត្រូវមានសកម្មភាពដែលលំបាកធ្វើមិនបាននោះទេ;

ចំពោះបុគ្គលដែលមានបរិយាព្យាយាម សម្រេចទៅតាមបទបញ្ញត្តិគម្ពីរនីតិសាស្ត្រ គ្មានអ្វីដែលលំបាកនឹងប្រព្រឹត្តប្រតិបត្តិសោះឡើយ; ចំពោះបណ្ឌិត, មាតុភូមិ ឬ បរទេសក៏ដូចជាប្រទេសរបស់ខ្លួន; មនុស្សណាដែលពោលវាចាល្អឬពាក្យផ្អែមល្ហែម, មនុស្សនោះមិនមានបច្ចាមិត្រ ” ។ ក្រោយដែលទ្រង់មានព្រះបន្ទូលរួចហើយ, ព្រះមហាក្សត្រិយ៍ទ្រង់ក៏បានហោះទៅលើអាកាសដោយព្រះសុពណ៌បាទដ៏មានរិទ្ធិ, ទ្រង់ស្តេចយាងទៅដល់យោគីដែលស្ថិតនៅក្នុងនគរក្រឹត រួចទ្រង់ប្រថាប់នៅទីនោះ ។

យោគីក្រឡេកឃើញព្រះមហាក្សត្រិយក៏ក្រាបបង្គំទូលថា: “ ឱមហារាជវិក្រមាទិត្យ, សូមទ្រង់ព្រះមេត្តាប្រោស, ហេតុម្តេចក៏ទ្រង់ស្តេចយាងមកកាន់ទីនេះ ? ។ មហារាជទ្រង់មានព្រះបន្ទូលតបថា: “ យើងមកសួរអ្នកឯង ” ។ ក្នុងមួយរំពេចនោះ, យោគីជ្រាបច្បាស់ថាមហារាជវិក្រមាទិត្យ ទ្រង់មានព្រះរូបល្អ ដ៏ឧត្តមជាងមហារាជទាំងឡាយហើយទ្រង់មានព្រះរាជហឫទ័យល្អលើសលប់, ក៏បានថ្វាយនូវវត្ថុពិសិដ្ឋបីយ៉ាងហៅថា កន្ថា (Kanthâ) ១, ខន្ធិកា (Khandikâ) ១, ទន្ឌៈ (Danda) ១, ហើយក៏បានក្រាបបង្គំទូលទ្រង់អំពីគុណសម្បត្តិនៃវត្ថុទាំងបីនោះ :

“ សូមទ្រង់ព្រះមេត្តាប្រោស, អំពីគុណសម្បត្តិនៃវត្ថុកន្ថា, បើទ្រង់ព្រះតម្រិះក្នុងព្រះរាជហឫទ័យចង់បានទ្រព្យសម្បត្តិ, គ្រឿងអលង្ការ, ស្លាប់ព្រះជង្គង់ ឬ ព្រះភូសា ។ល។ ទ្រង់គ្រាន់តែយកព្រះហស្តឆ្វេងពាល់កន្ថានោះ, វត្ថុអ្វីដែលទ្រង់ព្រះតម្រិះចង់បានក៏នឹងចេញមកឯង ៗ ពីកន្ថានោះ ។ ចំណែកវត្ថុដែលហៅថាខន្ធិកា, វាមានចេញនូវចំនួនដី, សេះ, រទេះ,

ទាហានធ្វើដើរ ។ល។ តាមចំនួនដែលព្រះអង្គទ្រង់សរសេរជាលាយលក្ខអក្សរ ។ ឯវត្ថុទន្ទះ, ព្រះអង្គគ្រាន់តែយកព្រះហស្តស្តាំពាល់ហើយ, ក្នុងពេលនោះ បើមនុស្សស្លាប់ក៏ប្រែទៅជាមានជីវិតឡើងវិញ ។ វត្ថុទាំងបីយ៉ាងនេះ ដែលទូលព្រះបង្គំជាខ្ញុំបានដោយកម្លាំងព្យាយាម, ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយចំពោះព្រះអង្គ ព្រោះទូលព្រះបង្គំយល់ថាព្រះអង្គទ្រង់មានព្រះរាជចរិយាល្មមរក្សាវត្ថុនេះបាន ។

ព្រះបាទវិក្រមាទិត្យ ទ្រង់បានវត្ថុដ៏ប្រសើរទាំងបីដោយសេចក្ដីអនុគ្រោះយោគី, ទ្រង់ក៏ធ្វើប្រទក្សិណ រួចទ្រង់ស្ដេចហោះទៅលើអាកាសដោយព្រះសុពណ៌បាទមានរិទ្ធ, ហើយក៏វិលត្រឡប់ទៅកាន់រាជធានីវិញ ។

នៅតាមរយៈផ្លូវនៃព្រះរាជដំណើរ ព្រះបាទវិក្រមាទិត្យ ទ្រង់បានទតឃើញឧត្តមបុរសម្នាក់វង្វេងនៅក្នុងព្រៃហើយ កំពុងមានទុក្ខជាទម្ងន់ ទ្រង់ក៏មានព្រះបន្ទូលសួរទៅឧត្តមបុរសនោះថា: “ឱបុរស, ហេតុម្ដេចក៏អ្នកឯងវង្វេងនៅក្នុងព្រៃនេះ? ”

(មានត)

## មុននិយាយគិតសិន

៣៣- ក្នុងកាលណា បុគ្គលហាមាត់និយាយទៅហើយបានផលចិតថេរយូរ ដូចជាពណ៌ជាប់ឮជិសំពត់សដូច្នោះ ក្នុងកាលណោះ បុគ្គលគប្បីហាមាត់និយាយចុះ ។

បញ្ចតន្ត្រៈ

## ដំណឹងព្រះអនិច្ចធម្ម

# នៃសម្តេចព្រះសុធម្មាធិបតី ពុទ្ធឆាគោ អ៊ុង-ស្រី
# ព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ

ក្នុងកម្ពុជរដ្ឋ

## លោក ប៊ូ-ប៉ូ រៀបរៀង

---

សម្តេចព្រះសុធម្មាធិបតី ប្រឈួនពីថ្ងៃ ៤ ៗ៩ ១ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៣ វិច្ឆិកា ១៩៥៥) ចំនួន ២ ខែ ៧ ថ្ងៃ បានទទួលព្រះអនិច្ចធម្មនៅថ្ងៃ ១ ៗ៣ ៣ ឆ្នាំមមែសប្តស័ក ព. ស. ២៤៩៨ (២៩-៣០ មករា ១៩៥៦) វេលាម៉ោង ៥ ទឹង ២០ នាទី ជិតភ្លឺ ក្នុងព្រះជន្មគំរប់ ៨៥ ឆ្នាំ វស្សា ៦២ នៅទីកុដិរបស់សម្តេច នាវត្តបទុមវតី ។ ឯពិធីបូជាព្រះសពនោះ មិនទាន់កំណត់ពេលនៅឡើយ ។

ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យតាំងព្រះពុទ្ធាចារ្យ កុល-ទេស រាជាគណៈទី ១ ព្រះជន្ម ៦៥ ឆ្នាំ វស្សា ៤៥ ជាព្រះសង្ឃនាយកស្តីទី ទំពំទឹងទ្រង់តាំងជាព្រះសង្ឃនាយកពេញទីតទៅ ។ ទ្រង់តាំងព្រះមង្គលទេពាចារ្យ កែប-ភួង រាជាគណៈទី ១ ព្រះជន្ម ៧៧ ឆ្នាំ វស្សា ៥៧ ជាសម្តេចព្រះមង្គលទេពាចារ្យ ឧត្តមប្រឹក្សាខាងគណៈធម្មយុត្តិកនិកាយ ។

# ប្រវត្តិរូបសង្ខេបនៃសម្ដេចព្រះសុធម្មាធិបតី (១)

សម្ដេច សម្ភពនៅថ្ងៃ៥ ៗ១៣ ១ ឆ្នាំមមែត្រីស័ក ព.ស. ២៤១៣ គ.ស. ១៨៧០ នៅភូមិស្វាយ ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល មាតានាម ណៃ បិតានាម អ៊ុង ។

– ព្រះជន្ម ១២ ឆ្នាំ បិតាអនិច្ចកម្មចោលទៅ សម្ដេចនៅក្នុងសំណាក់មាតា ។

– ព្រះជន្ម ១៣ ឆ្នាំចាប់ផ្ដើមសិក្សាអក្សរសាស្ត្រខ្មែរ នៅក្នុងសំណាក់លោកគ្រូ ឃួន ចៅអធិការវត្តស្វាយ គណៈមហានិកាយ នៅស្រុកកំណើត លុះរៀនចេះចាំល្មមប្រើការបានហើយក៏លាលោកគ្រូវិលទៅនៅផ្ទះជាមួយមាតាវិញ ។

ព្រះជន្ម ១៩ ឆ្នាំ បានចូលបួសជាសាមណេរ ក្នុងសំណាក់លោកគ្រូ ឃួន ជាបព្វជ្ជាចារ្យ នៅវត្តស្វាយដែលបានផ្លាស់មកជាវត្តគណៈធម្មយុត្តិវិញ បួសនៅឆ្នាំជូវឯកស័ក ព.ស. ២៤៣២ គ.ស. ១៨៨៩ ។ បួសបាន ១ វស្សាលាចាកសិក្ខាបទហើយវិលទៅនៅផ្ទះជាមួយមាតាវិញ ។

– ព្រះជន្ម ២២ ឆ្នាំ បានចូលឧបសម្បទជាភិក្ខុភាវៈ ក្នុងសំណាក់នៃសម្ដេចព្រះសុគន្ធាធិបតី បញ្ញាសីលោ ប៉ាន ជាព្រះឧបជ្ឈាយ៍, សម្ដេចព្រះមង្គលទេពាចារ្យ កទ្ធុគោតម អៀម កាលនៅជាព្រះមហាព្រហ្មមុនី ជាកម្មវាចាចារ្យ, លោកគ្រូ ជៀង ចៅអធិការវត្តព្រែកឬស្សី ជាអនុសាវនាចារ្យ មានគណៈសង្ឃ ២០ អង្គគង់ហត្ថបាស បាននាមឆាយាថា "ពុទ្ធនាគោ" សម្រេចញត្តិចតុត្ថកម្មវាចា ក្នុងសីមាវត្ត

---

១ ស្រង់ពីសំណុំរឿងរបស់ក្រសួងធម្មការ ។

បទុមវតី នៅថ្ងៃ៥ ១៥ ៦ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៣៥ គ.ស. ១៨៩៣ លុះស្រេចកិច្ចនេះហើយនិមន្តទៅគង់នៅវត្តស្វាយវិញ ចាប់ផ្តើមសិក្សាព្រះត្រៃបិដកតាំងអំពីវស្សាជាដំបូង ក្នុងសំណាក់លោកគ្រូអាចារ្យ ពៅ កេទគ្រហស្ថ ។

- ព្រះជន្ម ២៥ ឆ្នាំ វស្សាបាន ៤ និមន្តចេញពីវត្តស្វាយមកគង់នៅវត្តបទុមវតី ក្នុងសំណាក់ព្រះគ្រូវិន័យធរ នុត នៅឆ្នាំមមែសប្តស័ក ព.ស. ២៤៣៨ គ.ស. ១៨៩៥ ហើយចាប់សិក្សាព្រះត្រៃបិដកតមកទៀត ក្នុងសំណាក់លោកគ្រូអាចារ្យ ពៅ, ប៉ែន, ឆូរ, ណុប, កែវ, ជាកេទគ្រហស្ថ ។ ក្នុងពេលកំពុងរៀននេះ សម្តេចបានឈ្លៀតបង្រៀនព្រះត្រៃបិដកដល់កូនសិស្សជាច្រើនរូប រហូតអស់វេលា ៣០ ឆ្នាំទើបឈប់ផ្អាក ។

## អំពីសមណៈសក្តិនៃសម្តេច

ទី ១ - ព្រះគ្រូវិន័យធម្ម ទីឋានា ក្នុងព្រះជន្មគំរប់ ៤០ ឆ្នាំ វស្សាបាន១៨ នៅថ្ងៃ៥ ៨ ៦ ឆ្នាំចទោស័ក ព.ស. ២៤៥៣ គ ស.១៩១០ ។

ទី ២ - ព្រះធម្មុត្តម ទីពជាគណៈ ក្នុងព្រះជន្មគំរប់ ៤៣ ឆ្នាំ វស្សាបាន២១ នៅថ្ងៃ១ ។ ១២ ៦ ឆ្នាំឆ្លូវបញ្ចស័ក ព.ស. ២៤៥៦ (១ យូកំង គ.ស. ១៩១៣) ។

ទី ៣ - ព្រះធម្មរីយព្រឹឈ ទីពជាគណៈ ក្នុងព្រះជន្មគំរប់ ៧០ ឆ្នាំ វស្សាបាន៤៨ នៅថ្ងៃ ៦ ២ ១២ ឆ្នាំរោងទោស័ក (១ ខែណូវែម គ.ស. ១៩៤០) ។

ទី ៤ — ស្ដីទីព្រះសង្ឃនាយក ក្នុងព្រះជន្មគំរប់ ៧៤ ឆ្នាំ វស្សាបាន ៥០ នៅថ្ងៃ ៥ ᧱ ៦ ឆ្នាំមមីចត្វាស័ក ព.ស. ២៤៨៥ (៣០ ខែមេសា គ.ស. ១៩៤២) ។ ជាដំណពីសម្ដេចព្រះមង្គលទេពាចារ្យ ស៊ុក ដែលទទួលព្រះអនិច្ចធម្មនៅថ្ងៃខែឆ្នាំខាងលើនេះ ។

ទី ៥ — សម្ដេចព្រះសុធម្មាធិបតី ព្រះសង្ឃនាយកទី ៤ ក្នុងព្រះជន្មគំរប់ ៧៣ ឆ្នាំ វស្សាបាន ៥៣ នៅថ្ងៃ ៧ ᧲ ៧ ឆ្នាំមមែបញ្ចស័ក ព.ស. ២៤៨៦ (១៩ ខែមិថុនា គ.ស. ១៩៤៣) ។

## អំពីគ្រឿងឥស្សរិយយសនៃសម្ដេច

ទី ១ — ធិបឌិន ក្នុងឋានៈជាសម្ដេចព្រះសង្ឃនាយក នៅថ្ងៃ ២ ᧳ ២ ឆ្នាំវកឆស័ក ព.ស. ២៤៨៧ គ.ស. ១៩៤៤ ។

ទី ២ — ម៉េដាយមាស នៅថ្ងៃ ១ ᧤ ៦ ឆ្នាំរកាសប្តស័ក ព.ស. ២៤៨៨ (១៥ ខែមេសា គ ស. ១៩៤៥) ។

(នៅមានគ្រឿងឥស្សរិយយសជាច្រើនទៀត តែពុំបានបញ្ជាក់ក្នុងទីនេះ)

## អំពីកិច្ចការជាស្នាព្រះហស្ដនៃសម្ដេច

ក្នុងសម័យនៃសម្ដេច បានកសាងថាវរវត្ថុជាច្រើនដូចតទៅនេះ ៖

១ — ទីប៉ាឆា ព.ស. ២៤៨៩ គ.ស. ១៩៤៦ ។

២ — សាលាសម្រាប់ទទួលភ្ញៀវ ២ ខ្នងនៅជិតប៉ាឆា ព.ស. ២៤៩២ គ.ស. ១៩៤៩ និងបានធ្វើចិញ្ចើមថ្នល់នៅមុខវត្តផង ។

៣ — សាលាភេសជ្ជៈ ១ ខ្នង ជិតទីប៉ាឆា ព.ស. ២៤៩៣ គ.ស. ១៩៥០

៤ – សាលាបិណ្ឌ ១ ខ្នង ព.ស. ២៤៩២ គ.ស. ១៩៤៩ ។

៥ – សាលាបរិយត្តិធម្មវិន័យ ១ ខ្នង ព.ស. ២៤៩៥ គ.ស. ១៩៥២

៦ – បង្កើតឲ្យមានក្រុមអភិបាលវត្ត ព.ស. ២៤៩៧ គ.ស. ១៩៥៤

៧ – ធ្វើកំពែងខាងលិចទីងខាងជើងវត្ត ព្រមទាំងខ្លោងទ្វារខាងលិចផង ព.ស. ២៤៩៨ គ.ស. ១៩៥៥ ។

៨ – ជួសជុលកំពែងព្រះពោធិព្រឹក្ស ព.ស. ២៤៩៣ គ.ស. ១៩៥០ ។

៩ – រុះរើរោងឆ្លងធ្វើជាថ្មីនៅកន្លែងចាស់ដដែល ព.ស. ២៤៩៨ គ.ស. ១៩៥៥ ។

១០ – ធ្វើជណ្តើរខាងជើង ទីងខាងត្បូងព្រះវិហារ ១ គូទៀតផង ព.ស. ២៤៩៨ គ.ស. ១៩៥៥ ។

ថាវរវត្ថុទាំងអម្បាលនេះ អ្នកឧកញ៉ាមហាមន្ត្រី ញ៉ុក-ទូវ ជាអ្នកទទួលភារៈចាត់ការគ្រប់ចំពូក ក្រោមអធិបតីភាពនៃសម្តេច ។

១១ – សម្តេចបានកសាងព្រះង្គណ៌ ១ នៅវត្តស្វាយ នាស្រុកកំណើត ព.ស. ២៤៩៨ គ.ស. ១៩៥៥ ។

## អំពីប្រឡូង នឹង ទទួលព្រះអភិធម្ម

សម្តេចព្រះសុធម្មាធិបតី ពុទ្ធនាគោ អ៊ុង-ស្រី ព្រះសង្ឃនាយកទី ៤ នៃគណៈធម្មយុត្តិកនិកាយ កម្ពុជរដ្ឋ បានទទួលឋានៈជាព្រះសង្ឃនាយកតាំងពីព្រះជន្ម ៧៣ ឆ្នាំ រហូតដល់ព្រះជន្ម ៨៥ ឆ្នាំ វស្សាបាន ៦២ រួមត្រូវជា ១៣ ឆ្នាំ ។

សម្ដេចចាប់ប្រឈួនបន្តិចៗ តាំងពីថ្ងៃ ៤ ៗ ១ ឆ្នាំមមែ សប្តស័ក ព.ស. ២៤៩៨ (២៣ វិច្ឆិកា ៥៥) រួមវេលាប្រឈួន ២ ខែ និង ៧ ថ្ងៃ បានទទួលព្រះអនិច្ចធម្ម នៅ ១ ៗ៣ ៣ ឆ្នាំដដែល ដោយព្រះរោគជរា នៅវេលាម៉ោង ៥ និង ២០ នាទីឯភ្លឺ (២៩-៣០ មករា ៥៦) ក្នុងព្រះជន្មាយុ ៨៥ ឆ្នាំ វស្សាបាន ៦២ ។

## ពិធីថ្វាយព្រះសុគន្ធវារី[១]

នៅថ្ងៃទី ៣០ មករា ១៩៥៦ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្ដេចព្រះមហាក្សត្រិយានី និងសម្ដេចព្រះឧបយុវរាជ ដែលមានសម្ដេចចៅហ្វាវាំងវរៈវៀងជ័យ អធិបតីស្រីគ្គារ ប៉ែន-នុត, ឯកឧត្ដមឡេង-ង៉ែត ឯកឧត្ដមយឹម-ឌិត, ឯកឧត្ដមសម-សារី ឯកឧត្ដមប្រាក់-ប្រាព្រៀង ជាសមាជិកឧត្ដមប្រឹក្សានៃព្រះមហាក្សត្រិយ៍ ព្រមទាំងរាជបរិពារដទៃទៀតជាច្រើនរូបហែហមអមព្រះអង្គផង ស្ដេចយាងទៅកាន់វត្តបទុមវតី នៅវេលាម៉ោង ១៧ រសៀល ដើម្បីថ្វាយព្រះសុគន្ធវារី ចំពោះព្រះសព នៃសម្ដេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិ ដែលទទួលព្រះអនិច្ចធម្មកាលពីយប់ថ្ងៃទី ២៩ ទៅថ្ងៃទី ៣០ មករានេះ វេលាម៉ោង ៥,២០ នាទីទៀបភ្លឺ ក្នុងព្រះជន្មាយុគំរប់ ៨៥ ព្រះវស្សា ។

នៅទីវត្តបទុមវតី មុនដែលព្រះមហាក្សត្រិយ៍ទាំងពីរព្រះអង្គ និងសម្ដេចព្រះឧបយុវរាជស្ដេចយាងទៅដល់ យើងសង្កេតឃើញសមាជិកនៃរាជរដ្ឋាភិបាល ដែលមានឯកឧត្ដមអ៊ុំ-ឈាងស៊ុន ជានាយក, ឯកឧត្ដម

១ ស្រង់ពីសារពត៌មានកម្ពុជា លេខទី ៣០៨៣ ចុះថ្ងៃពុធ ទី ១ កុម្ភៈ ១៩៥៦ ។

ប្រធានវដ្តសភា, ឯកឧត្តមប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រនិង សមាជិកខ្លះនៃសភាទាំងពីរ អគ្គទូតប្រចាំនៅប្រទេសកម្ពុជា និងនាម៉ឺន សព្វមុខមន្ត្រីនៅក្រសួងផ្សេងៗ ក្នុងរាជធានី បានឈររង់ចាំថ្វាយបង្គំ គោរពព្រះរាជាទាំងពីរព្រះអង្គនៅមុខសាលាបុណ្យ ជំកល់ព្រះសព ។

នៅក្នុងសាលាជិតព្រះសព មានសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ វត្តឧណ្ណាលោម, សម្ដេចព្រះធម្មលិខិត វត្តលង្កា, ព្រះពោធិវង្ស ហួត-តាត និងរាជាគណៈ ឋានានុក្រម ជាច្រើនអង្គ គង់នៅក្បែរព្រះសព ព្រមទាំងមានពួកពុទ្ធបរិស័ទអង្គុយគោរព ព្រះសពនៅទីនោះផង ។

នៅម៉ោង ១៧ ព្រះមហាក្សត្រិយ៍ទាំងពីរព្រះអង្គស្ដេចយាងទៅដល់ ហើយក្រោយដែលព្រះរាជាគោរពក្នុងជាតិ និងទទួលការរាក់ទាក់ពីរដ្ឋ រួចហើយ ស្ដេចយាងចូលទៅកាន់ទីដំកល់ព្រះសព មុនដំបូងព្រះអង្គ ថ្វាយបង្គំព្រះសព, ថ្វាយបង្គំព្រះសង្ឃនិងព្រះពុទ្ធបដិមាករ ដែលដំកល់ ក្បែរព្រះសពនោះ ។ បន្ទាប់ពីនោះភ្លាម អ្នកឧកញ៉ាមហាមន្ត្រីញឹក-ទូវ តាងហ្លួងពិធីការក្នុងព្រះបរមរាជវាំង ថ្វាយព្រះសុគន្ធវារិចំពោះព្រះមហា- ក្សត្រិយ៍ ព្រះអង្គយកព្រះសុគន្ធវារីនេះស្រស់ព្រំលើព្រះសពនៃសម្ដេច ព្រះសុធម្មាធិបតី សង្ឃនាយក, នៅពេលជាមួយនេះ ក្រុមបារគូផ្លុំស័ង្ខ ភ្លេងក្រែនិងភ្លេងខ្លងផ្ទាត់បន្ទំបទមរណសញ្ញា គួរឲ្យសង្វេគដល់សង្ខារមិន ទៀងគ្រប់ៗប្រាណ ។

ការថ្វាយព្រះសុគន្ធវារីនេះ បានធ្វើជាបន្ទាប់ៗមក គឺសម្ដេចព្រះ

មហាក្សត្រិយានី, សម្តេចព្រះឧបយុវរាជ, ក្រុមព្រះរាជវង្សានុវង្ស, សម្តេចចៅហ្វាវាំងវរៈវៀងជ័យ អធិបតីស្រីង្គារ, សមាជិកឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រិយ៍, ប្រធានរដ្ឋសភា, ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, នាយករដ្ឋមន្ត្រី, សមាជិករាជរដ្ឋាភិបាល រហូតដល់អគ្គទូតប្រចាំនៅប្រទេសកម្ពុជាត ៗ មកជាលំដាប់ ៗ លុះចប់ហើយ ព្រះមហាក្សត្រិយ៍ទាំងពីរព្រះអង្គទ្រង់គោរពព្រះសព ស្តេចយាងវិលត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ដែលមានព្រះរាជបរិពារហែហម ដូចកាលស្តេចយាងទៅ ។

## ពិធីតែងតាំងព្រះសង្ឃនាយកគណៈធម្មយុត្តិកថ្មី ក្រោមអធិបតីភាពនៃសម្តេចចៅហ្វាវាំងវរៈវៀងជ័យអធិបតីស្រីង្គារ ប៉ែន-នុត ជាព្រះរាជតំណាង [1]

កាលពីព្រឹកថ្ងៃទី ៣១ មករា ១៩៥៦ មានធ្វើពិធីតែងតាំងព្រះសង្ឃនាយកគណៈធម្មយុត្តិកថ្មី ជំនួសសម្តេចព្រះសុគន្ធាធិបតី សង្ឃនាយកគណៈធម្មយុត្តិ ដែលទទួលព្រះអនិច្ចធម្មកាលពីយប់ថ្ងៃទី ២៩ ទៅថ្ងៃ ៣០ មករា ១៩៥៦ វេលាម៉ោង ៥ និង ២០ នាទី ទៀបភ្លឺ, ក្រោមអធិបតីភាពនៃសម្តេចចៅហ្វាវាំងវរៈវៀងជ័យអធិបតីស្រីង្គារ ប៉ែន-នុត ជាព្រះរាជតំណាងនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ នៅពេលដែលសម្តេចចៅហ្វាវាំងវរៈវៀងជ័យអធិបតីស្រីង្គារ ព្រះរាជតំណាង នៃព្រះករុណាជា

---

១ ស្រង់ពីសារពត៌មានកម្ពុជា លេខ ៣០៨៤ ចុះថ្ងៃព្រហស្បតិ៍ទី ២ កុម្ភៈ ១៩៥៦ ។

អម្ចាស់ជីវិតលើត្បូង ដោយមានអ្នកឧកញ៉ាមហាមន្ត្រី ញ៉ុក-ទូវ ចាងហ្វាង ពិធីការក្នុងព្រះបរមរាជវាំងអមផង បានអញ្ជើញទៅដល់នៅម៉ោង ៩, នោះ គេសង្កេតឃើញឯកឧត្តម ស៊ឹម-វ៉ា ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ឯកឧត្តម ទ្រី ញ-វ៉ាញ រដ្ឋលេខាធិការក្រសួងធម្មការ, ឯកឧត្តម មៀច-គន្ធ ចៅហ្វាយក្រុង, សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំង បុគ្គលិកក្រសួងធម្មការរង់ចាំទទួល, ព្រមទាំងមានកងទាហានរក្សា ព្រះអង្គ ក្រុមតូរ្យតន្ត្រីព្រះរាជទ្រព្យគោរព ជាកិត្តិយសចំពោះព្រះរាជ ដំណាងផង ។

លុះទទួលគារវកិច្ចពីសប្បុរសជនរួចហើយ សម្ដេចអញ្ជើញចូលទៅកាន់ ព្រះវិហារវត្តបទុមវតី ដែលមានជួបជុំព្រះរាជាគណៈ ឋានានុក្រម ភិក្ខុ សាមណេរបាននិមន្តទៅរួមក្នុងពិធីនោះផង ។ ក្រោយដែលព្រះរាជ ដំណាងបានក្រាបថ្វាយបង្គំព្រះសង្ឃរួចហើយ, ឯកឧត្តមទ្រីញ-វ៉ាញ បាន ប្រកាសប្រគេនព្រះសង្ឃ និងជំរាបទីប្រជុំថា សម្ដេចចៅហ្វាវាំងវរៈវៀង ជ័យអធិបតីស្រឹង្គារ ជាព្រះរាជដំណាងព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងថ្វាយព្រះរាជឧង្ការប្រគេនដំណឹង និងជូនប្រាប អំពីការតែងតាំងព្រះ សង្ឃនាយកថ្មី ។ បន្ទាប់មក សម្ដេចព្រះរាជដំណាងបានចាប់ថ្វាយសេចក្ដី នៃព្រះរាជឧង្ការ នូវព្រះបន្ទូលស្បូវសីហនាទ មានសេចក្ដីដូចតទៅ ៖

## ព្រះរាជឱង្ការ នូវព្រះបន្ទូលស្បូវសីហនាទ នៃព្រះបាទ សម្ដេចព្រះនរោត្តម-សុរាម្រិត វិសុទ្ធមហាខត្តិយវង្ស វិសិដ្ឋហ-

វិពង្ស គុណាតិរេក ធម្មបរិយោត្តម បរមបពិត្រ ព្រះចៅព្រះរាជអាណាចក្រកម្ពុជា ជាអម្ចាស់ជីវិតលើត្បូង ។

នៅឱកាស ដែលសម្ដេចព្រះសុធម្មាធិបតី អ៊ុង - ស្រី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ទទួលព្រះអនិច្ចធម្មនៅយប់ថ្ងៃទី ២៩ ទៅ ៣០ មករា ព.ស. ២៤៩៨ ( ១៩៥៦ ) វេលាម៉ោង ៤ នឹង ២០ នាទីឯក្ដី ។

ទ្រង់សព្វព្រះរាជហឫទ័យ តាំងព្រះពុទ្ធាចារ្យ កុល - ទេស រាជាគណៈទី ១ ជាសង្ឃនាយកស្ដីទី ដើម្បីសម្រេចកិច្ចការនានា ក្នុងសង្ឃមណ្ឌលគណៈធម្មយុត្តិ ។

ដូច្នេះ ចាប់តាំងពីថ្ងៃនេះតទៅ ព្រះពុទ្ធាចារ្យ កុល - ទេស មានសិទ្ធិពេញបរិបូណ៌ អាចសម្រេចកិច្ចការផ្សេងៗ ក្នុងគណៈសង្ឃទាំងពួងបាន ទំរាំនឹងតែងតាំងជាសង្ឃនាយកពេញទីតទៅ ។

រីឯព្រះមង្គលទេពាចារ្យ កែប - កួង រាជាគណៈទី ១ ទ្រង់សព្វព្រះរាជហឫទ័យតាំង ជាសម្ដេចព្រះមង្គលទេពាចារ្យ ឧត្តមប្រឹក្សា ខាងគណៈធម្មយុត្តិកនិកាយ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ មករា ព.ស. ២៤៩៨

ព្រះរាជហត្ថលេខា :

នរោត្តម - សុរាម្រិត

នៅពេលដែលចប់សេចក្ដី នៃព្រះរាជឱង្ការ នូវព្រះបន្ទូលសួរសីហនាទ សម្ដេចចៅហ្វាវាំងវរៈវៀងជ័យអធិបតីស្រីង្គារ ជាព្រះរាជ-

តំណាង  ក៏ចាប់មានប្រសាសន៍បន្តទៅទៀត  ដោយសូមឲ្យព្រះថេរា-
នុត្ថេរៈគ្រប់ព្រះអង្គទទួលស្គាល់ ព្រះសង្ឃនាយកស្ដីទីនេះតទៅ ។

តមក  ព្រះសង្ឃទាំងអស់ក៏ចាប់ផ្ដើមស្វាធ្យាយធម៌ជយន្តោ
ប្រសិទ្ធិពរចំពោះព្រះសង្ឃនាយក  និង សម្ដេចព្រះមង្គលទេពាចារ្យ
ឧត្តមប្រឹក្សា ដែលទើបទទួលព្រះឋានន្តរសក្តិថ្មី ។ បន្ទាប់មក ព្រះរាជ-
តំណាងព្រមទាំងឥស្សរជនទាំងអស់  បានអញ្ជើញទៅកាន់មន្ទីរដំកល់
ព្រះសព  ដើម្បីបួងសួងថ្វាយដំណឹងដល់ព្រះសពអំពីការតាំងព្រះសង្ឃ
នាយកស្ដីទីនោះ ដោយមានអ្នកឧកញ៉ាមហាមន្ត្រី ញឹក-នូវ ចាងហ្វាង
ពិធីការក្នុងព្រះបរមរាជវាំង  ជាអ្នកប្រកាសសូមឲ្យព្រះសពបង្វិលមកនូវ
សេចក្តីសុខគ្រប់ប្រការ  ដល់ព្រះថេរានុត្ថេរៈ គណៈធម្មយុត្តិគ្រប់ព្រះ
អង្គផង ។ នៅពេលនោះព្រះសង្ឃទាំងអស់ ក៏បានចំរើនសត្តប្បករណ៍
បង្សុកូលថ្វាយព្រះសព ។ ឥស្សរជនទាំងអស់ ក៏ទទួលអនុមោទនា
ឧទ្ទិសផលចំពោះព្រះវិញ្ញាណក្ខន្ធនៃព្រះសពដែរ ។

ពិធីនេះ បញ្ចប់នៅម៉ោង ៩ និង ៤០ នាទី ។